EXT/MSC-99

របាយការណ៍ស្រាវជ្រាវខ្នាតតូច
ស្ដីពី

គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា
Cooperation Committee for Cambodia
Comité de Coopération pour le Cambodge

# បទពិសោធន៍របស់ក្រុមប្រឹក្សាឃុំ/សង្កាត់ ក្នុងការលើកកំពស់អភិបាលកិច្ចមូលដ្ឋានដោយមានការចូលរួម

## ករណីសិក្សារបស់ឃុំ/សង្កាត់ចំនួនប្រាំនៅក្នុងប្រទេសកម្ពុជា



## ការវិភាគបញ្ហាអភិវឌ្ឍន៍

ស្រាវជ្រាវដោយៈ អតីតសិក្ខាកាមនៃវគ្គ និងក្រុមអ្នកសំរបសំរួលគំរោងអេឌីអាយ

មិនា ឆ្នាំ ២០០៤

library.ncdd.gov.kh
007459

បណ្ណាល័យ
គ.ជ.អ.ប

# បទពិសោធន៍របស់ក្រុមប្រឹក្សាឃុំ/សង្កាត់ ក្នុងការលើកកំពស់អភិបាលកិច្ចមូលដ្ឋានដោយមានការចូលរួម

## ករណីសិក្សារបស់ឃុំ/សង្កាត់ចំនួនប្រាំនៅក្នុងប្រទេសកម្ពុជា

**ការវិភាគបញ្ហាអភិវឌ្ឍន៍**

ស្រាវជ្រាវដោយៈ អតីតសិក្ខាកាមនៃវគ្គ និងក្រុមអ្នកសំរបសំរួលគំរោងអេឌីអាយ

មិនា ឆ្នាំ ២០០៤

352.74
EXP
sh: DAD

# មាតិការឿង


| | ទំព័រ |
|---|---|
| **សេចក្តីថ្លែងអំណរគុណ** | ៣ |
| **សេចក្តីសង្ខេប** | ៤ |
| **អក្សរកាត់** | ៥ |
| **សេចក្តីផ្តើម** | ៦ |
| គោលបំណង | ៦ |
| សំណួរគន្លឹះ | ៧ |
| សម្រង់ឯកសារ | ៨ |
| វិធីសាស្ត្រនៃការស្រាវជ្រាវ | ១១ |
| ទំហំនិងដែនកំណត់ | ១២ |
| **លទ្ធផលរកឃើញ និងការវិភាគ** | ១៣ |
| រដ្ឋបាលឃុំ | ១៣ |
| ការរៀបចំ និងអនុវត្តន៍ផែនការ | ១៧ |
| ភាពជាដៃគូរវាងក្រុមប្រឹក្សាឃុំ និងសង្គមស៊ីវិល | ២១ |
| ការទំនាក់ទំនងរវាងរដ្ឋាភិបាលនៅថ្នាក់ជាតិ និងគណបក្សនយោបាយ | ២៥ |
| **សេចក្តីសន្និដ្ឋាន** | ២៨ |
| ការរៀនសូត្រពីបទពិសោធន៍របស់ក្រុមប្រឹក្សាឃុំ | ២៨ |
| ការរួមចំណែកការកាត់បន្ថយភាពក្រីក្រ និងលទ្ធិប្រជាធិបតេយ្យនៅមូលដ្ឋាន | ៣១ |
| **អនុសាសន៍សំរាប់អង្គការមិនមែនរដ្ឋាភិបាល** | ៣៣ |
| ឧបសម្ព័ន្ធ ១: ករណីសិក្សា ទី១ | ៣៥ |
| ឧបសម្ព័ន្ធ ២: ករណីសិក្សា ទី២ | ៤៥ |
| ឧបសម្ព័ន្ធ ៣: ករណីសិក្សា ទី៣ | ៥៥ |
| ឧបសម្ព័ន្ធ ៤: ករណីសិក្សា ទី៤ | ៦៤ |
| ឧបសម្ព័ន្ធ ៥: ករណីសិក្សា ទី៥ | ៧២ |
| ឧបសម្ព័ន្ធ ៦: សិក្ខាកាម និងអ្នកស្រាវជ្រាវ អេឌីអាយ | ៧៩ |

# សេចក្តីថ្លែងអំណរគុណ

ក្រុម **អេឌីអាយ** និងសិក្ខាកាមសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ ក្រុមប្រឹក្សាឃុំសង្កាត់ដែលបានចូលរួមក្នុងការស្រាវជ្រាវនេះ រួមទាំងតំណាងសង្គមស៊ីវិល ប្រជាជនរស់នៅតាមសហគមន៍ មន្ត្រីថ្នាក់ស្រុក បុគ្គលិករបស់កម្មវិធីសីលា និងក្រុមអ្នកអភិវឌ្ឍន៍ដែលបានចែករំលែកបទពិសោធន៍ និងបញ្ចេញទស្សនៈជាមួយនឹងយើងខ្ញុំ។ ក្រុមរបស់យើង និងសិក្ខាកាមក៏សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ Shelley និង Ismael Transmonte ដែលបានជួយជ្រោមជ្រែងក្នុងការរៀបចំក្របខ័ណ្ឌនៃការស្រាវជ្រាវតាំងពីដំបូងមក ។ ក្រុមអ្នកស្រាវជ្រាវរបស់**អេឌីអាយ** សូមថ្លែងអំណរគុណផងដែរ ចំពោះអ្នកដែលបានជួយសំរួលដល់ការងារនៅតាមមូលដ្ឋាន ជាពិសេស លោក **ទេង ប៊ុនរិទ្ធិ** អង្គការទស្សនៈពិភពលោក Georg Deichert និង **សុង សាយ័ន** អង្គការ GTZ **ម៉ម សម្បត្តិ** និង **ឈឹម ផារឿន** អង្គការស៊ីដសេ Joanne Morrison និង **ចេង សំណាង** PLG និង Mark Munoz និង Kim Miratori អង្គការ Concern Worldwide ។ ទស្សនៈដែលបញ្ចេញនៅក្នុងឯកសារស្រាវជ្រាវនេះ គឺជាការទទួលខុសត្រូវរបស់ក្រុមអ្នកនិពន្ធតែម្នាក់ឯងតែប៉ុណ្ណោះ ។

# សេចក្ដីសង្ខេប


ការស្រាវជ្រាវរបស់ គំរោងការវិភាគបញ្ហាអភិវឌ្ឍន៍ (អេឌីអាយ) គឺដើម្បីពិនិត្យមើលបទពិសោធន៍របស់ក្រុមប្រឹក្សាឃុំក្នុងការលើកកំពស់អភិបាលកិច្ចមូលដ្ឋានដោយមានការចូលរួម ។ ករណីសិក្សាចំនួន ៥ ត្រូវបានលើកឡើង ដោយធ្វើការអង្កេតមើលទៅលើ ការប្រែប្រួលនៃរដ្ឋបាលឃុំ ដំណើរការនៃការធ្វើផែនការ និងការអនុវត្តន៍សកម្មភាពអភិវឌ្ឍន៍ ភាពជាដៃគូរវាងក្រុមប្រឹក្សាឃុំនិងសង្គមស៊ីវិល និងទំនាក់ទំនងរវាងក្រុមប្រឹក្សាឃុំ និងតំណាងរដ្ឋាភិបាលថ្នាក់ជាតិ និងទីភ្នាក់ងារនានា ព្រមទាំងមន្ត្រីគណបក្សនយោបាយ ។ ការស្រាវជ្រាវនេះចងក្រងសមិទ្ធិផល ដែលសំរេចបាននៅក្នុងវិស័យទាំងនេះ និងពិនិត្យមើលបញ្ហាប្រឈមមុខដែលត្រូវដោះស្រាយនៅក្នុងវិស័យនីមួយៗ ។

គេបានរកឃើញបញ្ហាប្រឈមមុខសំខាន់ៗមួយចំនួន ។ ពិសេស ក្រុមប្រឹក្សាឃុំជាទូទៅមិនមានទំនាក់ទំនងជិតស្និទ្ធល្អជាមួយនឹងអ្នកភូមិសាមញ្ញឡើយ ។ គំរោងដែលទទួលលុយពីថវិកាឃុំមានប្រសិទ្ធិភាពតិចតួចលើការកាត់បន្ថយភាពក្រីក្រ ។ កម្មវិធីដែលដើរទន្ទឹមគ្នារបស់អង្គការមិនមែនរដ្ឋាភិបាល អាចនឹងធ្វើអោយការខិតខំប្រឹងប្រែងរបស់ក្រុមប្រឹក្សាឃុំក្លាយទៅជាអសកម្មទៅវិញ ។ រីឯអ្នកប្រកាន់គណបក្សក៏បានធ្វើអោយខូចប្រសិទ្ធិ-ភាពការងាររបស់ក្រុមប្រឹក្សាឃុំខ្លះដែរ ។ នៅទីបំផុត ការបង្កើនលទ្ធិប្រជាធិបតេយ្យនៅតាមមូលដ្ឋាន តំរូវអោយមានការកែប្រែដ៏ធំធេងនៅក្នុងសង្គម ។ ទោះបីជាមានឧបសគ្គយ៉ាងនេះក្ដី ការស្រាវជ្រាវអាចសន្និដ្ឋានបានថាបទពិសោធន៍របស់ក្រុមប្រឹក្សាឃុំពីដំបូងបានជួយជំរុញឱ្យមានការកែទំរង់កម្មវិធីវិមជ្ឈការយ៉ាងច្រើន ។ ទោះបីជាមកដល់ពេលនេះ ភាពជឿនលឿនទទួលបានមិនស្មើគ្នា ហើយមិនឃើញមានអ្វីច្បាស់លាស់ក្ដី តែបើគិតពីពេលវេលាដ៏ខ្លីវិញ ឃើញថាមានការសំរេចបានច្រើនហើយ ។

# អក្សរកាត់

| | |
|---|---|
| ADI | ការវិភាគបញ្ហាអភិវឌ្ឍន៍ |
| CARERE | គំរោងស្តីពីការស្តារនីតិសម្បទា និងការតាំងទីលំនៅឡើងវិញនៅកម្ពុជា |
| CBRD | ការកសាងសមត្ថភាពសំរាប់ការអភិវឌ្ឍន៍ជនបទ |
| CCSP | គំរោងគាំទ្រក្រុមប្រឹក្សាឃុំ/សង្កាត់ |
| CDP | ផែនការអភិវឌ្ឍន៍ឃុំ/សង្កាត់ |
| CDRI | វិទ្យាស្ថានស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា |
| CEDAC | មជ្ឈមណ្ឌលសិក្សានិងអភិវឌ្ឍន៍កសិកម្មកម្ពុជា |
| CIDSE | កិច្ចសហប្រតិបតិការអន្តរជាតិដើម្បីអភិវឌ្ឍន៍និងសាមគ្គីភាព |
| CPP | គណបក្សប្រជាជនកម្ពុជា |
| DFT | ក្រុមសំរបសំរួលថ្នាក់ស្រុក |
| DIW | សិក្ខាសាលាសមាហរណកម្មថ្នាក់ស្រុក |
| DOLA | នាយកដ្ឋានរដ្ឋបាលមូលដ្ឋាន |
| E&D | កុមារនិងការអភិវឌ្ឍន៍ |
| FAO | អង្គការស្បៀងអាហារនិងកសិកម្ម |
| GTZ | Gesellschaft fur Technische Zusammenarbeit |
| HEKS | Hilfswerk der Evagelischen Kirchen Schweiz |
| ICD | អភិវឌ្ឍន៍សហគមន៍ចំរុះ |
| IFSP | កម្មវិធីសន្តិសុខស្បៀងចំរុះ |
| NGO | អង្គការមិនមែនរដ្ឋាភិបាល |
| PBC | គណៈកម្មាធិការរៀបចំផែនការនិងថវិកា |
| PLG | ភាពជាដៃគូសំរាប់អភិបាលកិច្ចមូលដ្ឋាន |
| POLA | ការិយាល័យខេត្តសំរាប់គ្រប់គ្រងរដ្ឋបាលមូលដ្ឋាន |
| PRA | ការវាយតំលៃនៅតាមជនបទដែលមានលក្ខណៈចូលរួម |
| RACHA | សម្ព័ន្ធភាពដើម្បីសុខភាពកុមារនិងសុខភាពបន្តពូជ |
| RDRP | កម្មវិធីស្តារនីតិសម្បទា និងអភិវឌ្ឍន៍ជនបទ |
| UNDP | កម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ |
| VDC | គណៈកម្មការអភិវឌ្ឍន៍ភូមិ |
| WFP | កម្មវិធីស្បៀងអាហារពិភពលោក |
| WVC | ទស្សនៈពិភពលោកកម្ពុជា |

# សេចក្តីផ្តើម

ចាប់តាំងពីការបោះឆ្នោតឃុំ/សង្កាត់នៅក្នុងខែកុម្ភៈ ឆ្នាំ ២០០២ មក មន្ត្រីក្រុមប្រឹក្សាឃុំ/សង្កាត់ដែលបានជាប់ឆ្នោត ត្រូវបានតំរូវអោយអនុវត្តគោលនយោបាយវិមជ្ឈការដែលកំណត់ដោយរដ្ឋាភិបាល ។ ជារួមមិនត្រឹមតែការកែទំរង់រដ្ឋបាលប៉ុណ្ណោះទេ តែក៏មានការរៀបចំ និងការអនុវត្តផែនការផងដែរ ។ តាមពិតទៅក្រុមប្រឹក្សាឃុំ/សង្កាត់ត្រូវការពេលវេលាគ្រប់គ្រាន់ ដើម្បីបំពេញតួនាទីរបស់គេអោយបាន ពេញលេញតាមការដែលគេរំពឹងទុក ។ យ៉ាងណាក៏ដោយ មានការសំរេចបានភាពជឿនលឿនខ្លះនៅក្នុងដំណើរនៃការធ្វើវិមជ្ឈការជាពិសេស ក្រុមប្រឹក្សាឃុំ/សង្កាត់ដែលបានទទួលការគាំទ្រយ៉ាងខ្លាំងក្លាពីរដ្ឋាភិបាល និងអង្គការនានា ។

ការសិក្សាស្រាវជ្រាវពិសេសរបស់គំរោង ស្តីពីការវិភាគបញ្ហាអភិវឌ្ឍន៍ (ADI) ពិនិត្យមើលទៅលើបទពិសោធន៍របស់ក្រុមប្រឹក្សាឃុំ ដែលទទួលបានការគាំទ្រយ៉ាងពេញទំហឹងពីទីភ្នាក់ងារនានា ។ ករណីសិក្សាចំនួន៥ត្រូវបានលើកឡើងដោយផ្តោតទៅលើបទពិសោធន៍របស់ឃុំចំនួន៥ ដែលឃុំនិមួយៗត្រូវបាន ជ្រើសរើសនិងគាំទ្រដោយអង្គការដូចតទៅ: World Vision Cambodia (Takeo), GTZ (Kampot), CIDSE (Kampot), PLG (Pursat) និង Concern Worldwide (Pursat) [១] ។ វិស័យដែលត្រូវស្រាវជ្រាវរួមមានការប្រែប្រួលរដ្ឋបាលឃុំ ដំណើរការនៃការធ្វើផែនការ និងការអនុវត្តសកម្មភាពអភិវឌ្ឍន៍ ភាពជាដៃគូរវាងក្រុមប្រឹក្សាឃុំនិងសង្គមស៊ីវិល ទំនាក់ទំនងរវាងក្រុមប្រឹក្សាឃុំនិងតំណាងរដ្ឋាភិបាលថ្នាក់ជាតិ និង ទីភ្នាក់ងារនានា និងគណៈបក្សនយោបាយ ។ ការស្រាវជ្រាវតាមរយៈឯកសារ និងការប្រៀបធៀបបទពិសោធន៍ នៅក្នុងឃុំទាំង៥ជាមេរៀនដែលគួររៀនសូត្រតាម ក្នុងការជំរុញឱ្យមានអភិបាលកិច្ចមូលដ្ឋានដែលមានការចូលរួម ។ ដូច្នេះការស្រាវជ្រាវនេះ មានបំណងចង់រួមចំណែកដល់ការប្រឹងប្រែងទូទៅ ក្នុងការពង្រឹងដំណើរការវិមជ្ឈការ នៅក្នុងប្រទេសកម្ពុជា ។

## គោលបំណង

១. ពិនិត្យមើលការប្រែប្រួលដែលកើតមាននៅក្នុងរដ្ឋបាលឃុំ ចាប់តាំងពីពេលបោះឆ្នោតឃុំមក ។

២. ពិនិត្យមើលដំណើរការការងាររបស់ក្រុមប្រឹក្សាឃុំ ក្នុងការធ្វើផែនការ និងការអនុវត្តសកម្មភាពអភិវឌ្ឍន៍ ។

---

[១] គួរកត់សំគាល់ថាការគាំទ្រដែលសហគមន៍ទាំងនេះទទួលបានមិនមែនសុទ្ធតែបានមកពីអង្គការដែលជ្រើសរើសនោះទេ ។ PLG ជួយដល់កម្មវិធីសីលារបស់រដ្ឋាភិបាលនៅក្នុងឃុំទាំង៥ ចំណែកឯអង្គការ Concern Worldwide ជួយនៅក្នុងឃុំដែលជ្រើសរើស ដោយ PLG ។

៣. ស្វែងយល់ចរិតលក្ខណៈ និងភាពជាដៃគូរវាងក្រុមប្រឹក្សាឃុំ និងសង្គមស៊ីវិល ។
៤. វាយតំលៃលើចរិតលក្ខណៈ នៃការទំនាក់ទំនងជាមួយតំណាងរដ្ឋាភិបាល ទីភ្នាក់ងារនានា និង គណបក្សនយោបាយ ។

## សំណួរគន្លឹះ

ការប្រែប្រួលរដ្ឋបាលឃុំសង្កាត់

១. តើមានការប្រែប្រួលក្នុងរដ្ឋបាលឃុំដែរឬទេ ចាប់តាំងពីពេលបោះឆ្នោតក្រុមប្រឹក្សាឃុំមក?
២. តើអ្វីខ្លះដែលបានប្រែប្រួល? តើអ្វីខ្លះដែលមិនប្រែប្រួល?
៣. តើអ្នកដែលមានការពាក់ព័ន្ធនៅក្នុងឃុំយល់យ៉ាងណាដែរចំពោះការប្រែប្រួលទាំងនេះ?

ដំណើរការនៅក្នុងការធ្វើផែនការ និងការអនុវត្តសកម្មភាពអភិវឌ្ឍន៍នានា

១. តើក្រុមប្រឹក្សាឃុំ និងគណៈកម្មាធិការផែនការនិងថវិកា អាចធ្វើផែនការអភិវឌ្ឍន៍ឃុំបានឬទេ? តើគេមានយុទ្ធសាស្ត្រអ្វីខ្លះ? តើគេសំរេចអ្វីបានហើយ?តើកត្តាអ្វីខ្លះដែលមានឥទ្ធិពលលើការធ្វើផែនការរបស់គេ?
២. តើក្រុមប្រឹក្សាឃុំ និងគណៈកម្មាធិការផែនការនិងថវិកា អាចអនុវត្តន៍ការងារអភិវឌ្ឍន៍បានដែរឬទេ? តើគេមានយុទ្ធសាស្ត្រអ្វី? តើគេសំរេចបានអ្វីខ្លះហើយ? តើកត្តាអ្វីខ្លះដែលប៉ះពាល់ដល់សមត្ថភាពរបស់គេក្នុងការអនុវត្តន៍សកម្មភាព?

ភាពជាដៃគូរវាងក្រុមប្រឹក្សាឃុំ និងសង្គមស៊ីវិល

១. តើភាពជាដៃគូរដែលកើតឡើងរវាងក្រុមប្រឹក្សាឃុំ និងសង្គមស៊ីវិលឈានដល់កំរិតណា? តើការសហការ និងការសំរបសំរួលផ្តោតទៅលើវិស័យអ្វីខ្លះ?
២. តើកត្តាអ្វីខ្លះដែលជួយដល់ការលើកកំពស់ (ការធ្លាក់ចុះ) ភាពជាដៃគូរវាងក្រុមប្រឹក្សាឃុំ និង សង្គមស៊ីវិល?
៣. តើការចូលរួម ឬការមិនចូលរួមរបស់សង្គមស៊ីវិលប៉ះពាល់យ៉ាងណាខ្លះដល់អភិបាលកិច្ចមូលដ្ឋាន?

ទំនាក់ទំនងរវាងរដ្ឋាភិបាលថ្នាក់ជាតិ និងគណបក្សនយោបាយនានា

១. តើក្រុមប្រឹក្សាឃុំមានទំនាក់ទំនងដោយផ្ទាល់ជាមួយនឹងតំណាងរដ្ឋាភិបាលឬទេ? តើទំនាក់ទំនងនេះ (ឬកង្វះទំនាក់ទំនង) ប៉ះពាល់ដល់ការអនុវត្តន៍ការងាររបស់គេយ៉ាងម៉េចដែរ?

២. តើក្រុមប្រឹក្សាឃុំមានការទាក់ទងយ៉ាងដូចម្តេចខ្លះជាមួយនឹងអភិបាលស្រុក? ជាមួយនឹងតំណាងនៃមន្ទីរក្រសួងដែលពាក់ព័ន្ធនានា? តើទំនាក់ទំនងនេះមានការទាក់ទងយ៉ាងដូចម្តេច ទៅនឹងការងារអនុវត្តន៍របស់ក្រុមប្រឹក្សាឃុំ?

៣. តើក្រុមប្រឹក្សាឃុំមានការចូលរួមជាមួយគណបក្សនយោបាយលើសពីមួយឬ? តើទំនាក់ទំនងនេះមានការប៉ះពាល់យ៉ាងដូចម្តេចទៅនឹងការងារអនុវត្តន៍របស់ក្រុមប្រឹក្សាឃុំ?

## សម្រង់ឯកសារ

នៅក្នុងខែកក្កដា ឆ្នាំ២០០១ David Ayers ដែលនៅពេលនោះជាប្រធាននៃ CCSP បានពិនិត្យមើលលើប្រភពឯកសារចំនួនប្រហែល ១០០ ដោយផ្តោតទៅលើបញ្ហាការធ្វើវិមជ្ឈការដែលត្រូវបានគេមើលឃើញថាមានលក្ខណៈបង្គាប់បញ្ជាចំពោះប្រទេសកម្ពុជា[២] ។ ចំណុចសំខាន់ៗដែលស្រង់ចេញមកនេះ ត្រូវបានលើកយកមកបង្ហាញនៅក្នុងរបាយការណ៍ ដើម្បីលើកជាសំណួរនៅក្នុងការស្រាវជ្រាវនេះឱ្យបានកាន់តែទូលំទូលាយ ។

ការពិនិត្យរបស់ CCSP បង្ហាញឱ្យឃើញមានលក្ខខ័ណ្ឌបួនដើម្បីធ្វើអោយដំណើរការវិមជ្ឈការទទួលជោគជ័យ ។ ១) ក្របខ័ណ្ឌច្បាប់ដែលត្រូវបានកំណត់ច្បាស់ ។ ២) ស្ថាប័នប្រកបដោយសមត្ថភាព ។ ៣) ប្រព័ន្ធនៃគណនេយ្យភាព និង ៤) សង្គមស៊ីវិលដែលសកម្ម ។ បើនិយាយអោយខ្លី ក្របខ័ណ្ឌច្បាប់គួរចែងឱ្យច្បាស់អំពីស្ថាប័នដែលត្រូវធ្វើវិមជ្ឈការ បង្ហាញពីការដែលស្ថាប័នទាំងនោះត្រូវបានបង្កើតឡើង បង្ហាញអោយឃើញច្បាស់ពីទំនាក់ទំនងរវាងស្ថាប័នទាំងនោះទៅនឹងស្ថាប័នដទៃទៀត ។ ស្ថាប័នដែលត្រូវបានធ្វើវិមជ្ឈការក៏គួរតែមានសមត្ថភាពនៅក្នុងការអនុវត្តន៍អំណាច និងការទទួលខុសត្រូវដែលត្រូវបានគេប្រគល់អោយ ដោយរួមទាំងការមានថវិកា និងសមត្ថភាពគ្រប់គ្រាន់នៅក្នុងការផ្តល់សេវាល្អៗ ។ ដូច្នេះប្រព័ន្ធវិមជ្ឈការត្រូវតែធានាថាប្រជាជនអាចចូលរួមយ៉ាងសកម្មនៅក្នុងការសំរេចចិត្តរបស់រដ្ឋបាលមូលដ្ឋាន ហើយអាចតាមដានការអនុវត្តន៍ការងាររបស់មន្ត្រីនៅតាមមូលដ្ឋាន ។ ទាក់ទងនឹងរឿងនេះ សង្គមស៊ីវិលត្រូវជំរុញឱ្យមានការចូលរួមយោបល់ពីប្រជាជននៅក្នុងអភិបាលកិច្ចមូលដ្ឋាន ហើយធ្វើអោយមន្ត្រីមានការទទួលខុសត្រូវចំពោះទង្វើរបស់គេ ។ ដូច្នេះ ការពិនិត្យមើលឡើងវិញរបស់ CCSP បានបង្ហាញឱ្យឃើញថា ការកែទំរង់វិមជ្ឈការគួរតែដាក់បញ្ចូលរួមមាន: ១) ក្របខ័ណ្ឌច្បាប់ និងនយោបាយដែលងាយយល់ ដោយមានការគាំទ្រយ៉ាងពេញទំហឹងពីរដ្ឋាភិបាល។ ២) ការរៀបចំ

[២] David Ayers, Decentralization: A Review of the Literature, (Phnom Penh: Commune Council Support Project, July 2001)

ផ្នែកសារពើព័ន្ធបានគ្រប់គ្រាន់ ។ ៣) យន្តការដើម្បីលើកកំពស់តម្លាភាព ៤) យន្តការសំរាប់លើកទឹកចិត្តអោយសង្គមស៊ីវិលមានការចូលរួម ។

សម្រង់ឯកសាររបស់ CCSP ផ្តោតផងដែរទៅលើសក្តានុពលផលប្រយោជន៍ នៃការធ្វើវិមជ្ឈការ ។ សម្រង់ឯកសារនេះ លើកឡើងនូវវិស័យមួយចំនួនដែលការធ្វើវិមជ្ឈការទទួលបាន ។ ទី១ វិមជ្ឈការត្រូវបានគេមើលឃើញថា ដើម្បីពង្រឹងស្ថាប័ននៅថ្នាក់ក្រោម ។ គេក៏មើលឃើញផងដែរថាវាជួយជំរុញអោយមានការចូលរួមរបស់ប្រជាជននៅក្នុងបញ្ហាអភិបាលកិច្ច ។ នៅពេលដែលវិមជ្ឈការក្លាយទៅជាផ្នែកមួយនៃការកែទំរង់បែបលទ្ធិប្រជាធិបតេយ្យ ពេលនោះវាអាចបង្កើនការយកចិត្តទុកដាក់ពីសំណាក់រដ្ឋាភិបាល ។ ដូច្នេះ វិមជ្ឈការអាចបង្កើនការផ្តល់និងផ្លាស់ប្តូរពត៌មានរវាងរដ្ឋាភិបាលនិងប្រជាជន ។ បន្ថែមពីលើនេះទៀត គេមើលឃើញថា វិមជ្ឈការ ជួយធ្វើអោយមាននិរន្តភាពនៃគំរោងអភិវឌ្ឍន៍ លើកកំពស់តម្លាភាពនៃស្ថាប័នរដ្ឋាភិបាលបង្កើនការទទួលខុសត្រូវរបស់មន្រ្តីចំពោះប្រជាជនដែលបោះឆ្នោតអោយគេ ផ្តល់ឱកាសច្រើនអោយមានការចូលរួមនៅក្នុងកិច្ចការនយោបាយ ។ ដូច្នេះ វិមជ្ឈការអាចពង្រឹងការខិតខំដើម្បីបណ្តុះលទ្ធិប្រជាធិបតេយ្យនៅទូទាំងប្រទេស ។

នៅក្នុងវិស័យផ្សេងទៀត វិមជ្ឈការមិនសូវមានប្រសិទ្ធិភាពច្រើនប៉ុន្មានទេ ។ ឧទាហរណ៍ កម្មវិធីអភិវឌ្ឍន៍ដែលជាផ្នែកមួយនៃវិមជ្ឈការ បានឆ្លើយតបច្រើនទៅនឹងសេចក្តីត្រូវការរបស់អ្នកមូលដ្ឋាន តែច្រើនផ្តោតទៅលើគំរោងហេដ្ឋារចនាសម្ព័ន្ធតូចៗ ។ ការផ្ទេរអំណាចទៅថ្នាក់ក្រោមត្រូវបានគេយល់ថា ជាការពង្រឹងការប្តេជ្ញាចិត្តរបស់រដ្ឋាភិបាលថ្នាក់ជាតិចំពោះការអភិវឌ្ឍន៍ជនបទ តែរដ្ឋអំណាចថ្នាក់ខ្ពស់នៅតែមានការជំទាស់ខ្លះ ។ ពិតមែនតែការកែទំរង់បែបវិមជ្ឈការអាចផ្តល់សិទ្ធិអំណាចដល់សហគមន៍នៅតាមមូលដ្ឋាន ក្នុងការទប់ទល់នឹងឥទ្ធិពលដែលគេមិនចង់បានពីលោកខាងលិច តែវាអាចធ្វើអោយគេមានជំនឿ និងទំលាប់អនុវត្តន៏ការងារតាមបែបថ្មីកាន់តែច្រើន។ អាចនិយាយថា វិមជ្ឈការមិនធ្វើអ្វីបានច្រើននៅក្នុងការលើកកំពស់ផលប្រយោជន៍របស់ក្រុមសាសនា ជនជាតិភាគតិច និងនារីបានឡើយ ។ កត្តាសំខាន់គឺវិមជ្ឈការផ្តល់ឱកាស អោយមានការសហប្រតិបត្តិការជាមួយគ្នានៅក្នុងន័យស្ថាបនារវាងអង្គការមិនមែនរដ្ឋាភិបាល និងរដ្ឋអំណាចមូលដ្ឋាន តែទាល់តែការសង្ស័យដែលបានចាក់ឫសនោះត្រូវបានបំបាត់ចោលអោយអស់សិន ។ ក្រៅពីនេះទៀត ឯកសារនោះមិនបានបញ្ជាក់ឱ្យច្បាស់ពីទំនាក់ទំនងរវាងការកែទំរង់បែបវិមជ្ឈការ និងការកាត់បន្ថយអំពើពុករលួយទេ ។

បើគិតអោយមែនទែនទៅ ការពិនិត្យមើលឯកសាររបស់ CCSP កំណត់ឱ្យឃើញពីដែនកំណត់នៃការធ្វើវិមជ្ឈការ ។ តួរឱ្យចំលែក ឯកសារនោះបង្ហាញថាវិមជ្ឈការ មានផលវិជ្ជមានតិចតួចទៅលើការកាត់បន្ថយភាពក្រីក្រ ។ ហេតុផលចំពោះរឿងនេះគឺថា អ្នកមានអំណាចនៅតាមមូលដ្ឋានច្រើនកៀបសង្កត់ទៅលើប្រព័ន្ធនយោបាយនៅតាមមូលដ្ឋាន ហើយទាញយកផលប្រយោជន៍ពីការកៀបសង្កត់នេះ ។ សភាពការណ៍បែបនេះពិតជាមានទំនាក់ទំនងចំពោះប្រទេសកម្ពុជា ដោយសារទិសដៅនៃការកែទំរង់វិមជ្ឈការរបស់រដ្ឋាភិបាលគឺផ្តោតទៅលើការកាត់បន្ថយភាពក្រីក្រ ។ ក្រៅពីនេះ វិមជ្ឈការមានជោគជ័យតិចតួចនៅក្នុងការជំរុញការចូលរួមរបស់សហគមន៍នៅក្នុងការអភិវឌ្ឍន៍ ។ ហេតុការណ៍នេះបណ្តាលមកពីទីតាំងចំពេក ឬធំជាងស្ថាប័នវិមជ្ឈការដែលជាគំនិតផ្តួចផ្តើមរបស់រដ្ឋាភិបាលបានគ្រោងទុក ការប្រកួតប្រជែងនៅក្នុងការបោះឆ្នោតនៅក្នុងភូមិ ឬវិសមភាពនៅក្នុងចំណោមភូមិ។ ក្រៅពីនេះ វិមជ្ឈការត្រូវបានគេមើលឃើញថាឆ្លើយតបតិចតួចនៅក្នុងការកាត់បន្ថយការចំណាយទូទៅរបស់រដ្ឋាភិបាល ផ្ទេរធនធានទៅមូលដ្ឋាន ហើយនិងការធ្វើការងារដែលផ្ទេរអោយដោយរដ្ឋាភិបាល។

នៅក្នុងខែសីហា ឆ្នាំ ២០០២ ទីប្រឹក្សាពិគ្រោះយោបល់មកពី Padrigu បានរៀបចំសម្រង់ឯកសារស្តីពីបញ្ហាវិមជ្ឈការ សំរាប់រៀបចំក្របខ័ណ្ឌនៃការស្រាវជ្រាវ នៃកម្មវិធីស្រាវជ្រាវលើគោលនយោបាយស្តីពីវិមជ្ឈការ[៣] របស់ CDRI ។ លទ្ធផលរកឃើញសំខាន់ៗនៃរបាយការណ៍នេះផ្តល់នូវចំណុចយោង យ៉ាងមានប្រយោជន៍ សំរាប់បញ្ហានៃការស្រាវជ្រាវដែលត្រូវបានលើកឡើងនៅក្នុងការសិក្សានេះ ។

ការពិនិត្យមើលឯកសារឡើងវិញដោយ Padrigu បានបញ្ជាក់ទៀតថាវិមជ្ឈការតែឯកឯងមិនអាចនាំទៅរកប្រជាធិបតេយ្យ និងការកាត់បន្ថយភាពក្រីក្រនៅតាមមូលដ្ឋានបាននោះទេ ។ មានន័យថា នយោបាយនឹងមិនមានការផ្លាស់ប្តូរ អភិបាលកិច្ចល្អនឹងមិនកើតមាន ហើយភាពក្រីក្រនឹងមិនត្រូវបានកាត់បន្ថយជាស្វ័យប្រវត្តិដោយសារតែវិមជ្ឈការនោះទេ ។ ឆន្ទៈនយោបាយរបស់រដ្ឋាភិបាលនៅក្នុងការអនុវត្តន៍ និងតាមដានការកែទំរង់គឺមានសារៈសំខាន់ ដូចសមត្ថភាពផ្នែកស្ថាប័ននៅតាមមូលដ្ឋានក្នុងការបំពេញការងារអោយបានត្រឹមត្រូវ ។ ការយល់ឃើញទាំងនេះ ទាក់ទងនឹងប្រទេសកម្ពុជាសំរាប់ប្រជាធិបតេយ្យ និងការកាត់បន្ថយភាពក្រីក្រនៅតាមមូលដ្ឋាន ដូចដែលបានលើកឡើងនៅក្នុងទិសដៅនៃការកែទំរង់ ។ ការពិនិត្យឡើងវិញលើផ្នែកខ្លះដោយ Padrigu លើកឡើងពីការសិក្សានៅតាមប្រទេសអាស៊ីដទៃទៀត ដែលលើកឡើងពីកង្វល់ស្តីពីឯករាជ្យភាព

---

[៣] Joakim Ojendal, Robin Biddulph, Pia Wallgren, and Kim Sedara, Understanding Decentralization in Cambodia: A Research Framework to Support the Process of Devolution and Deconcentration in Cambodia, (Goteborg/Phnom Penh:Padrigu Consultants, August 2002).

និង ភាពត្រឹមត្រូវនៃស្ថាប័នវិមជ្ឈការដូចជា ក្រុមប្រឹក្សាឃុំ/សង្កាត់ទាក់ទងនឹងមន្ត្រីជាន់ខ្ពស់នៃរដ្ឋាភិបាល ហើយនិង គណបក្សនយោបាយដែលមានបង្កប់អត្ថប្រយោជន៍ផ្ទាល់ខ្លួន ។ មានសំណួរមួយចំនួនលេចចេញឡើង ។ តើសមាជិកក្រុមប្រឹក្សាឃុំ/សង្កាត់ ដែលមិនសូវមានការសិក្សាអប់រំច្រើនអាចបំពេញមុខងាររបស់គេបានល្អដែរឬទេ ? តើសមាជិកក្រុមប្រឹក្សាឃុំ/សង្កាត់ ទទួលបាននូវការគាំទ្រសមស្របពីថ្នាក់លើដែរឬទេ ? តើអ្នកមានឥទ្ធិពលនៅតាមមូលដ្ឋាន នៅក្នុងស្ថានភាពដូចសព្វថ្ងៃ គៀបសង្កត់លើអភិបាលកិច្ចមូលដ្ឋានឬទេ? នៅក្រោមលក្ខខ័ណ្ឌបែបនេះ តើសង្គមស៊ីវិលមានសិទ្ធិនៅក្នុងការបញ្ចេញមតិយោបល់ ជាមួយនឹងរដ្ឋអំណាចមូលដ្ឋានទេ? ឯកសារបង្ហាញថា ការកែទំរង់ វិមជ្ឈការធ្វើទៅបានល្អបំផុត នៅពេលដែលសង្គមស៊ីវិលមួយដែលរឹងមាំទាមទារអោយមានអភិបាលកិច្ចល្អ និងការទទួលខុសត្រូវពីរដ្ឋអំណាចមូលដ្ឋាន ។

## វិធីសាស្ត្រនៃការស្រាវជ្រាវ

ការសិក្សានេះត្រូវបានរៀបចំឡើងជាសកម្មភាពស្រាវជ្រាវពិសេស សំរាប់សិក្ខាកាមកន្លងមកនៅក្នុងវគ្គបណ្តុះបណ្តាលរបស់ ADI ។ ទិសដៅចំបងនៃសកម្មភាពនេះ គឺកសាងសមត្ថភាពរបស់អតីតសិក្ខាកាមក្នុងការស្រាវជ្រាវ ដោយផ្តោតលើការស្រាវជ្រាវបែបគុណភាព ។ ការស្រាវជ្រាវនេះ មានការចូលរួមពីអ្នកគ្រប់គ្រងអង្គការមិនមែនរដ្ឋាភិបាលចំនួន២១នាក់ (ប្រុស១០ ស្រី ១១) មកពីអង្គការចំនួន១៥ (សូមមើលឧបសម្ព័ន្ធទី៦) ។ សិក្ខាសាលា ស្តីពីការណែនាំមួយដែលត្រូវបានប្រារព្ធឡើងពីថ្ងៃទី ១២ ដល់ ១៥ ខែ សីហា ឆ្នាំ ២០០៣ នៅភ្នំពេញ ដោយបានពិភាក្សាទៅលើប្រភេទនៃការស្រាវជ្រាវបែបគុណភាព រៀបចំក្របខ័ណ្ឌស្រាវជ្រាវ រៀបចំគំរោងនៃការស្រាវជ្រាវ វិធីសាស្ត្រក្នុងការប្រមូលទិន្នន័យនិងកត់ត្រា និងវិភាគទិន្នន័យ ។ នៅក្នុងសិក្ខាសាលា ទិសដៅនៃការស្រាវជ្រាវ និងសំណួរគន្លឹះត្រូវបានគេយកមកច្នៃឱ្យចេញជាបញ្ជីសំណួរនាំមុខ សំរាប់ការពិភាក្សាជាក្រុម និងជាបុគ្គល ។ ចំពោះការរៀបចំការងារចុះតាមមូលដ្ឋានវិញ សិក្ខាកាមត្រូវបានបែងចែកជាបួនក្រុមសំរាប់ធ្វើការស្រាវជ្រាវ ។ ក្រុមនិមួយៗដឹកនាំដោយ បុគ្គលិក ADI ម្នាក់ ។

ការស្រាវជ្រាវនៅតាមមូលដ្ឋានផ្តោតទៅលើឃុំចំនួន៥ ដែលទទួលការជួយឧបត្ថម្ភយ៉ាងច្រើនពីទីភ្នាក់ងារខាងក្រៅ ។ ពីថ្ងៃទី ២០ ដល់ ២១ ខែសីហា ឆ្នាំ ២០០៣ ក្រុមរបស់ ADI ដែលមានសមាជិកចំនួន ៥នាក់ បានធ្វើការប្រមូលទិន្នន័យសាកល្បងជាមុននៅក្នុងឃុំក្រាំងលាវ ស្រុកបាទី ខេត្តតាកែវ ។ ឃុំនេះបានទទួលការជួយគាំទ្រពីអង្គការទស្សនៈពិភពលោក ។ ពីថ្ងៃទី ១ ដល់ទី ៦ ខែកញ្ញា ឆ្នាំ ២០០៣ ក្រុមសិក្ខាកាមស្រាវជ្រាវ២ក្រុម ក្នុងចំណោម៤ក្រុម បានចុះស្រាវជ្រាវនៅតាមមូលដ្ឋាននៅក្នុងខេត្តកំពត ។ មួយក្រុមបានចុះទៅឃុំចំប៉ី ក្នុងស្រុកអង្គរជ័យ ដែលទទួលជំនួយពីអង្គការ GTZ ។ ចំណែកក្រុមមួយទៀតបានចុះទៅឃុំច្រេស ក្នុងស្រុកជុំគិរី ដែលទទួលបានជំនួយពីអង្គការ ស៊ីដសេ ។ ពីថ្ងៃទី ៨ ដល់ថ្ងៃទី ១៣ ខែកញ្ញា ឆ្នាំ ២០០៣ ។ ក្រុមសិក្ខាកាម

ស្រាវជ្រាវចំនួន២ក្រុមទៀត បានចុះទៅខេត្តពោធិសាត់ ។ មួយក្រុមបានចុះទៅឃុំផ្ទះរុងនៅក្នុងស្រុកក្រវ៉ាញ ដែលបានទទួលជំនួយពី PLG ។ ក្រុមមួយទៀតបានចុះទៅឃុំមេទឹក នៅក្នុងស្រុកបាកាន ដែលទទួលជំនួយពីអង្គការ Concern Worldwide ។ សកម្មភាពការងារនៅតាមមូលដ្ឋាននៅក្នុងតំបន់ទាំង៥ រួមមានការសំភាសន៍ជាបុគ្គល និងជាក្រុម ជាមួយនឹងសមាជិកក្រុមប្រឹក្សាឃុំ ការសំភាសន៍របស់ក្រុម ជាមួយនឹងមេដឹកនាំសង្គមស៊ីវិល ការសំភាសន៍ក្រៅផ្លូវការរបស់ក្រុម ជាមួយនឹងអ្នករស់នៅនៅក្នុងឃុំ សំភាសន៍ជាមួយនឹងមន្ត្រីថ្នាក់ស្រុក សំភាសន៍ជាមួយនឹងក្រុមសំរបសំរួលកម្មវិធីសីលានៅថ្នាក់ស្រុក និងសំភាសន៍ជាមួយនឹងបុគ្គលិកទីភ្នាក់ងារដែលផ្តល់ជំនួយដែលមកពីអង្គការ World Vision, GTZ, CIDSE, PLG ឬ Concern ។

សិក្ខាសាលាចុងក្រោយបង្អស់ ចូលរួមដោយសិក្ខាកាមទាំងអស់ត្រូវបានរៀបចំឡើងនៅភ្នំពេញពីថ្ងៃទី ២១ ដល់ ២៤ ខែតុលា ឆ្នាំ២០០៣ ។ នៅក្នុងពេលនេះ ក្រុមស្រាវជ្រាវបានកំណត់កូដ និងវិភាគលើទិន្នន័យបែបគុណភាពដែលទទួលបានពីករណីសិក្សានៅក្នុងឃុំនិមួយៗ ។ ដូច្នេះ ក្រុមបានរៀបចំពង្រាងករណីសិក្សា ហើយលើកយកមកបង្ហាញដើម្បីផ្តល់យោបល់នៅក្នុងក្រុមធំ ។ ការវិភាគបែបប្រៀបធៀបលើលទ្ធផលរកឃើញ ហើយនិងការវិភាគលើបទពិសោធន៍នៃឃុំទាំង៥ត្រូវបានធ្វើឡើងនៅមុនពេលចប់សិក្ខាសាលា ។ បន្ទាប់មក ក្រុម ADI បានរៀបចំការសំភាសន៍ទាក់ទងនឹងការសិក្សាស្រាវជ្រាវនៅតាមមូលដ្ឋាន ការសរសេរករណីសិក្សា និងការវិភាគដោយបញ្ចូលវាទៅជារបាយការណ៍ចុងក្រោយនេះ ។

## ទំហំ និងដែនកំណត់

ដោយសារក្រុមប្រឹក្សាឃុំ/សង្កាត់នៅក្នុងប្រទេសកម្ពុជាចំនួន ១៦២១ ត្រូវបានបង្កើតឡើង ហើយការសិក្សាស្រាវជ្រាវពីបទពិសោធន៍ក្រុមប្រឹក្សាឃុំនៅក្នុងឃុំចំនួនប្រាំ មិនអាចត្រូវបានចាត់ទុកថាគ្រប់ជ្រុងជ្រោយនោះទេ ។ តែការស្រាវជ្រាវនេះមានបំណងធ្វើអោយមានការពិភាក្សាលើដំណើរការ ក្នុងកម្មវិធីកែទំរង់បែបវិមជ្ឈការ ដោយផ្អែកលើការស្រាវជ្រាវនៅតាមមូលដ្ឋានឱ្យស៊ីជំរៅ មានដែនកំណត់ ដែលត្រូវបានធ្វើឡើងនៅរយៈពេល២ឆ្នាំបន្ទាប់ពីការបោះឆ្នោតឃុំ/សង្កាត់ ។ នៅក្នុងប្រការនេះ អ្នកអានរបាយការណ៍នេះត្រូវមើលការងារដ៏មានតំលៃស្តីពីការកែទំរង់បែបវិមជ្ឈការដែលត្រូវបានធ្វើឡើងដោយការសិក្សា[៤] ដទៃទៀតនៅពេលថ្មីៗនេះ ។ តាមការពិនិត្យលើលទ្ធផលរកឃើញនៃការស្រាវជ្រាវនេះ ដោយប្រៀបធៀបនឹងការស្រាវជ្រាវជាក់ស្តែងផ្សេងទៀត គេសង្ឃឹមថាបញ្ហាទាំងឡាយនៅក្នុងដំណើរការវិមជ្ឈការនៅក្នុងប្រទេសកម្ពុជា នឹងមានភាពកាន់តែច្បាស់ហើយ ជាកម្មវត្ថុមួយដើម្បីធ្វើសកម្មភាព ដោយអ្នកពាក់ព័ន្ធទាំងឡាយជាច្រើន ។

[៤] ឧទាហរណ៍ សូមមើល Caroline Rusten, Kim Sedara, Eng Netra and Pak Kinchoen, *The Challenges of the Decentralization Design in Cambodia*, (Phnom Penh: Cambodia Development Resource Institute, 204); Christina Mansfield and Kurt MacLeod, *Commune Council & Civil Society: Promoting Decentralization Through Partnership*, (Phnom Penh: PACT, January 2004); and Robin Biddulph, *PAT Empowerment Study – Final Report*, (Phnom Penh:DFID/Sida & UNDP, November 2003).

# លទ្ធផលរកឃើញ និងការវិភាគ

## វដ្តបាលឃុំសង្កាត់

*ការផ្លាស់ប្តូរ និងការមានជាបន្ត*

នៅក្នុងឃុំទាំង៥ដែលបានសិក្សា មានការយល់ស្របគ្នាជាទូទៅថាមានការប្រែប្រួលនៅក្នុងរដ្ឋបាលឃុំ ចាប់តាំងពីការបោះឆ្នោតឃុំនៅក្នុងខែកុម្ភៈឆ្នាំ២០០២ ។ ការប្រែប្រួលនេះទាក់ទងសំខាន់លើសមាសភាព និងការអនុវត្តន៍របស់មន្ត្រីឃុំ ។ នៅមុនពេលបង្កើតក្រុមប្រឹក្សាឃុំ មេឃុំដែលត្រូវបានគេតែងតាំងគ្រប់គ្រងឃុំជាតំណាងនៃគណបក្សដែលមានសំលេងភាគច្រើន ។ បច្ចុប្បន្ន ក្រុមប្រឹក្សាឃុំដែលជាប់ឆ្នោតដែលមានសមាជិកពី៥ទៅ១១នាក់ ហើយដែលច្រើនតែតំណាងអោយគណបក្សលើសពីមួយជាអ្នកគ្រប់គ្រងឃុំ ។ ពីមុន មេឃុំធ្វើការប្រជុំតិចតួច ហើយសំរេចកិច្ចការទៅតាមការបង្គាប់បញ្ជារបស់រដ្ឋាភិបាលថ្នាក់កណ្តាល ។ បច្ចុប្បន្ន ក្រុមប្រឹក្សាឃុំធ្វើការប្រជុំទៀងទាត់ ហើយសំរេចកិច្ចការដោយមានការពិគ្រោះយោបល់ជាមួយគ្នាទៅវិញទៅមក ។ ពីមុន មន្ត្រីឃុំគ្រាន់តែជាអ្នកផ្សព្វផ្សាយ អនុក្រឹត្យដែលចេញឡើងដោយអ្នកតាក់តែងច្បាប់ថ្នាក់ជាតិ ។ បច្ចុប្បន្ន ក្រុមប្រឹក្សាឃុំបានចេញបទបញ្ជា ឬដីការសំរាប់ឃុំរបស់គេផ្ទាល់ ដែលបទបញ្ជា ឬដីការខ្លះសំរាប់ដោះស្រាយបញ្ហារបស់ឃុំ ។ ពីមុន តួនាទីនិង ការទទួលខុសត្រូវរបស់រដ្ឋអំណាចឃុំមិនមានភាពច្បាស់លាស់ទេ ។ បច្ចុប្បន្ន តួនាទី និងការទទួលខុសត្រូវរបស់សមាជិកក្រុមប្រឹក្សាឃុំត្រូវបានកំណត់ច្បាស់លាស់ ហើយសមាជិកនិមួយៗមានភារកិច្ចដោយឡែកពីគ្នា។ ពីមុន គេគិតថាមានការបណ្តុះបណ្តាលតិចតួចដល់មន្ត្រីឃុំ ។ បច្ចុប្បន្ន សមាជិកក្រុមប្រឹក្សាឃុំ បានទទួលការបណ្តុះបណ្តាលដើម្បីធ្វើការងាររបស់គេដោយការពេញចិត្ត ។ ពីមុន រដ្ឋអំណាចឃុំ មានការទាក់ទងតិចតួចជាមួយនឹងអង្គការសមាគមន៍នៅក្នុងភូមិ ។ បច្ចុប្បន្ន ក្រុមប្រឹក្សាឃុំធ្វើការជិតស្និទ្ធជាមួយនឹងក្រុមទាំងនេះ ។

ទោះបីជាមានការប្រសើរឡើងយ៉ាងនេះក្តី ក៏ការផ្លាស់ប្តូរនៅក្នុងរដ្ឋបាលឃុំមិនសាយភាយទៅគ្រប់ទីកន្លែងនោះទេ ។ សមាជិកក្រុមប្រឹក្សាឃុំនៅពឹងពាក់ច្រើន លើការណែនាំរបស់ថ្នាក់លើទាក់ទងនឹងអ្វីដែលគេគួរធ្វើ ហើយមេឃុំក៏នៅមានឥទ្ធិពលច្រើនលើការសំរេចចិត្តជារួម ។ ជាញឹកញាប់ សមាជិកដែលមកពីគណបក្សដែលមានសំលេងភាគតិច មិនអាចបញ្ចេញទស្សនៈរបស់គេបានគ្រប់គ្រាន់ទេ ហើយការសំរេចចិត្តរបស់ក្រុមប្រឹក្សាឃុំគឺស្របទៅនឹងគោលជំហររបស់គណបក្សដែលមានសំលេងភាគច្រើន ។ មេឃុំភាគច្រើនជាមនុស្សដដែល ហើយ

មិនបានបោះបង់ចោលនូវទំលាប់ប្រើអំណាចរបស់គេទេ ។ ការចូលរួមរបស់នារីជាសមាជិកឃុំគឺស្ទើរតែមិនមាន[៥] ។ ជាទូទៅ ក្រុមប្រឹក្សាឃុំខ្វះការទទួលខុសត្រូវចំពោះអ្នកបោះឆ្នោតអោយខ្លួន ហើយកំរប្រជុំ ឬពិគ្រោះជាមួយនឹងពួកគេណាស់ ពិតមែនហើយថាសមាជិកក្រុមប្រឹក្សាឃុំអាចដាក់ចេញបទបញ្ជារបស់ឃុំ តែគេមិនមានអំណាចនៅក្នុងការធ្វើអោយមានការអនុវត្តន៍បានច្រើនលើបទបញ្ជាទាំងនោះទេ ។ សមាជិកក្រុមប្រឹក្សាឃុំជាច្រើនមិនសូវមានការសិក្សាអប់រំបានច្រើនទេ ហើយបានថ្លែងថាគេត្រូវការការបណ្តុះបណ្តាលថែមទៀត ដើម្បីបំពេញតួនាទីរបស់គេអោយបានសមស្រប ។ ជាទូទៅ ទំនាក់ទំនងជាមួយនឹងអង្គការសមាគមន៍ នៅក្នុងភូមិត្រូវបានកំណត់ទៅតាមលក្ខខ័ណ្ឌទាមទារនៃច្បាប់ ជាជាងកំណត់ដោយឱកាសប្រកបដោយការច្នៃប្រឌិត ។

ដូចគ្នានេះដែរ ការយល់ឃើញអំពីការអនុវត្តន៏ការងារមានភាពខុសគ្នាច្រើននៅក្នុងចំណោមអ្នកដែលបានសំភាសន៏ ។ ជាទូទៅ ក្រុមប្រឹក្សាឃុំដែលយើងបានសិក្សា គិតថាគេបានធ្វើការបានល្អចាប់តាំងពីពេលចូលកាន់តួនាទីមក ។ តំណាងរបស់សង្គមស៊ីវិល ក៏មានការរីករាយនឹងដំណើរការទៅមុខគន្លងមកនោះដែរ ដោយផ្អែកទៅលើការវាយតំលៃរបស់គេ ។ បើប្រៀបធៀប ជាទូទៅអ្នកភូមិមិនមានការពេញចិត្តនឹងការងាររបស់ក្រុមប្រឹក្សាឃុំទេ ។ តាមទស្សនៈរបស់ប្រជាជនក្នុងភូមិ សមាជិកក្រុមប្រឹក្សាឃុំគឺច្រើនជាអ្នកប្រកាន់គណបក្សនយោបាយដែលមិននាំឱ្យពួកគេចូលរួមនៅក្នុងការងារ ឬក៏មិនរាយការណ៍ប្រាប់គេអោយបានទៀងទាត់នោះទេ ។

*ការប្រៀបធៀបលក្ខណៈនៃការផ្លាស់ប្តូរ*

ការសង្កេតឃើញខាងលើនេះ គឺជាលក្ខណៈជាទូទៅនៃការផ្លាស់ប្តូរដែលមានលក្ខណៈលេចធ្លោពីឃុំនីមួយៗ ក្នុងចំណោមឃុំទាំងប្រាំដែលបានសិក្សា ។

នៅក្នុងឃុំក្រាំលាវ (ខេត្តតាកែវ) ប្រធានក្រុមប្រឹក្សាឃុំដែលជាប់ឆ្នោត គឺជាអតីតមេឃុំចាស់ ។ ក្នុងនាមជាអ្នកដឹកនាំដ៏ខ្លាំងម្នាក់ មេឃុំនោះអាចទាញយកប្រយោជន៍ពីដំណើរការវិមជ្ឈការដើម្បីបង្កើនអំណាចរបស់គាត់ ហើយគៀងគរការជួយពីអង្គការទីភ្នាក់ងារអភិវឌ្ឍន៍ពីខាងក្រៅ ។ នៅក្រាំងលាវ ក្រុមប្រឹក្សាឃុំធ្វើការប្រជុំទៀងទាត់ប្រចាំខែទៅតាមច្បាប់កំណត់ ហើយខិតខំធ្វើអោយមានការព្រមព្រៀងគ្នាជារួម ព្រមទាំងដោះស្រាយបញ្ហា

---

[៥] មានតែម្នាក់ជានារី(២.៤៥%) ក្នុងចំណោមសមាជិកក្រុមប្រឹក្សាឃុំចំនួន៤០នាក់នៅក្នុងឃុំទាំង៥ដែលបានសិក្សា ។ នៅទូទាំងប្រទេសមាន ៩៨៣នាក់ (៨.៧%) នៃចំនួនសមាជិកក្រុមប្រឹក្សាឃុំសរុប ចំនួន១១ ២៦១ នាក់នៅក្នុងឃុំចំនួន១ ៦២១ គឺជានារី (សូមមើល Mansfield and MacLeod, *Commune Council and Civil Society, 5-6)*. Rusten et al, *The Challenges of Decentralization Design in Cambodia,* បានសង្កេតឃើញថានៅតាមកន្លែងដែលមានការចូលរួមរបស់នារីជាសមាជិកក្រុមប្រឹក្សា លទ្ធភាពរបស់គេនៅក្នុងការសំរេចចិត្ត គឺមានតិចតួចណាស់ ។

អោយបានឆាប់រហ័ស ។ ដោយសារនៅក្នុងចំណោមសមាជិកក្រុមប្រឹក្សាឃុំទាំង៩នាក់នោះ មានតែម្នាក់ទេដែលមិនមែនមកពីគណបក្សប្រជាជន ដូច្នេះមិនមានការប្រជែងគ្នា ច្រើនរវាងគណបក្សនោះទេ ។ ការទាក់ទងដោយផ្ទាល់ជាមួយនឹងរដ្ឋមន្ត្រីដែលមកពីគណបក្សប្រជាជនរឹតតែជួយអោយមានការគាំទ្រទៅទៀត ។ តែមិនមានសមភាពផ្នែកយេនឌ័រទេ ដោយពួកគេនោះសុទ្ធតែជាបុរស ។ តំណាងរបស់សង្គមស៊ីវិលបានបង្ហាញអោយឃើញថារដ្ឋអំណាចឃុំមានភាពសកម្មជាងមុន ហើយផ្តល់ការដឹកនាំដល់មនុស្សកាន់តែច្រើននៅក្នុងភូមិចំនួន២៣នៅក្នុងឃុំនោះ ។ ប្រជាជនធម្មតាមិនបានចូលរួម ឬមិនត្រូវបានគេប្រាប់អំពីបញ្ហាទាក់ទងនឹងអភិបាលកិច្ចមូលដ្ឋានទេ តែតាមជាក់ស្តែង មេឃុំ និងសមាជិកក្រុមប្រឹក្សាឃុំដទៃទៀតចូលរួមនៅ ក្នុងពិធីមង្គលការនិងបុណ្យខ្មោចនៅក្នុងភូមិ ធ្វើអោយប្រជាជនមានការគោរពដល់ពួកគេ ។ កត្តារួមផ្សំគ្នានៃការខិតខំធ្វើការងារ ការមានទំនាក់ទំនងខ្លាំងទៅនឹងគណបក្សនយោបាយ ហើយនិងភាពជិតស្និទ្ធដែលមានជា ទំលាប់មកជាមួយនឹងអ្នកភូមិបានធ្វើអោយ ក្រុមប្រឹក្សាឃុំក្រាំងលាវសំរេចបានជោគជ័យពីដើមទីនៅក្នុងការគ្រប់គ្រងរដ្ឋបាលឃុំ ប្រកបដោយប្រសិទ្ធិភាព ។

នៅក្នុងឃុំចំប៉ី (ខេត្តកំពត) ប្រធានក្រុមប្រឹក្សាឃុំដែលជាប់ឆ្នោតក៏ធ្វើជាប្រធានឃុំពីមុនមកដែរ គឺនៅខាងគណបក្សប្រជាជន ។ ក្រុមប្រឹក្សានេះមានសមាជិកចំនួនបួននាក់មកពីគណបក្សប្រជាជន ម្នាក់មកពីគណបក្សហ៊្វុនស៊ិនប៉ិច និង ម្នាក់ទៀតមកពីគណបក្សសមរង្ស៊ី ។ សមាជិកក្រុមប្រឹក្សាទាំងអស់សុទ្ធតែជាបុរស ។ ទោះបីជាមាននិន្នាការនយោបាយខុសគ្នាក្តី គេបានជំនះបានលើនិន្នាការទាំងនេះ ហើយធ្វើការរួមគ្នា ។ ការសំរេចបានដ៏ធំមួយនោះគឺការអនុម័តលើបទបញ្ជារបស់ឃុំទាក់ទងនឹងសន្តិសុខនៅក្នុងឃុំ ហើយនិងការគ្រប់គ្រងធនធាន។ សមត្ថភាពរបស់ក្រុមប្រឹក្សាឃុំ នៅក្នុងការទំនាក់ទំនងជាមួយនឹងអ្នកភូមិ ដើម្បីផ្តល់ពត៌មានអំពីអ្វីដែលគេបានធ្វើនោះ គឺមិនសូវមានប្រសិទ្ធិភាពប៉ុន្មានទេ ។ ម៉្យាងដោយសារការខ្វះការយល់ដឹងអំពីតួនាទីការក្នុងការបង្កើនតម្លាភាព និង ភាពបើកចំហកាន់តែច្រើន ។ ម៉្យាងទៀតគឺដោយសារទំលាប់អនុវត្តន៍ការងាររបស់គេតាមរយៈប្រធានភូមិនិង គណៈកម្មាធិការអភិវឌ្ឍន៍ភូមិ (VDCs) ។ ក្រុមប្រឹក្សាឃុំត្រូវការបង្កើនការយល់ដឹងនិងសមត្ថភាព ក្នុងការអនុវត្តន៍ការងាររបស់ខ្លួន ហើយត្រូវទាក់ទងដោយផ្ទាល់ជាមួយនឹងប្រជាជនដែលបោះឆ្នោតអោយគេនៅក្នុងភូមិទាំង១១ នៅក្នុងឃុំ ។

នៅក្នុងឃុំច្រេស (ខេត្តកំពត) ក្រុមប្រឹក្សាឃុំរួមមានតំណាងមកពីគណបក្សខុស១គ្នា គឺមកពីគណបក្សប្រជាជនចំនួនបីរូប គណបក្សហ្វុនស៊ិនប៉ិចមួយរូប និងគណបក្សសមរង្ស៊ីមួយមួយរូប ។ តែទោះបីយ៉ាងណាក៏ដោយមេឃុំថ្មីដែលមកពីគណបក្សប្រជាជន ត្រូវបានជាប់ឆ្នោតចូលជំនួសមេឃុំចាស់ហើយប្រជាជននៅក្នុងឃុំច្រេសមិនចូលចិត្ត បានសេចក្តីថាគាត់នៅតែស្ថិតនៅក្នុងសមាសភាពក្រុមប្រឹក្សាឃុំដដែល ។ សមាជិកក្រុមប្រឹក្សាឃុំទាំង៥គឺជាបុរស ។ ក្រុមប្រឹក្សាឃុំច្រេសមានការប្រជុំទៀងទាត់ ។ ការងារនេះ ធ្វើអោយពួកគេមានទំនាក់ទំនងល្អ

នៅក្នុងចំណោមពួកគេ ហើយអាចដោះស្រាយបញ្ហានៅក្នុងការគ្រប់គ្រង ។ តែក្រុមប្រឹក្សាឃុំមិនសូវប៉ុនរ អោយមានការចូលរួមពីអ្នកភូមិនៅក្នុងការពិភាក្សាអំពីអភិបាលកិច្ចមូលដ្ឋាន មិនសូវរាយការណ៍អោយប្រជាជន ដឹងពីការងាររបស់គេ ឬផ្សព្វផ្សាយសារាចរពីថ្នាក់លើទេ។ ជាទូទៅ ក្រុមប្រឹក្សាឃុំដើរតួជារដ្ឋអំណាចឃុំ ដែលនៅក្នុងពេលអតីតកាល បានបំពេញមុខងារសំខាន់ចាំបាច់ ដូចជាការធ្វើជាអាជ្ញាកណ្តាលនៅក្នុងជំលោះ ហើយរក្សាអោយមានសន្តិសុខ នៅក្នុងភូមិទាំងបួនរបស់ឃុំ ។ ដូចគ្នានេះដែរ ក្រុមប្រឹក្សាមានការទទួល ខុសត្រូវចំពោះថ្នាក់ដឹកនាំរដ្ឋាភិបាល ជាជាងចំពោះប្រជាជនដែលជាអ្នកបោះឆ្នោតអោយគេ ។ ពិតមែនតែដំណើរ ការបោះឆ្នោតបានបើកឱកាសអោយមានការគ្រប់គ្រងជាលក្ខណៈពហុបក្សក្តី តែទំលាប់គ្រប់គ្រងរដ្ឋបាលរបស់ក្រុម ប្រឹក្សាឃុំច្រេសស្តែងអោយ ឃើញពីនិន្នាការបន្តរបៀបចាស់ជាជាងការផ្លាស់ប្តូរ ។

នៅក្នុងឃុំផ្ទះរុង (ខេត្តពោធិសាត់) ដូចគ្នានេះដែរ ក្រុមប្រឹក្សាឃុំមានតំណាងមកពីគណបក្សនយោបាយ ផ្សេងៗ: ៨នាក់មកពីគណបក្សប្រជាជន ២នាក់មកពីគណបក្សហ៊្វុនស៊ិនប៊ិច និង១នាក់មកពីគណបក្សសមរង្ស៊ី ។ មេឃុំគឺជាសមាជិកគណបក្សប្រជាជន មានតែសមាជិកក្រុមប្រឹក្សាម្នាក់ប៉ុណ្ណោះដែលជានារី ។ តាមរយៈការ ធ្វើការនៅក្នុងក្រុមដែលមាននិន្នាការនយោបាយខុសគ្នា សមាជិកក្រុមប្រឹក្សាឃុំបានចរចារដោយផ្អែកលើតួនាទី ជាមួយគ្នាទៅវិញទៅមកហើយសំរេចចិត្តរួមគ្នា ។ ទោះបីជា មេឃុំមានឥទ្ធិពលច្រើនក្តី ក៏សេចក្តីត្រូវការរបស់ ភូមិគាត់មិនត្រូវបានទទួលអាទិភាពលើសពីភូមិដទៃឡើយ ។ ក្រុមប្រឹក្សាឃុំផ្តល់ពត៌មាន និងសេចក្តីថ្លែងការ តាមរយៈប្រធានភូមិ និងVDC ប៉ុន្តែរបាយការណ៍ទាំងនេះមិនមែនចេះតែបានដល់អ្នកភូមិគ្រប់ស្រទាប់នោះទេ ។ ហេតុនេះ អ្នកភូមិជាច្រើននៅតែមិនដឹងពីការសំរេចចិត្តរបស់ក្រុមប្រឹក្សាឃុំ ។ មេភូមិ និងនគរបាលដែលត្រូវបាន ជ្រើសតាំងឡើងនៅក្នុងរដ្ឋបាលមុន ច្រើនតែនៅជាប់ជាមួយនឹងអ្នកភូមិជាងមន្ត្រីឃុំដែលបានជាប់ឆ្នោតថ្មី ។ ក្រុមប្រឹក្សាឃុំផ្ទះរុង បានជំនះលើឧបសគ្គដែលបន្សល់ពីរដ្ឋអំណាចឃុំកន្លងមក តែគេនៅមិនទាន់កសាងបាន ទំនាក់ទំនងរឹងមាំជាមួយនឹងអ្នកស្រុកនៅក្នុងភូមិទាំង១៣របស់ឃុំដដែល ។

នៅក្នុងឃុំមេទឹក (ក្នុងខេត្តពោធិសាត់) ក្រុមប្រឹក្សាឃុំមានសមាជិកដែលមកពីគណបក្សនយោបាយ ផ្សេងៗ គឺមាន៦នាក់មកពីគណបក្សប្រជាជន ២នាក់មកពីគណបក្សហ៊្វុនស៊ិនប៊ិច និង១នាក់មកពីគណបក្ស សមរង្ស៊ី ។ មេឃុំមកពីគណបក្សប្រជាជនហើយសមាជិកទាំងអស់នៃក្រុមប្រឹក្សាឃុំគឺជាបុរស។ ការបោះឆ្នោត ក្រុមប្រឹក្សាឃុំបានធ្វើអោយចំនួនមន្ត្រីរបស់ឃុំកើន ហើយមានការផ្ទេរការងារទទួលខុសត្រូវច្រើន ។ តួនាទីនិងការ ទទួលខុសត្រូវបានកំណត់ច្បាស់ ហើយការប្រជុំបានរៀបចំទៀងទាត់ ។ ជាលទ្ធផលនៃការផ្លាស់ប្តូរទាំងនេះ ការ ងារត្រូវបានសំរេច និងចែករំលែកបានឆាប់រហ័សជាងកាលពីរដ្ឋបាលមុន ។ ទោះបីជាមានជោគជ័យយ៉ាងនេះក្តី ការប្រកាន់គណបក្ស នៅតែធ្វើអោយរាំងស្ទះដល់ប្រសិទ្ធិភាពរបស់ក្រុមប្រឹក្សាឃុំ ដោយសមាជិកគិតគូរពី ប្រយោជន៍របស់បក្សច្រើនជាងកង្វល់របស់រដ្ឋអំណាចមូលដ្ឋាន ។ ចំណុចគួរអោយកត់សំគាល់មួយគឺ ក្រុមប្រឹក្សាឃុំ

បានចេញបញ្ញាមិនអោយមានការឆក់ត្រី និងលេងល្បែងស៊ីសងនៅក្នុងឃុំ តែមានការពិបាកនឹងធ្វើអោយគេគោរព តាមបទបញ្ញានេះបើសិនជាមិនមានការគាំទ្រពីមន្ត្រីធំៗ ។ ភាពមិនសូវមានការសិក្សាអប់រំឱ្យបានត្រឹមត្រូវ ធ្វើអោយសមាជិកក្រុមប្រឹក្សាឃុំមានការពិបាកនៅក្នុងការធ្វើការទៅតាមការទៅតាមតួនាទីរបស់គេ ទោះបីជាគេបានទទួលការបណ្តុះបណ្តាលជាច្រើនពីអង្គការមិនមែនរដ្ឋាភិបាល និងកម្មវិធីសីលារបស់រដ្ឋាភិបាលក្តី ។ ដោយសារសមាជិកក្រុមប្រឹក្សាមិនសូវចុះទៅតាមភូមិទាំង១៥នៅក្នុងឃុំ ហើយធ្វើរបាយការណ៍មិនសូវបានញឹកញាប់តាមរយៈប្រធានភូមិនិង VDC ដូច្នេះគេមិនសូវមានទំនាក់ទំនងរឹងមាំល្អជាមួយនឹងប្រជាជនដែលគេត្រូវគ្រប់គ្រងនោះឡើយ ។

## ការរៀបចំ និងអនុវត្តន៍ផែនការ

*ការចូលរួមនៅក្នុងការអភិវឌ្ឍន៍មូលដ្ឋាន*

ជាផ្នែកមួយនៃកំណែទំរង់បែបវិមជ្ឈការ ក្រុមប្រឹក្សាឃុំត្រូវបានបង្កើតឡើងដើម្បីឱ្យមានការចូលរួមនៅក្នុងការអភិវឌ្ឍន៍មូលដ្ឋាន ។ ការបង្កើតឱ្យមានផែនការ និងការអនុវត្តន៍ផែនការអភិវឌ្ឍន៍នៅថ្នាក់ឃុំ សឱ្យឃើញថាមានការផ្លាស់ប្តូរពីការគ្រប់គ្រងដោយរដ្ឋាភិបាលថ្នាក់ជាតិ ហើយគិតថានឹងមានផលវិបាកយូរអង្វែង ពិសេសសំរាប់អ្នកដែលចូលរួមនៅក្នុងការអភិវឌ្ឍន៍ជនបទ ។ ដោយទាញយកបទពិសោធន៍រយៈពេល៥ឆ្នាំ (១៩៩៦-២០០១) របស់ UNDP/CARERE ជាមួយនឹងកម្មវិធីសីលារបស់រដ្ឋាភិបាល ច្បាប់ត្រូវបានអនុម័ត ហើយប្រព័ន្ធនិងនិតិវិធីត្រូវបានកំណត់ឡើង ដើម្បីជួយសំរួលដល់ការចូលរួមរបស់ក្រុមប្រឹក្សាឃុំ នៅក្នុងការអភិវឌ្ឍន៍មូលដ្ឋាន។ ដូចដែលត្រូវបានគ្រោងរៀបចំឡើង ដំណើរការរួមមានការតាក់តែងនិងពង្រឹងផែនការ៥ឆ្នាំ ដែលត្រូវបានធ្វើឡើងជាមួយនឹងការចូលរួមរបស់អ្នកភូមិ[៦] ។ ដូច្នេះ បន្ទាប់មកត្រូវមានការបង្កើតគណៈកម្មាធិការផែនការ និងគណៈ-កម្មាធិការថវិកា និងគណៈកម្មាធិការផ្គត់ផ្គង់ ដែលរួមមានរដ្ឋអំណាចមូលដ្ឋាន និងតំណាងរបស់សង្គមស៊ីវិលដើម្បីជួយនិងផ្តល់យោបល់ប្រឹក្សាដល់សមាជិកក្រុមប្រឹក្សាឃុំ។ ប្រការសំខាន់គឺកំណែទំរង់បានបង្កើតអោយមានថវិកាឃុំ ដែលបែងចែករៀងរាល់ឆ្នាំសំរាប់គំរោងអាទិភាពនានា នៅក្នុងផែនការ[៧] ។ គោលការណ៍ណែនាំត្រូវបាន

---

[៦] Biddhlph, *PAT Empowerment Study* ពិភាក្សាវែងពីបញ្ហានៅក្នុងការចូលរួម ។ ការសិក្សានេះដែលត្រូវបានធ្វើឡើងនៅក្នុងឃុំចំនួន២០ និង សង្កាត់ចំនួន៤ ចែងថា៩០%នៃអ្នកភូមិដែលមានតួនាទីទទួលខុសត្រូវនៅក្នុងសហគមន៍ ដែលត្រូវបានសំភាសន៍ និង៤៩%នៃអ្នកភូមិដែលត្រូវបានជ្រើសឡើងដោយមិនចំពោះ បានប្រាប់ថាគេបានចូលរួមនៅក្នុងដំណើរការជ្រើសរើសគំរោង ។

[៧] យោងទៅតាម Rusten et al, *Challenges of the Decentralization Design in Cambodia (បញ្ហាប្រឈមនៅក្នុងការគ្រោងរៀបចំវិមជ្ឈការនៅក្នុងប្រទេសកម្ពុជា)* ឃុំនីមួយៗកំណត់ត្រូវទទួលបានជាមធ្យមនូវប្រាក់ប្រហែល៥ពាន់ដុល្លាសំរាប់ការអភិវឌ្ឍន៍ និង ៣ ពាន់ដុល្លាសំរាប់រដ្ឋបាល នៅក្នុងឆ្នាំ ២០០៣។ Biddulph, *PAT Empowerment Study* និយាយថា៣៨%នៃអ្នកភូមិដែលមានមុខទទួលខុសត្រូវហើយដែលត្រូវបានសំភាសន៍ជាមួយនឹង ១៧%ទៀតដែលត្រូវបានជ្រើសរើសដោយមិនរើសមុខ ដឹងថាក្រុមប្រឹក្សា មានថវិកាសំរាប់ការអភិវឌ្ឍន៍ដែលខ្លួនអាចទទួលបាន ។

អនុម័តស្តីពីរបៀបធ្វើការដេញថ្លៃកុងត្រា[៨] ។ សិក្ខាសាលា សមាហរណកម្មថ្នាក់ស្រុកត្រូវបានកំណត់ធ្វើរៀងរាល់ឆ្នាំ ដើម្បីសំរបសំរួលការធ្វើផែនការថ្នាក់ឃុំជាមួយនឹងការធ្វើ ផែនការនៅថ្នាក់ខេត្តនិងថ្នាក់ស្រុក និងដើម្បីស្វែងរកថវិកាបន្ថែមពីអង្គការខាងក្រៅ ។ ក្រុមសំរបសំរួលថ្នាក់ស្រុក ត្រូវបានបង្កើតឡើងនៅក្នុងកម្មវិធីសីលា ដើម្បីជួយការងាររបស់សមាជិកក្រុមប្រឹក្សាឃុំ និងដើម្បីធ្វើយ៉ាងណាអោយភារកិច្ចដែលបានធ្វើនោះ សំរេចបានទៅតាមកំរិតបទដ្ឋានកំណត់ ។

ជារួម ក្រុមប្រឹក្សាឃុំទាំងប្រាំដែលបានសិក្សានោះ មានការជឿនលឿនច្រើននៅក្នុងការបំពេញភារកិច្ចរៀបចំផែនការ និងការអនុវត្តន៍ផែនការនៅតាមមូលដ្ឋាន ។ នៅពេលស្រាវជ្រាវ ក្រុមប្រឹក្សាឃុំទាំង៥បានបង្កើតគណៈកម្មាធិការផែនការនិងថវិកា បានរៀបចំធ្វើផែនការនៅក្នុងភូមិ ហើយបានរៀបចំផែនការរយៈពេល៥ឆ្នាំ ។ ក្រុមប្រឹក្សាបានអនុម័តថវិកា និងបានជួលអ្នកម៉ៅការតាមរយៈការដេញថ្លៃដើម្បីអនុវត្តន៍គំរោងផ្នែកហេដ្ឋារចនាសម្ព័ន្ធ ដូចជាផ្លូវថ្នល់ សាលារៀន និងលូទឹកនៅក្នុងភូមិ ដោយមានការរួមវិភាគទានបដិភាគរបស់អ្នកភូមិ ។ គំរោងទាំងនេះផ្តល់ប្រយោជន៍ដល់គ្រួសារអ្នកមានព្រលទាំងគ្រួសារអ្នកក្រីក្រ ។ សមាជិកក្រុមប្រឹក្សាឃុំក៏បានបង្ហាញពីផែនការរបស់គេដល់សិក្ខាសាលាសមាហរណកម្មថ្នាក់ស្រុក ហើយបានទទួលថវិកាបន្ថែមសំរាប់គំរោងពីទីភ្នាក់ងារអភិវឌ្ឍន៍ពីខាងក្រៅផងដែរ ។ បើយោលទៅលើពេលវេលាដែលសមាជិកក្រុមប្រឹក្សាឃុំបានឡើងកាន់តួនាទី និងកំរិតនៃការសិក្សាអប់រំរបស់គេ ការងារនេះសំរេចបានលទ្ធផលគួរអោយកត់សំគាល់ហើយ ។ ពិតមែនហើយមួយផ្នែកធំនៃជោគជ័យរបស់គេ គឺដោយសារគេបានទទួលជំនួយខ្លាំងក្លាពីរដ្ឋាភិបាល និងទីភ្នាក់ងារអភិវឌ្ឍន៍នានា ។

ទោះបីជាក្រុមប្រឹក្សាឃុំទាំង៥បានសំរេចបានជោគជ័យពីដំបូងមកនៅក្នុងការធ្វើផែនការ និងអនុវត្តន៍នៅតាមមូលដ្ឋានក្តី ក៏ដំណើរការមិនទាន់បានរលូននិងឥតខ្ចោះនោះទេ ។ ការចូលរួមរបស់ប្រជាជននៅក្នុងការប្រជុំធ្វើផែនការមិនបានជាប់លាប់ល្អ ហើយពេលខ្លះបានត្រឹមតែសង្កេត[៩] តែប៉ុណ្ណោះ ។ គោលបំណងនៃការប្រជុំជាមួយនឹងអ្នកភូមិច្រើនតែមិនច្បាស់ ។ ការជ្រើសរើសគំរោងសំរាប់យកទៅអនុវត្តន៍គឺច្រើនតែជំរុញដោយអ្នកនៅថ្នាក់លើដែលចង់បានការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ ដែលមិនសុទ្ធតែឆ្លើយតបទៅនឹងសេចក្តីត្រូវការចាំបាច់ជាមូលដ្ឋានរបស់ប្រជាជន ។ មានការពិបាកក្នុងការប្រមូលវិភាគទានរបស់អ្នកភូមិ ។ បែបបទនៃការអនុញ្ញាតិលើការចាយវាយ និងការជួលអ្នកម៉ៅការមិនអាចឱ្យគេយល់បានជាទូទៅទេ ។ ការបញ្ចេញប្រាក់ពីរតនាគារជាតិពេលខ្លះ

---

[៨] សូមមើល Mansfield and MacLeod, *Commune Council and Civil Society*, 7-8 ដែលមាននិយាយពីជំហ៊ានក្នុងដំណើរការដេញថ្លៃ។

[៩] សូមមើលការពិភាក្សា Rusten et al ទៅលើពាក្យថាការចូលរួមនៅក្នុងជំពូកទី៧នៃ *The Challenges of the Decentralization Design in Cambodia*

មានការយឺតយ៉ាវ ហើយពេលខ្លះបានតិចជាងការរំពឹងទុក[១០] ។ គំរោងហេដ្ឋារចនាសម្ព័ន្ធមិនត្រូវបានធ្វើស្រប ទៅតាមកំរិតបទដ្ឋានទេ។ ការចំណាយសំរាប់គំរោងអភិវឌ្ឍន៍តាមធម្មតាមិនត្រូវបានសាធារណជនទូទៅដឹងទេ ។ ផលដែលបានមកពីគំរោង ទោះបីជាផ្តល់ឱ្យជាទូទៅក្តី តែមិនឃើញមានច្រើនទេ ។ ការពឹងផ្អែកទៅលើក្រុមសំរបសំរួលថ្នាក់ស្រុក និងទីភ្នាក់ងារអភិវឌ្ឍន៍នៅក្នុងការមពពេញការងារ នៅពេលខ្លះដូចជាមានច្រើនហួសពេក ។ ប្រហែលគេអាចយល់បានថា ទោះបីជាមានកង្វល់ខ្លះក្តី ក៏ដំណើរការត្រូវបានជំរុញដោយផែនការ និងលក្ខខ័ណ្ឌដែលដាក់ចុះដោយថ្នាក់លើ ជាជាងដោយការរៀនសូត្រចេញពីថ្នាក់ក្រោម ។

*ប្រៀបធៀបបទពិសោធន៍នៅក្នុងការអភិវឌ្ឍន៍មូលដ្ឋាន (Comparative Experiences in Local Development)*

ការរកឃើញខាងលើនេះ បង្ហាញឱ្យឃើញពីនិន្នាការជាទូទៅ តែចំណុចលំអិតនៃបទពិសោធន៍របស់បុគ្គល ក៏ជាការល្អដែលគេត្រូវដឹងដែរ ។

នៅក្នុងឃុំក្រាំងលាវ (ខេត្តតាកែវ) ការសិក្សាវាយតំលៃពីសេចក្តីត្រូវការ ត្រូវបានធ្វើឡើងនៅក្នុងភូមិនិមួយៗនៃភូមិទាំង២៣ ។ បន្ទាប់មក គេយកលទ្ធផលនេះមកបូកសរុបជាផែនការ៥ឆ្នាំ ដោយមានការជួយជ្រោមជ្រែងពីក្រុមសំរបសំរួលថ្នាក់ស្រុករបស់កម្មវិធីសីលា ។ ក្រុមប្រឹក្សាឃុំពឹងផ្អែកជាបឋមទៅលើប្រធានភូមិ និងVDC ដើម្បីធ្វើការសិក្សាវាយតំលៃ ក្នុងនាមគេជាសមាជិកនៃគណៈកម្មាធិការផែនការនិងថវិកា ដែលរួមមានសមាជិកក្រុមប្រឹក្សាឃុំផងដែរ។ ជាទូទៅ ការប្រជុំធ្វើផែនការមានការចូលរួមច្រើន ទោះបីជាការប្រជុំនោះអ្នកភូមិមានការយល់ច្រឡំជាមួយនឹងការប្រជុំលើកមុនៗដែលគេបានចូលរួម ។ ការប្រជុំខ្លះត្រូវបានធ្វើឡើងក្នុងនាមក្រុមប្រឹក្សាឃុំ ហើយការប្រជុំខ្លះទៀតក្នុងនាមអង្គការមិនមែនរដ្ឋាភិបាល ។ ដូចគ្នានេះដែរ អ្នកភូមិខ្លះចូលរួមនៅ ក្នុងការវាយតំលៃពីសេចក្តីត្រូវការ ហើយអ្នកខ្លះបានចូលរួមនៅក្នុងការប្រជុំក្នុងពេលធ្វើឧទ្ទេសនាមពីផែនការរួម៥ឆ្នាំ ។ ក្រុមប្រឹក្សាឃុំបានសាងសង់សាលារៀនចំនួនបួន ដោយប្រើថវិកាឃុំ ទោះបីជាគេមានការពិបាកនៅក្នុងការប្រមូលវិភាគទានរបស់អ្នកស្រុកក្តី ។ ចំណុចគួរអោយកត់សំគាល់គឺថា ក្រុមប្រឹក្សាឃុំអាចដឹកនាំគំរោងហេដ្ឋារចនាសម្ព័ន្ធធំៗដទៃទៀត នៅក្នុងក្របខ័ណ្ឌនៃផែនការប្រាំឆ្នាំរបស់គេ តាមរយៈថវិកា និងជំនួយដែលទទួលបានពី World Vision Cambodia និង Spean Kampuchea-Holland ។

នៅក្នុងឃុំចំប៉ី (ខេត្តកំពត) គណៈកម្មាធិការរៀបចំផែនការនិងថវិកាបានសិក្សាវាយតំលៃ និងកំណត់លំដាប់ អាទិភាពនៃសេចក្តីត្រូវការនៅក្នុងភូមិទាំង៨ ។ គណៈកម្មាធិការនេះរួមមានសមាជិក

---

[១០] បើយោលទៅតាម Seila/PLG Mid-Term 2003 មានតែ៥០%នៃថវិកាសំរាប់រដ្ឋបាល និង៤០%នៃថវិកាសំរាប់ការងារអភិវឌ្ឍន៍តែប៉ុណ្ណោះត្រូវបានបញ្ចេញនៅទូទាំងប្រទេសទៅអោយរតនាគារខេត្តសំរាប់ឃុំនៅត្រឹមដំណាច់ខែតុលា ឆ្នាំ ២០០៣ (ត្រូវបានលើកឡើងនៅក្នុង Rusten et al, *The Challenges of Decentralization Design in Cambodia*)

ក្រុមប្រឹក្សាឃុំ ប្រធានភូមិ តំណាងសង្គមស៊ីវិលដូចជា VDC។ ជាក់ស្តែង ក្រុមសង្គមស៊ីវិលចូលរួមយ៉ាងសកម្ម នៅក្នុងការធ្វើផែនការ តែប្រជាជនទូទៅនៅតែស្ថិតនៅក្រៅរង្វង់ ហើយមិនយល់ច្បាស់ពីអ្វីដែលកើតឡើងនោះទេ។ ផែនការ៥ឆ្នាំដែលរៀបចំឡើងដោយសមាជិកក្រុមប្រឹក្សាឃុំ និងសមាជិកគណៈកម្មាធិការ ហើយដោយមានការជួយរបស់ក្រុម សំរបសំរួលថ្នាក់ស្រុក និងអង្គការ GTZ ដើម្បីធ្វើការឆ្លុះបញ្ចាំងទៅនឹងថវិកាមានកំរិតរបស់ឃុំ។ ក្រុមប្រឹក្សាឃុំ បានធ្វើផ្លូវ និងលូ ដោយសារលុយរបស់រដ្ឋាភិបាល GTZ ហើយអង្គការដទៃទៀតដែលផ្តល់ថវិកាសំរាប់លើកកំពស់ផ្នែកកសិកម្ម បសុពេទ្យ ការថែទាំសុខភាពនៅតាមភូមិ ហើយនិងគំរោងដទៃទៀត ។ ក្រុមប្រឹក្សាជួបប្រទះនឹងបញ្ហាមួយចំនួន នៅក្នុងការប្រមូលប្រាក់វិភាគទានពីអ្នកភូមិ និងត្រូវដោះស្រាយជាមួយនឹងគ្រួសារដែលមានដីប៉ះចំកន្លែងត្រូវធ្វើផ្លូវ ។ ប៉ុន្តែតំណាងសង្គមស៊ីវិលពន្យល់ដោយមោទនៈភាពថា ការរួមចំណែកនៃធនធាន ពីប្រជាជនធ្វើអោយគេមានស្មារតីម្ចាស់ការទទួលខុសត្រូវលើគំរោងជាច្រើន ។ នៅក្នុងពេលជាមួយគ្នានោះ តំណាងសង្គមស៊ីវិលដដែលនេះបានអះអាងថា មានការប្រសើរឡើងក្នុងការគ្រប់គ្រងហិរញ្ញវត្ថុ និងមានតម្លាភាព អាចផ្តល់ផលប្រយោជន៍ដល់ការអនុវត្តន៍គំរោង ។

នៅក្នុងឃុំច្រេស (ខេត្តកំពត) គណៈកម្មាធិការផែនការនិងថវិកា ដែលមានសមាជិក ជាសមាជិកក្រុមប្រឹក្សាឃុំទាំង៥នាក់ ប្រធានភូមិ៤នាក់ សមាជិក VDC ៤នាក់ ហើយនិងតំណាងភូមិ២នាក់ បានធ្វើផែនការ៥ឆ្នាំ ដោយមានការជួយពីក្រុមសំរបសំរួលថ្នាក់ស្រុក ស៊ីដសេ ហើយនិងអង្គការ FAO ។ ប្រធានភូមិ និង VDC ទទួលខុសត្រូវជាចំបងនៅក្នុងការរកមើលនិងកំណត់លំដាប់អាទិភាពនៅក្នុងភូមិទាំងបួនរបស់ឃុំ ។ ក្រុមប្រឹក្សាឃុំកសាងគំរោងហេដ្ឋារចនាសម្ព័ន្ធ (សាលារៀន ផ្លូវថ្នល់ ទ្វារទឹក) ដោយប្រើថវិការបស់ឃុំ ទោះបីជាការអនុវត្តន៍សកម្មភាពតាមផែនការនោះជួបនឹងឧបសគ្គដោយអ្នកភូមិមិនចង់ចូលរួមជាថវិកានិងលុយកាក់ក្តី ។ ម្យ៉ាងគឺដោយសារសមាជិកក្រុមប្រឹក្សាឃុំមាននិន្នាការប្រកាន់គណបក្សនយោបាយ ។ សមាជិកដែលមកពីសង្គមស៊ីវិលនៅក្នុងគណៈកម្មាធិការផែនការនិងថវិកាបានត្អូញត្អែរថាគេមិនដឹងច្បាស់ពីការចំណាយលើការអភិវឌ្ឍន៍របស់ឃុំ ហើយថាសំណង់ខ្លះដែលត្រូវបានកសាងឡើងមិនបានបំពេញតាមបទដ្ឋាននៃកំរិតបច្ចេកទេសទេ ។ ទោះបីជាមានឧបសគ្គយ៉ាងនេះក្តី មានជំនួយរបស់អង្គការស៊ីដសេនិង FAO សំរាប់បន្ថែមលើគំរោងសកម្មភាពនេះ មានន័យថាឃុំច្រេសទទួលបាននូវអត្ថប្រយោជន៍ច្រើនផ្នែកអភិវឌ្ឍន៍ ។

នៅក្នុងឃុំផ្ទះរុង (ខេត្តពោធិសាត់) គណៈកម្មាធិការផែនការនិងថវិកា ដែលរួមមានប្រធានភូមិ និងមេឃុំ បានជួយបំផុសការចូលរួមរបស់ប្រជាជននៅក្នុងដំណើរការធ្វើផែនការ ។ ការសិក្សាវាយតំលៃពីសេចក្តីត្រូវការត្រូវបានធ្វើឡើងនៅក្នុងភូមិទាំង១៣ ដោយមានជំនួយពីក្រុមសំរបសំរួលថ្នាក់ស្រុក ។ ទោះបីជាមានសកម្មភាពអាទិភាពជាច្រើនក៏ដោយ ក្រុមប្រឹក្សាបានសំរេចផ្តល់ថវិកាជាចំបងទៅលើគំរោងផ្នែកហេដ្ឋារចនាសម្ព័ន្ធដូចជា

អណ្ដូងទឹក ផ្លូវថ្នល់ សាលារៀន និងប្រឡាយទឹក ។ VDC ត្រូវបានគេអំពាវនាវអោយជួយផ្សព្វផ្សាយផែនការចុងក្រោយទៅប្រជាជន និងរៃអង្គាសវិភាគទានពីអ្នកភូមិ ។ ជាទូទៅ ក្រុមសង្គមស៊ីវិលមិនមានការពាក់ព័ន្ធច្រើននៅក្នុងដំណើរការនេះទេ ។ ក្រុមអ្នកសំរបសំរួលថ្នាក់ស្រុក បានជួយចាត់ចែងដំណើរការដេញថ្លៃ និងអ្នកម៉ៅការដើម្បីគោរពតាមបទដ្ឋានបច្ចេកទេសនៃគំរោង ។ ថវិកាបែងចែកសំរាប់យកទៅចាយនោះ មិនត្រូវបានគេយកទៅប្រើបានខ្ជាប់ខ្ជួនតាមការកំណត់ទេ ហើយថវិកាច្រើនតែគេដកពីគំរោងមួយយកទៅប្រើនៅក្នុងគំរោងមួយទៀត ។ គំរោងដែលមាននៅក្នុងផែនការ ដែលទទួលថវិកាពីអង្គការកម្មវិធីស្បៀងអាហារពិភពលោក និងអង្គការអភិវឌ្ឍន៍ដទៃទៀតត្រូវបានតាមដាន និងអនុវត្តន៍ដោយផ្ទាល់ដោយក្រុមអង្គការទាំងនេះ ។

នៅក្នុងឃុំមេទឹក (ខេត្តពោធិសាត់) ប្រធានភូមិ VDC ហើយនិងបុគ្គលិករបស់អង្គការ Concern Worldwide មានការទទួលខុសត្រូវច្រើនជាងគេ លើការប៉ាន់ប្រមាណលើសេចក្ដីត្រូវការនៅក្នុងភូមិទាំង១៥។ គណៈកម្មាធិការរៀបចំផែនការនិងថវិកា ដែលមានសមាជិកក្រុមប្រឹក្សាឃុំចំនួន៩នាក់ រួមជាមួយនឹងសមាជិក VDC ចំនួន២នាក់ មកពីភូមិនីមួយៗនៃភូមិ១៥នោះ បានបញ្ចូលផែនការភូមិទៅក្នុងផែនការឃុំរយៈពេល៥ឆ្នាំដោយមានជំនួយពីអង្គការ Concern Worldwide និងក្រុមសំរបសំរួលថ្នាក់ស្រុក ។ ក្រុមប្រឹក្សាឃុំផ្ដល់ថវិកាសំរាប់គំរោងហេដ្ឋារចនាសម្ព័ន្ធដូចជា ផ្លូវថ្នល់ និងប្រព័ន្ធស្រោចស្រព តែមានការពិបាកនៅក្នុងការប្រមូលវិភាគទានបដិភាគដោយសារប្រជាជនខ្វះស្បៀងខ្លាំង ។ អង្គការ Concern Worldwide បានផ្ដល់មួយចំណែកធំនៃថវិកាដល់ផែនការរបស់ឃុំ ទោះបីជាខ្លួនផ្ដោតទៅលើភូមិចំនួន៥ដែលស្ថិតនៅក្នុងតំបន់កម្មវិធីរបស់ខ្លួនក៏ដោយ។ ការផ្ដល់ថវិកាដូច្នេះ ធ្វើអោយ Concern Worldwide អាចគ្រប់គ្រងនិងតាមដានគំរោងបាន តែវាបង្វែរទិសនៃការអភិវឌ្ឍន៍មូលដ្ឋាន ហើយបានធ្វើអោយលេចចេញនូវ បញ្ហាប្រឈមមុខចំពោះអង្គការមិនមែនរដ្ឋាភិបាលដែលគិតគូរទៅមុខចំពោះអភិបាលកិច្ចមូលដ្ឋាន។

## ភាពជាដៃគូរវាងក្រុមប្រឹក្សាឃុំ និងសង្គមស៊ីវិល

### *ការកសាងភាពជាដៃគូ*

នៅមុនពេលបោះឆ្នោតឃុំ/សង្កាត់នៅខែកុម្ភៈឆ្នាំ ២០០២ អង្គការមិនមែនរដ្ឋាភិបាលបានសំដែងនូវកង្វល់និងការសង្ស័យចំពោះវិមជ្ឈការនៅក្នុងប្រទេសកម្ពុជា ។ គេបានរិះគន់លើច្បាប់បោះឆ្នោតតាមប្រព័ន្ធសមាមាត្រនិងការប្រើបញ្ជីគណបក្ស ហើយគេបានចោទជាសំណួរធ្ងន់ៗអំពីបំណងពិតប្រាកដនៃការកែទំរង់បែបវិមជ្ឈការ និងលទ្ធភាពដែលអាចធ្វើអោយប៉ះពាល់ ឬអាចបានផលប្រយោជន៍ពីកម្មវិធីអភិវឌ្ឍន៍របស់អង្គការមិនមែនរដ្ឋាភិបាលដើម្បីបំពេញបំណងផ្នែកនយោបាយ ។ យោលទៅលើការបារម្ភពីដំបូងមកនេះ កំរិតនៃការសហការដែលគេបានកត់សំគាល់មករវាងអង្គការមិនមែនរដ្ឋាភិបាល និងក្រុមប្រឹក្សាឃុំនៅក្នុងឃុំទាំង៥ ដែលបានសិក្សានោះឃើញថា

ល្អគួរអោយកត់សំគាល់ ។ អង្គការមិនមែនរដ្ឋាភិបាលជួយបណ្តុះបណ្តាល ដល់សមាជិកនៃក្រុមប្រឹក្សាឃុំ នៅក្នុងវគ្គធ្វើផែនការ ហើយថែមទាំងបង្ហាញនូវចិត្តចង់ផ្តល់ថវិកាជួយដល់គំរោងនានាក្នុងផែនការ៥ឆ្នាំរបស់ឃុំ ។ VDC និងសមាគមអ្នកដឹកនាំភូមិ ដែលជាសមាជិកនៃគណៈកម្មាធិការថវិកា និងផែនការបានធ្វើការជិតស្និទ្ធជាមួយនឹងក្រុមប្រឹក្សាឃុំ ដើម្បីធ្វើការសិក្សាវាយតំលៃពីសេចក្តីត្រូវការរបស់ភូមិ និងដើម្បីបូកសរុបផែនការ៥ឆ្នាំ ។ សមាជិកនៃសមាគមភូមិបានចូលរួមយ៉ាងសកម្មនៅក្នុងវគ្គធ្វើផែនការ និងបានរួមចំណែកជាថវិកាបដិភាគ សំរាប់ដំណើរការគំរោងនៅក្នុងឃុំ ។

ដោយផ្តោតទៅលើភាពជាដៃគូនៅក្នុងការធ្វើវិមជ្ឈការ អង្គការមិនមែនរដ្ឋាភិបាលបានបើកសិក្ខាសាលាស្តីពីភាពជាដៃគូពីថ្ងៃទី ២៧ ដល់ ២៩ ខែ មករា ឆ្នាំ ២០០៣ ជាមួយនឹងតំណាងក្រុមប្រឹក្សាឃុំនិងសង្គមស៊ីវិលមកពីឃុំចំនួន១១ ។ នៅក្នុងសិក្ខាសាលានោះ ភាពជាដៃគូត្រូវបានគេកំណត់ថាជា "ទំនាក់ទំនងដែលផ្តល់ផលប្រយោជន៍ទៅវិញទៅមករវាងភាគីពីរឬច្រើន ដើម្បីសំរេចលើគោលដៅរួមនិងគោលដៅរបស់ភាគីនីមួយៗ" ។ លក្ខណៈសម្បត្តិជាមូលដ្ឋាននៃភាពជាដៃគូ ត្រូវបានគេកំណត់ថាជាការគោរពគ្នាទៅវិញទៅមក គោលដៅរួម ការប្តេជ្ញាចិត្ត និងការពិភាក្សាដោយមានអត្ថន័យ[១១] ។ ឯកសារបោះពុម្ពនៅពេលថ្មីៗនេះរបស់អង្គការ PACT ស្តីពីក្រុមប្រឹក្សាឃុំ/សង្កាត់ និងសង្គមស៊ីវិលកំណត់និយមន័យនៃភាពជាដៃគូថា ជា "ទំនាក់ទំនងរវាងក្រុមប្រឹក្សាឃុំ/សង្កាត់ និងសមាជិករបស់ខ្លួន ជាមួយនឹងភាគីមួយឬច្រើនដើម្បីសំរេចគោលបំណងរួមដែលត្រូវបានប្រកាសចេញ"[១២] ។ គ្រាន់តែមានការសហការគ្នារវាងក្រុមប្រឹក្សាឃុំ និងក្រុមសង្គមស៊ីវិល នៅក្នុងឃុំទាំង៥ ក្នុងរយៈកាលកន្លងមកនេះ គេមិនទាន់អាចនិយាយថា បានបង្កើតឡើងនូវភាពជាដៃគូពិតប្រាកដនោះទេ ។ គេត្រូវការរង់ចាំអោយពេលវេលាកន្លងទៅមួយរយៈសិន ហើយគេត្រូវការការខិតខំថែមទៀត ដើម្បីអោយទំនាក់ទំនងដែលមានសព្វថ្ងៃនេះអាចក្លាយទៅជាភាពជាដៃគូពេញលេញ ។ ទោះជាយ៉ាងណាក្តី ការសំរបសំរួលនិងសហប្រតិបត្តិ-ការមានភាពប្រសើរឡើង ហើយក្រុមប្រឹក្សាឃុំ និងក្រុមសង្គមស៊ីវិលបានធ្វើការរួមគ្នាជិតស្និទ្ធ ដើម្បីរៀបចំ និងអនុវត្តន៍ផែនការឃុំ ។

*ការប្រៀបធៀបបទពិសោធន៍ក្នុងការកសាងភាពជាដៃគូ*

ទោះបីជាមានទំនាក់ទំនងសហការគ្នារវាងក្រុមប្រឹក្សាឃុំ និងសង្គមស៊ីវិលនៅក្នុងឃុំទាំង៥ក្តី តែទំនាក់ទំនងនីមួយៗខុសៗគ្នា ។

---

[១១] សូមមើល Shelley Flam, *Perspectives for Partnership: Workshop Handbook*, (Phnom Penh: CIDSE Cambodia, January 2003).

[១២] Mansfield and MacLeod, *Commune Council & Civil Society*, 4.

នៅក្នុងឃុំក្រាំងលាវ (ខេត្តតាកែវ) ក្រុមប្រឹក្សាឃុំបានទទួលជោគជ័យនៅក្នុងការធ្វើអោយអង្គការមិនមែនរដ្ឋាភិបាល និងទីភ្នាក់ងារអភិវឌ្ឍន៍ចូលរួមនៅក្នុងការផ្តល់ថវិកាដល់គំរោងផែនការ៥ឆ្នាំរបស់ឃុំ ។ ការងារនេះជួយពង្រីកការអភិវឌ្ឍន៍របស់ក្រុមប្រឹក្សាឃុំ ហើយនៅពេលជាមួយគ្នានោះដែរ ក៏បានបង្វែរអង្គការឱ្យចៀសវាងការរៀបចំធ្វើកម្មវិធីដូចគ្នា ។ ដោយមានអង្គការពីក្រៅមួយចំនួនធ្វើការនៅក្នុងឃុំនេះ ដូច្នេះកំរិតនៃជំនួយបច្ចេកទេសគឺមានច្រើន ។ ក្រុមប្រឹក្សាឃុំពឹងពាក់យ៉ាងខ្លាំងលើ VDC នៅក្នុងការធ្វើការសិក្សាវាយតំលៃពីសេចក្តីត្រូវការ និងបំផុសអោយអ្នកស្រុកចូលរួមវិភាគទាន ។ ក្រោមការស្ពាបនារបស់កម្មវិធីសីលា និងការទទួលខុសត្រូវតិចតួចចំពោះសកម្មភាពដែលគាំទ្រដោយអង្គការមិនមែនរដ្ឋាភិបាល VDC ត្រៀមជួយដល់ការងាររបស់ក្រុមប្រឹក្សាឃុំ ។ បើគេធ្វើការប្រៀបធៀប ក្រុមប្រឹក្សាមិនបានសកម្មក្នុងការធ្វើអោយសមាគមភូមិចូលរួមនៅក្នុងការងារសហការទេ ។

នៅក្នុងឃុំចំប៉ី (ខេត្តកំពត) ក្រុមប្រឹក្សាឃុំបានទទួលការបណ្តុះបណ្តាល និងជំនួយថវិកាជាច្រើនពីអង្គការ GTZ ដែលជាអង្គការអភិវឌ្ឍន៍ទ្វេភាគី ។ អង្គការមិនមែនរដ្ឋាភិបាលមួយចំនួនតូចដែលធ្វើការនៅក្នុងឃុំបានសហការយ៉ាងជិតស្និទ្ធិជាមួយនឹងក្រុមប្រឹក្សាឃុំ តែមិនមែនក្នុងទ្រង់ទ្រាយធំនោះទេ ។ ការដែលថា GTZ (ព្រមទាំងPLG) ធ្វើការតាមរយៈបុគ្គលិករដ្ឋ មានន័យថាក្រុមប្រឹក្សាឃុំមានការទាក់ទងជាច្រើនជាមួយនឹងតំណាងរបស់រដ្ឋ ហើយការទាក់ទងជាមួយនឹងអង្គការមិនមែនរដ្ឋាភិបាលគឺមានតិច ។ នៅតាមថ្នាក់មូលដ្ឋាន VDC និង សមាគមភូមិបានចូលរួមនៅក្នុងការប៉ាន់ប្រមាណពីសេចក្តីត្រូវការ ហើយចូលរួមដល់ការអនុវត្តន៍គំរោង ដូចជាការកសាងផ្លូវថ្នល់ជាដើម ។ ចំណុចគួរអោយកត់សំគាល់ បណ្តាក្រុមមនុស្សនៅក្នុងភូមិ ដូចជាធនាគារស្រូវឥណទាន និងតុជួល ដែលបានបង្កើតឡើងដោយអង្គការ GTZ ពឹងផ្អែកលើក្រុមប្រឹក្សាឃុំក្នុងការផ្តល់ការណែនាំ និងធ្វើសវនកម្មលើគណនេយ្យហិរញ្ញវត្ថុ ។ ការងារនេះបង្ហាញអោយឃើញពីភាពល្អក់កករ នៃទំនាក់ទំនងរវាងសង្គមស៊ីវិលនិងរដ្ឋអំណាចនៅតាមមូលដ្ឋាន ។

នៅក្នុងឃុំច្រេស (ខេត្តកំពត) ក្រុមប្រឹក្សាឃុំបានផ្តើមសកម្មភាពអភិវឌ្ឍន៍របស់គេជាមួយនឹងកម្មវិធីអភិវឌ្ឍន៍សហគមន៍ដ៏ធំមួយរបស់អង្គការស៊ីដសេ ដែលត្រូវបានដំណើរការយៈពេល៨ឆ្នាំមកហើយ ។ ដើម្បីឈានទៅធ្វើការរួមគ្នា ក្រុមប្រឹក្សា និងអង្គការស៊ីដសេបានសំរបសំរួលការធ្វើផែនការអភិវឌ្ឍន៍ភូមិ ហើយស៊ីដសេ បានផ្តល់ថវិកាសំរាប់គំរោងផែនការ៥ឆ្នាំ ដែលស្របទៅតាមគោលបំណងរបស់ខ្លួន ។ នៅក្នុងពេលជាមួយគ្នានោះសកម្មភាពអភិវឌ្ឍន៍របស់ស៊ីដសេនៅក្នុងសហគមន៍មានភាពទូលំទូលាយជាងសកម្មភាព ដែលបានគេកំណត់យកជាអាទិភាពនៅក្នុងផែនការឃុំ ហើយបើនិយាយអោយចំទៅរួមមានកម្មវិធីស្របមួយទៅនឹងកម្មវិធីរបស់ក្រុមប្រឹក្សាឃុំ ។ ការនេះចោទជាបញ្ហាចំពោះភាពជាដៃគូដែលទើបតែមានថ្មីថ្មោង ។ ក្រុមប្រឹក្សាឃុំត្រូវការស្វែង

អោយឃើញថា ខ្លួនអាចគ្រប់គ្រងកម្មវិធីធំៗបានប្រកបដោយភាពស្មោះត្រង់នៅក្នុងការចាត់ចែងលុយកាក់ ចំណែកឯស៊ីដសេវិញ ត្រូវការបញ្ចូលសកម្មភាពច្រើនទៀតរបស់ខ្លួនទៅក្នុងផែនការ៥ឆ្នាំ ។ ក្រៅពីនេះ ដោយស៊ីដសេជួយពង្រឹងសមត្ថភាពរបស់ក្រុមប្រឹក្សាឃុំនៅក្នុងការអភិវឌ្ឍន៍មូលដ្ឋាននោះ ខ្លួនត្រូវពង្រឹងសំលេងរបស់ក្រុមសង្គមស៊ីវិលនៅក្នុងទំនាក់ទំនងជាមួយនឹងអាជ្ញាធរមូលដ្ឋាន ។ ការដែល ស៊ីដសេបង្កើតសមាគម VDC នៅថ្នាក់ឃុំគឺជាជំហ៊ានចាំបាច់នៅក្នុងទិសដៅនេះ ។ ចំណែកក្រុមប្រឹក្សាឃុំច្រេស ត្រូវការយកចិត្តទុកដាក់ចំពោះVDC និងសមាគមភូមិ ។

នៅក្នុងឃុំផ្ទះរុង (ខេត្តពោធិសាត់) ក្រុមប្រឹក្សាឃុំបានលើកទឹកចិត្តអោយអង្គការមិនមែនរដ្ឋាភិបាលធ្វើការសំរបសំរួលការងារដើម្បីជៀសវាងការធ្វើសកម្មភាពការងារដូចគ្នា និងដើម្បីផ្តល់ថវិកាដល់គំរោងដូចដែលត្រូវបានលើកឡើងនៅក្នុងផែនការ៥ឆ្នាំ។ ពិតមែនហើយថា ការសំរបសំរួលគ្នាមានការកែលំអរហើយអង្គការមិនមែនរដ្ឋាភិបាលបានផ្តល់ថវិកាសំរាប់សកម្មភាពខ្លះនៅក្នុងផែនការ៥ឆ្នាំ តែការផ្គត់ផ្គង់ថវិកាដល់គំរោងការអនុវត្តន៍និងការតាមដាន ត្រូវបានធ្វើដោយឡែកដោយក្រុមប្រឹក្សាឃុំ ហើយនិងអង្គការមិនមែនរដ្ឋាភិបាល ។ នៅក្នុងពេលជាមួយគ្នានោះ ក្រុមប្រឹក្សាឃុំមានទំនាក់ទំនងរឹងមាំជាមួយនឹងកម្មវិធីសីលារបស់រដ្ឋាភិបាល ដែលទទួលបានថវិកាពីPLG ។ ពីមុន សីលាបានបង្កើត VDC ហើយបានរួមចំណែកធនធានជាច្រើនដល់ឃុំតាមរយៈថវិកាអភិវឌ្ឍន៍មូលដ្ឋាន ។ ដោយសារថាវាជាកម្មវិធីរបស់រដ្ឋាភិបាល សីលាមិនសូវមានតួនាទីនៅក្នុងការជំរុញអោយមានទំនាក់ទំនងកាន់តែជិតស្និទ្ធ រវាងក្រុមប្រឹក្សាឃុំហើយនិងអង្គការមិនមែនរដ្ឋាភិបាល ឬសមាគមនៅតាមភូមិទេ ។ ក្រុមប្រឹក្សាឃុំ ច្រើនតែធ្វើការតាមរយៈប្រធានភូមិ ហើយមិនធ្វើការបណ្តុះអោយមានទំនាក់ទំនងជាមួយនឹងក្រុមសមាគមនៅតាមភូមិទេ ។

នៅក្នុងឃុំមេទឹក (ខេត្តពោធិសាត់) ក្រុមប្រឹក្សាឃុំមានទំនាក់ទំនងជាយុទ្ធសាស្ត្រជាមួយនឹងអង្គការ Concern Worldwide ។ អង្គការនេះបានរៀបចំយុទ្ធសាស្ត្រប្រតិបត្តិមួយច្បាស់លាស់សំរាប់ជួយដល់ការងាររបស់ក្រុមប្រឹក្សាឃុំនៅក្នុងការអភិវឌ្ឍន៍មូលដ្ឋាននៅក្នុងរង្វង់ក្របខ័ណ្ឌនៃកម្មវិធីសីលា ។ ការងារនេះរួមមានការរកមើលឃុំដែលក្រីក្រ ការបណ្តុះបណ្តាលលើកំណែទំរង់អភិបាលកិច្ចមូលដ្ឋាននិងវិមជ្ឈការ ការវិភាគស្ថានភាពនៅក្នុងសហគមន៍ និងជំនួយនៅក្នុងការគ្រប់គ្រងវដ្តនៃការអភិវឌ្ឍន៍គំរោង[១៣] (Project Development Cycle)។ នៅឃុំមេទឹក ក្រុមប្រឹក្សាឃុំទទួលជំនួយច្រើនពីអង្គការ Concern Worldwide នៅក្នុងដំណើរការអភិវឌ្ឍន៍ ។ តែការប្រកាន់ផលប្រយោជន៍គណបក្សនយោបាយរបស់សមាជិកក្រុមប្រឹក្សាឃុំ

---

[១៣] សូមមើល " NGO Pathways to Decentralization: The Experience of Concern Worldwide," *Commune Council Support Project Bulletin*, July 2003, issue No. 14.

និងការប្រកាន់ខ្ជាប់របស់អង្គការ Concern Worldwide ទៅលើការអភិវឌ្ឍន៍របស់ខ្លួន ព្រមទាំងលក្ខខ័ណ្ឌ ទាមទារថវិកាបានធ្វើ អោយទំនាក់ទំនងមានការពិបាកនៅពេលខ្លះ ។ ទោះបីជាក្រុមប្រឹក្សាឃុំពឹងផ្អែកលើ VDC នៅក្នុងការអនុវត្តនីភារកិច្ចដែលទាក់ទងនឹងការធ្វើផែនការនិងការអនុវត្តនីផែនការអភិវឌ្ឍន៍ក្តី តែខ្លួនមិនមាន ទំនាក់ទំនងជាមួយនឹង VDC ឬសមាគម ដទៃទៀតនៅក្នុងភូមិបានជាប់លាប់ទេ ។

## ការទំនាក់ទំនងជាមួយរដ្ឋាភិបាលនៅថ្នាក់ជាតិ និងគណបក្សនយោបាយ

*ទាក់ទងជាមួយរដ្ឋអំណាចថ្នាក់លើ*

ដើម្បីធានាជោគជ័យលើការកែទំរង់បែបវិមជ្ឈការ រាជរដ្ឋាភិបាលកម្ពុជាបានខិតខំអនុម័តច្បាប់ និងផ្តល់ប្រព័ន្ធនិងនិតិវិធីសំរាប់ជួយដល់ការងាររបស់ក្រុមប្រឹក្សាឃុំ ។ ជាទូទៅ ការធ្វើដូច្នេះបានជោគជ័យ[១៤] ។ ការងាររបស់ក្រុមសំរបសំរួលថ្នាក់ស្រុករបស់កម្មវិធីសីលាគឺមានលក្ខណៈគួរអោយកត់សំគាល់ជាពិសេស ។ នៅក្នុងឃុំទាំង ៩ដែលបានសិក្សា ក្រុមអ្នកសំរបសំរួលថ្នាក់ស្រុកបានផ្តល់ជំនួយយ៉ាងសំខាន់ដល់ក្រុមប្រឹក្សាឃុំនៅក្នុងការអភិវឌ្ឍន៍មូលដ្ឋាន ។ ជំនួយនេះរួមមានផ្តល់ការបណ្តុះបណ្តាលផ្នែកគ្រប់គ្រង សំរួលដល់ការសិក្សាអំពីការប៉ាន់ប្រមាណពីសេចក្តីត្រូវការរបស់ភូមិ សរសេរផែនការ៥ឆ្នាំ រៀបចំសិក្ខាសាលាសមាហរណកម្មថ្នាក់ស្រុក រៀបចំដំណើរការដេញថ្លៃ និងតាមដានការអនុវត្តនីគំរោង ។ ការងារដែលសំរេចបានដោយក្រុមអ្នកសំរបសំរួលថ្នាក់ស្រុកអាចថាមានច្រើន ប៉ុន្តែមិនផ្តល់ឱកាសសំរាប់រៀនសូត្រឡើយ[១៥] ។ អំណាច និងថវិកាត្រូវបានផ្ទេរទៅអោយក្រុមប្រឹក្សាឃុំ ហើយនិងជំនួយដែលបានមកពីកម្មវិធីសីលា ធ្វើការពឹងផ្អែករបស់ឃុំលើរដ្ឋអំណាចថ្នាក់ស្រុកមានការថយចុះ ។ នៅពេលជាមួយគ្នានោះ ថវិកាឃុំដែលមានកំណត់ និងឧបសគ្គនៅក្នុងការប្រមូលពន្ធរបស់ក្រុមប្រឹក្សាឃុំធ្វើឱ្យគេពឹងផ្អែកខ្លាំងទៅលើរដ្ឋាភិបាលថ្នាក់ជាតិ ។

---

[១៤] Robert B. Oberndorf, *Law Harmonization in Relation to Decentralization,* បទឧទ្ទេសនាមនៅឯសិក្ខាសាលាផ្សព្វផ្សាយស្តីពីបញ្ហាប្រឈមមុខនៅក្នុងការរៀបចំវិមជ្ឈការនៅក្នុងប្រទេសកម្ពុជា ដែលរៀបចំធ្វើដោយវិទ្យាស្ថានអភិវឌ្ឍន៍ធនធានកម្ពុជា (CDRI) នៅភ្នំពេញ កាលពីខែមករា ឆ្នាំ ២០០៤ ។

[១៥] Rusten et al, *Challenges of the Decentralization Design in Cambodia,* (*បញ្ហាប្រឈមមុខនៃការរៀបចំវិមជ្ឈការនៅក្នុងប្រទេសកម្ពុជា*) អះអាងថាភាពខ្សោយនៃសមត្ថភាពនៅក្នុងការជួយរបស់ក្រុមអ្នកសំរបសំរួលថ្នាក់ស្រុក ស្ថិតនៅត្រង់ថាក្រុមនេះមិនសូវមានលទ្ធភាព ធ្វើការផ្តួចផ្តើមគំនិតទៅនឹងមូលដ្ឋាន ។ គេស្នើសុំថា "ដល់ពេលហើយ (យ៉ាងហោចណាស់នៅតាមខេត្តដែលមានកម្មវិធីសីលាពីមុន) ដែលគេត្រូវរៀបចំឡើងវិញលើការជួយបង្កើនសមត្ថភាព ហើយត្រូវផ្តោតការយកចិត្តទុកដាក់ទៅលើការសិក្សា ដោយផ្ទាល់ជាជាងដោយប្រយោល ហើយត្រូវផ្តល់ឱកាសសំរាប់គំនិតផ្តួចផ្តើមថ្មីៗសំរាប់ជំរុញដល់ការផ្តល់សេវា" ។ Mansfield និង MacLeod, *Commune Council & Civil Society, 29, 30 & 33* ជំរុញដល់កំណើននៃការទាក់ទងគ្នាទៅវិញទៅមករវាងសហគមន៍ ។

ជាមួយគ្នានោះ ការអនុវត្តន៏តាមប្រព័ន្ធសមាមាត្រតំណាង និងបញ្ជីរគណបក្សនៅក្នុងដំណើរការបោះឆ្នោតធានាថាគណបក្សនយោបាយមានតួនាទីសំខាន់នៅក្នុងការកំណត់វិធីធ្វើការកែទំរង់បែបវិមជ្ឈការ ។ នៅក្នុងឃុំទាំង៥ ដែលបានសិក្សាភាគច្រើននៃសមាជិកក្រុមប្រឹក្សាឃុំ និងមេឃុំទាំងអស់សុទ្ធតែជាសមាជិករបស់គណបក្សប្រជាជន ដែលជាការធ្វើអោយគេនឹកគិតដល់រដ្ឋបាលចាស់ ។ ដូចគ្នានេះដែរ នៅតាមភូមិទាំងអស់នៅក្នុងឃុំទាំង៥នោះ ផ្លាកសញ្ញារបស់គណបក្សប្រជាជន ហ៊ុនសុិនប៊ុច និងសមរង្ស៊ីធ្វើអោយគេមើលឃើញច្បាស់ពីការយកចិត្តទុកដាក់លើផលប្រយោជន៏របស់គណបក្សនៅក្នុងជីវភាពរស់នៅតាមមូលដ្ឋាន ។ ជាទូទៅ ការជ្រៀតចូលនៃការប្រជែងគ្នារវាងគណបក្សនៅតាមមូលដ្ឋាន រឹតតែធ្វើអោយមានការមិនត្រូវគ្នា និងមានការបែងចែក ហើយបង្អាក់ដល់ការខិតខំជំរុញអោយមានការសហការ និងសាមគ្គីគ្នារបស់អ្នកមូលដ្ឋាន ។ ការដែលថាសមាជិកក្រុមប្រឹក្សាឃុំជាប់ឆ្នោតជាតំណាងគណបក្សនយោបាយ មានន័យថាគេគិតពីផលប្រយោជន៏គណបក្សនយោបាយរបស់គេ ច្រើនជាងផលប្រយោជន៏របស់ប្រជាជនដែលបោះឆ្នោតអោយគេ ។ ទោះជាមានយ៉ាងនេះក្តី ភាគច្រើននៃក្រុមប្រឹក្សាឃុំដែលត្រូវបានសិក្សានោះ អាចចរចារគ្នាដើម្បីជំនះលើការខ្វែងគំនិតគ្នារវាងគណបក្ស ហើយធ្វើការដើម្បីប្រយោជន៏នៃឃុំរបស់គេ ។ នៅក្នុងករណីដទៃទៀត ការប្រកាន់គណបក្សនយោបាយ បង្ករជាឧបសគ្គ ដល់ប្រសិទ្ធិភាពការងាររបស់ក្រុមប្រឹក្សាឃុំ[១៦] ។

*ប្រៀបធៀបបទពិសោធន៏ក្នុងការទំនាក់ទំនងជាមួយរដ្ឋអំណាចថ្នាក់លើ*

ដូចនៅក្នុងវិស័យផ្សេងទៀតដែលត្រូវបានស្រាវជ្រាវផងដែរ ទំនាក់ទំនងរបស់ក្រុមប្រឹក្សាឃុំជាមួយនឹងរដ្ឋអំណាចថ្នាក់លើ និងគណបក្សនយោបាយមានភាពខុសគ្នា ។

នៅក្នុងឃុំក្រាំងលាវ (ខេត្តតាកែវ) ក្រុមប្រឹក្សាឃុំបានដើរតាមសេចក្តីណែនាំរបស់ក្រសួងមហាផ្ទៃបានយ៉ាងខ្ជាប់ខ្ជួន ដូចជាការធ្វើរបាយការណ៏ទៀងទាត់ទៅអាជ្ញាធរស្រុកនិងខេត្ត ។ មេឃុំពូកែប្រាស្រ័យទាក់ទងហើយចេះទាញយកប្រយោជន៏ពីសិក្ខាសាលាសមាហរណកម្មថ្នាក់ស្រុក ដើម្បីបានជំនួយពីមន្ទីរ ក្រសួងពាក់ព័ន្ធ និងអង្គការអភិវឌ្ឍន៏ខាងក្រៅ ។ ក្រុមប្រឹក្សាដែលមានសមាជិកមានចំនួនលើសលុបមកពីគណបក្សប្រជាជនមានទំនាក់ទំនងរឹងមាំជាមួយនឹងរដ្ឋមន្ត្រី និងសមាជិករដ្ឋសភានៅភ្នំពេញដែលអាចផ្តល់ការឧបត្ថម្ភដោយផ្ទាល់ ។

---

16 Caroline Hughes សរសេរថាវិមជ្ឈការរួមចំណែកដល់ការលើកកំពស់ទំនាក់ទំនងរវាងគណបក្សនៅថ្នាក់មូលដ្ឋាននៅក្នុងការបោះឆ្នោតឆ្នាំ ២០០៣ នៅពេលប្រៀបធៀបនឹងការបោះឆ្នោតឆ្នាំ ១៩៩៨ ។ ប៉ុន្តែ គាត់បានសុំអោយមានការប្រយ័ត្នថាសូម្បីតែនៅក្នុងឆ្នាំ ២០០៣ ក៏មិនមានស្មារីរួមនិងសហប្រតិបត្តិការរវាងតំណាងគណៈបក្សនៅតាមមូលដ្ឋានទេ ។ សូមមើល Hughes, "Evolution of Conflict Management During Election Periods," *Cambodia Development Review*, January-March 2004 .

នៅក្នុងឃុំចំប៉ី (ខេត្តកំពត) ក្រុមប្រឹក្សាឃុំបានធ្វើរបាយការណ៍ជាទៀងទាត់ទៅមន្ត្រីថ្នាក់ស្រុក ហើយមេឃុំបានចូលរួមក្នុងការប្រជុំនៅថ្នាក់ស្រុក ។ ក្រុមប្រឹក្សាមានទំនាក់ទំនងល្អជាមួយនឹងមន្ទីរស្ថាប័នរដ្ឋក្នុងផ្នែកកសិកម្ម និងសុខាភិបាល ដែលបានជួយដល់ការងារអភិវឌ្ឍន៍នៅក្នុងឃុំ ។ ក្រុមប្រឹក្សាចង់បង្កើតទំនាក់ទំនងជិតស្និទ្ធជាមួយនឹងមន្ត្រីធំៗនៅក្នុងរដ្ឋាភិបាល ដើម្បីសុំការឧបត្ថម្ភសំរាប់គំរោងហេដ្ឋារចនាសម្ព័ន្ធធំៗ ដូចជាផ្លូវថ្នល់ សាលារៀន និងមណ្ឌលសុខភាព ។ ក្រុមប្រឹក្សាដែលមកពីគណបក្សនយោបាយចំរុះ ជាទូទៅអាចជំនះបានលើនិន្នាការនយោបាយខុសគ្នា ហើយស្រុះស្រួលធ្វើការជាមួយគ្នា ។

នៅក្នុងឃុំច្រេស (ខេត្តកំពត) ក្រុមប្រឹក្សាឃុំបានទទួលការគាំទ្រយ៉ាងខ្លាំងពីអាជ្ញាធរស្រុក ។ មន្ត្រីថ្នាក់ស្រុកបានធ្វើការកោះប្រជុំរវាងបុគ្គលិកកម្មវិធីសីលា និងសមាជិកក្រុមប្រឹក្សាឃុំដើម្បីដោះស្រាយការលំបាក ដែលបានកើតឡើងនៅក្នុងការអនុវត្តន៏គំរោង ។ គេមានតួនាទីយ៉ាងសំខាន់នៅក្នុងការតាមដានគំរោងហេដ្ឋារចនាសម្ព័ន្ធរបស់ឃុំ ។ ការលំអៀងផ្នែកនយោបាយនាំអោយមានការប្រជែងគ្នានៅក្នុងការអនុវត្តន៏គំរោង ហើយប៉ះពាល់ដល់ការចូលរួមរបស់អ្នកភូមិ ។ សមាជិកក្រុមប្រឹក្សាឃុំច្រើនប្រើមុខតំណែងរបស់ខ្លួន ដើម្បីធ្វើអោយប្រជាជនមានភក្ដីភាព និងគាំទ្រដល់គណបក្សរបស់គេ ។

នៅក្នុងឃុំផ្ទះរុង (ខេត្តពោធិសាត់) ក្រុមប្រឹក្សាឃុំបានទទួលជំនួយពីកម្មវិធីសីលា ដែលបានផ្ដល់អោយឃុំនូវជំនួយអភិវឌ្ឍន៍តាំងពីឆ្នាំ ១៩៩៦មក ។ សីលាបានជួយកសាងសមត្ថភាពរបស់សមាជិកក្រុមប្រឹក្សាឃុំ ហើយបានជួយការងាររបស់គេទាក់ទងនឹងការអនុវត្តន៏ ព្រមទាំងការធ្វើផែនការអភិវឌ្ឍន៏ ។ ជារួម ក្រុមប្រឹក្សាឃុំដែលមានសមាជិកមកពីគណបក្សច្រើនបានខិតខំជំនះនិន្នាការនយោបាយខុសគ្នារបស់គេ ដើម្បីបំរើផលប្រយោជន៍ប្រជាជននៅក្នុងតំបន់របស់គេ ។ ជាទូទៅ គឺឃើញមានជោគជ័យ ទោះបីជាការមានការប្រជែងគ្នារវាងគណបក្ស និងការមិនពេញចិត្តគ្នាក្ដី ។

នៅក្នុងឃុំមេទឹក (ខេត្តពោធិសាត់) ក្រុមប្រឹក្សាឃុំបានធ្វើរបាយការណ៏ទៀងទាត់ទៅអោយអភិបាលស្រុក និងប្រធានមន្ទីរស្ថាប័នដែលមានការពាក់ព័ន្ធ ។ ក្រុមប្រឹក្សាក៏បានសំរបសំរួលការងារជិតស្និទ្ធជាមួយនឹងកម្មវិធីសីលា ។ តែការប្រកាន់គណបក្សនយោបាយនៅតែជាឧបសគ្គចំពោះការអនុវត្តន៏ការងារជារួមរបស់ក្រុមប្រឹក្សាចំរុះគណបក្ស ។ ដោយមិនអាចជំនះបានលើនិន្នាការគណបក្ស ហើយមិនអាចធ្វើការដោយមានប្រសិទ្ធិភាព ក្រុមប្រឹក្សាឃុំបាត់បង់ការគាំទ្ររបស់ប្រជាជនខ្លួន ហើយធ្វើអោយប្រជាជនមានការស្រងាកចិត្តយ៉ាងខ្លាំង ។

# សេចក្តីសន្និដ្ឋាន

**ការរៀនសូត្រពីបទពិសោធន៍របស់ក្រុមប្រឹក្សាឃុំ**

ការពិនិត្យលើបទពិសោធន៍របស់ក្រុមប្រឹក្សាឃុំទាំង៥ ដែលបានស្រាវជ្រាវនៅក្នុងដំណាក់កាលដំបូងនៃការកែទំរង់វិមជ្ឈការ ផ្តល់ការលើកទឹកចិត្តច្រើនក្នុងការគាំទ្រក្នុងទ្រង់ទ្រាយទូលំទូលាយដល់កម្មវិធី។ ទោះបីជាភាពជឿនលឿនរហូតមកទល់នឹងពេលនេះមិនមានទៅព្រមគ្នាហើយមិនច្បាស់លាស់ក្តី តែគេសំរេចបានសមិទ្ធិផលច្រើន នៅក្នុងរយៈពេលដ៏ខ្លីនេះ ។ ក្រុមប្រឹក្សាឃុំបានពង្រីកការចូលរួមពីតំណាងដែលមកពីគណបក្សផ្សេងៗនៅក្នុងរដ្ឋបាលឃុំ ហើយទទួលខុសត្រូវលើការសំរេចចិត្តដែលគេបានធ្វើ ។ ក្រុមប្រឹក្សាក៏បានចេញបទបញ្ជារបស់ឃុំ សំរាប់ដោះស្រាយបញ្ហាសំខាន់ៗដែលកើតឡើងនៅក្នុងឃុំ ។ ជាទូទៅ ដោយសារចំនួននៃសមាជិកក្រុមប្រឹក្សាមានកាន់តែច្រើន ក្រុមប្រឹក្សាអាចទាក់ទងជាមួយនឹងមជ្ឈដ្ឋានជាច្រើន ហើយឆ្លើយតបចំពោះបញ្ហាដែលត្រូវបានបញ្ជូនមក ដូចជានៅក្នុងដំណោះស្រាយជំលោះ និងក្នុងការផ្តល់សេវាសាធារណៈ[១៧] ។ ក្រុមប្រឹក្សាបានចាប់ផ្តើមផ្សព្វផ្សាយពត៌មានតាមរយៈ VDC ។ ពីមុន គេផ្សព្វផ្សាយតែតាមរយៈប្រធានភូមិទេ ។ ទោះជាយ៉ាងណាក៏ដោយ ក្រុមប្រឹក្សាមិនបានជោគជ័យក្នុងការបង្កើតទំនាក់ទំនងជិតស្និទ្ធជាមួយនឹងប្រជាជនសាមញ្ញ និងការដឹកនាំអោយគេចូលរួមនៅក្នុងដំណើរការវិមជ្ឈការទេ ។

ចំពោះការអភិវឌ្ឍន៍មូលដ្ឋានវិញ ក្រុមប្រឹក្សាឃុំទាំង៥ដែលត្រូវបានស្រាវជ្រាវ បានបង្ហើយនូវភារកិច្ចជាគោលដែលត្រូវបានកំណត់អោយធ្វើ ។ ឧទាហរណ៍ ក្រុមប្រឹក្សាទាំងអស់បានបង្ហើយនូវការរៀបចំផែនការ៥ឆ្នាំ ហើយបានអនុវត្តន៍គំរោងហេដ្ឋារចនាសម្ព័ន្ធក្នុងទ្រង់ទ្រាយតូច។ ជាមួយគ្នានោះរដ្ឋអំណាចមូលដ្ឋាន និងថ្នាក់ដឹកនាំសង្គមស៊ីវិល បានចូលរួមយ៉ាងសកម្មនៅក្នុងដំណើរការការងារ តែប្រជាជនមិនសូវជាចូលរួមច្រើនទេ ។ ជាទូទៅ ក្រុមប្រឹក្សាឃុំចូលរួមនៅក្នុងការធ្វើផែនការ និងអនុវត្តន៍គំរោងនៅតាមមូលដ្ឋាន ឃើញថាជាបទពិសោធន៍សំរាប់ដើម្បីដកស្រង់ជាមេរៀនដ៏មានប្រយោជន៍មួយ ។ នៅក្នុងពេលជាច្រើនឆ្នាំតទៅមុខទៀត ត្រូវរៀបចំកែសំរួលនិតិវិធីបន្ថែម ដើម្បីធ្វើអោយមានការផ្តួចផ្តើមគំនិតពីមូលដ្ឋាន ហើយការធ្វើដូចនេះ នឹងនាំអោយមានការចូលរួមព្រមទាំងមានភាពម្ចាស់ការលើការងាររបស់ខ្លួនកាន់តែច្រើនឡើង ។ ដើម្បីធានាប្រសិទ្ធិភាពរយៈពេលយូរទៅមុខ ក្រុមប្រឹក្សាឃុំត្រូវអនុវត្តន៍សិទ្ធិរបស់គេនៅក្នុងការប្រមូលថវិកា តាមរយៈការទារពន្ធ និងការទទួលបានថវិកាជាតិ

---

[១៧] សូមមើល Mansfield and MacLeod, *Commune Council & Civil Society*, 13-14, 19-21 ទាក់ទងនឹងការពិភាក្សាលើការចូលរួមរបស់ក្រុមប្រឹក្សាឃុំនៅក្នុងការជួយដោះស្រាយជំលោះនិងផ្តល់សេវាសាធារណៈ ។

ច្រើន និងថវិកាពីអង្គការអភិវឌ្ឍន៍នានា ។ ដូចគ្នានេះដែរ ក្រុមប្រឹក្សាឃុំមិនត្រូវផ្តល់ថវិកាសំរាប់តែគំរោងហេដ្ឋារចនាសម្ព័ន្ធទ្រង់ទ្រាយតូចៗប៉ុណ្ណោះទេ តែត្រូវដោះស្រាយបញ្ហាចំពោះមុខធ្ងន់ធ្ងរនៅក្នុងសហគមន៍ផងដែរដូចជា កង្វះស្បៀងធ្ងន់ធ្ងរ ចំណាកស្រុកដើម្បីទៅរកការងារធ្វើនៅតំបន់ផ្សេង ជំងឺអេដស៍ ហើយនិង ភាពគ្មានការងារធ្វើនៅតាមតំបន់ជនបទជាដើម។ ប្រការចាំបាច់ ក្នុងការគិតគូរដល់បញ្ហានេះគឺ ត្រូវតែធ្វើការ តស៊ូមតិជាមួយនឹងថ្នាក់លើ ពោលគឺការពង្រីងសំលេងខ្លាំងក្លាមួយ ក្នុងការជំរុញអោយគិតគូរទៅលើបញ្ហា គោលនយោបាយថ្នាក់ជាតិសំរាប់ដោះស្រាយបញ្ហាទាំងនេះ ។

តាំងពីដើមទសវត្សទី៩០មក រាជរដ្ឋាភិបាលបានអនុញ្ញាតអោយអង្គការមិនមែនរដ្ឋាភិបាល ធ្វើការដោយផ្ទាល់ជាមួយនឹងសហគមន៍មូលដ្ឋាន ។ ទាក់ទងនឹងរឿងនេះ អង្គការមិនមែនរដ្ឋាភិបាល បានចុះហត្ថលេខាលើអនុស្សារណៈនៃកិច្ចព្រមព្រៀងជាមួយនឹងក្រសួងពាក់ព័ន្ធ ផ្ញើរបាយការណ៍ទៅមន្ត្រីខេត្ត និងចូលរួមប្រជុំនៅថ្នាក់ខេត្ត នៅពេលដែលមានការចាំបាច់។ ទន្ទឹមនឹងនោះ អង្គការក៏បានជំរាបទៅរដ្ឋអំណាចមូលដ្ឋានអំពីប្រភេទការងាររបស់គេដែរ ។ អង្គការមានការទំនាក់ទំនងជាមួយថ្នាក់ដឹកនាំឃុំ និងមេភូមិ តែគេយល់ថា រដ្ឋអំណាចមូលដ្ឋានគឺជាតំណាងដែលត្រូវបានតែងតាំងពីសំណាក់គណបក្សដែលមានសំលេងភាគច្រើន ទើបគេសំរេចចិត្តមិនផ្តល់ធនធានសំរាប់ការងារអភិវឌ្ឍន៍ តាមរយៈរដ្ឋអំណាចមូលដ្ឋានដែលតែងតាំងនោះទេ ។ ការធ្វើដូច្នេះ បានធ្វើអោយកម្មវិធីអភិវឌ្ឍន៍របស់អង្គការមិនមែនរដ្ឋាភិបាល មានដំណើរទន្ទឹមគ្នាទៅនឹងកម្មវិធីអភិវឌ្ឍន៍នានារបស់រដ្ឋដែរ ។ លុះមកដល់ពេលវេលាដែលមានការបង្កើតក្រុមប្រឹក្សាឃុំជាស្ថាប័នដែលត្រូវបានបោះឆ្នោត តាមលក្ខណៈប្រជាធិបតេយ្យ ហើយដែលមានភារកិច្ចធ្វើផែនការ និងអនុវត្តន៍ការងារអភិវឌ្ឍន៍នោះ ពេលនោះគេមើលឃើញថា មានបញ្ហាប្រឈមមុខមួយយ៉ាងធំដល់អង្គការមិនមែនរដ្ឋាភិបាល ។ ជាទូទៅ អង្គការមិនមែនរដ្ឋាភិបាលដែលធ្វើការនៅក្នុងឃុំទាំង៩ដែលត្រូវបានស្រាវជ្រាវ បានសំដែងអោយឃើញថា គេមានការយកចិត្តទុកដាក់ចំពោះលទ្ធភាពនៃការធ្វើការសហការជិតស្និទ្ធជាមួយនឹងក្រុមប្រឹក្សាឃុំ។ ជាក់ស្តែង គេបានជួយក្នុងដំណើរការធ្វើផែនការមូលដ្ឋាន ។ តែគេនៅមានការសង្ស័យចំពោះសមត្ថភាពរបស់សមាជិកក្រុមប្រឹក្សាឃុំ ហើយនិងការប្រើប្រាស់ថវិកាអោយបានសមស្រប ។ នៅពេលដែលអង្គការបានផ្តល់ថវិកាទៅតាមគំរោងផែនការ៥ឆ្នាំរបស់ឃុំ ពួកគេត្រូវបានទទួលឱ្យក្សានាទីខាងគ្រប់គ្រង និងត្រួតពិនិត្យ ។ គេមើលឃើញច្បាស់ថា អង្គការស្ថិតនៅក្នុងជំហរពេញលេញ ក្នុងការជំរុញដល់ការងាររបស់ក្រុមប្រឹក្សាឃុំបាន ។ តែដោយសារទំហំនៃកម្មវិធីរបស់អង្គការ ដែលកំពុងតែធ្វើដំណើរស្របគ្នាជាមួយកម្មវិធីរបស់រដ្ឋ និងការមន្ទិលសង្ស័យរបស់គេ ក្នុងការធ្វើការជាមួយនឹងរដ្ឋាភិបាល ព្រមទាំងទម្លាប់ធ្វើការដោយឯករាជ្យរបស់គេផងនោះ អង្គការមិនមែនរដ្ឋាភិបាលក៏អាចបង្ករជាឧបសគ្គក្នុងការអនុវត្តន៍ការងាររបស់ក្រុមប្រឹក្សាឃុំបានដែរ ។

លទ្ធផលសំខាន់មួយរបស់អង្គការមិនមែនរដ្ឋាភិបាលធ្វើការនៅក្នុងសហគមន៍មូលដ្ឋានគឺ ការបង្កើតបានជាគណៈកម្មការសង្គមស៊ីវិល និងសមាគមផ្សេងៗដូចជា គណៈកម្មការអភិវឌ្ឍន៍ភូមិ ធនាគារស្រូវ ធនាគារគោឥណទានសាច់ប្រាក់ និងក្រុមស្ត្រី ដែលក្រុមទាំងនេះបំពេញបន្ថែមលើក្រុមដែលមានស្រាប់ដូចជា ក្រុមជួយខ្លួនឯង និងក្រុមអាចារ្យវត្តជាដើម។ នៅក្នុងឃុំទាំង៥ដែលត្រូវបានស្រាវជ្រាវ តំណាងរបស់ក្រុមទាំងនេះត្រូវបានគេអំពាវនាវអោយចូលរួមនៅក្នុងសមាសភាពគណៈកម្មាធិការផែនការ និងថវិកាដែរ ។ សមាជិកនៃគណៈកម្មាធិការទាំងនេះ បានចូលរួមយ៉ាងសកម្មនៅក្នុងការធ្វើផែនការឃុំ និងដំណើរការអនុវត្តន៍ការងារច្រើនជាងប្រជាជនទូទៅក្នុងភូមិ ។ ជាពិសេសទៅទៀត ក្រុមសង្គមស៊ីវិលនៅថ្នាក់មូលដ្ឋានទាំងនេះ បានចោទជាសំណួរអំពីការអនុវត្តន៍របស់ក្រុមប្រឹក្សាឃុំទាក់ទងនឹងការផ្សព្វផ្សាយពត៌មាន និងតម្លាភាពនៃការចំណាយផងដែរ។ នៅក្នុងចំណោមប្រជាជនទូទៅ សមាគមទាំងនេះមានលទ្ធភាពច្រើនជាងគេក្នុងការធ្វើអោយក្រុមប្រឹក្សាឃុំមានការទទួលខុសត្រូវចំពោះរាល់សកម្មភាពរបស់គេ ។ គួរកត់សំគាល់ថា ការប្តេជ្ញាចិត្តរបស់ក្រុមសង្គមស៊ីវិលនៅក្នុងការធ្វើការជាមួយនឹងក្រុមប្រឹក្សាឃុំ នៅពេលខ្លះសមាគមនៅតាមមូលដ្ឋាន មិនត្រូវបានផ្តល់សារៈសំខាន់គ្រប់គ្រាន់ក្នុងតួនាទីតាមដានមើលការងាររបស់ក្រុមប្រឹក្សា ក្នុងភាពជាដៃគូថ្មីថ្មោងនោះទេ ។ ពិសេសគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ ច្រើនតែធ្វើខ្លួនជាអ្នកនៅក្រោមបង្គាប់របស់ក្រុមប្រឹក្សាឃុំ ដោយមិនហ៊ានចោទសួរទៅលើភាពស្មោះត្រង់ក្នុងការបំពេញការងាររបស់ក្រុមប្រឹក្សាទេ ។

ចំពោះក្រុមប្រឹក្សាឃុំវិញ ពួកគេមានការស្វាគមន៍ចំពោះការជួយពីសំណាក់ថ្នាក់ដឹកនាំសង្គមស៊ីវិលក្នុងការសិក្សាប៉ាន់ប្រមាណតម្រូវការ និងការបំផុសអោយមានការរួមវិភាគទានបដិភាគពីប្រជាជន ។ តែតាមធម្មតាក្រុមប្រឹក្សាឃុំចាត់ទុកអ្នកទាំងនេះហាក់ដូចជា ភ្នាក់ងាររបស់គេនៅក្នុងភូមិដូចគ្នាទៅនឹងប្រធានភូមិដែរ។ ជាទូទៅក្រុមប្រឹក្សាឃុំមិនយល់ ឬមិនទទួលយកនូវទំនាក់ទំនងក្នុងភាពជាដៃគូស្មើគ្នា និងជួយបំពេញគ្នាទៅវិញទៅមករវាងសង្គមស៊ីវិល និងរដ្ឋអំណាចមូលដ្ឋាននោះទេ។ នៅតាមឃុំទាំងឡាយដែលក្នុងនោះអង្គការមិនមែនរដ្ឋាភិបាលមានភាពមិនសូវសកម្ម គេមើលឃើញថាមានបញ្ហានេះច្បាស់ ហើយខ្សែបន្ទាត់ទំនាក់ទំនងរវាងសង្គមស៊ីវិលហើយនិងរដ្ឋអំណាចមូលដ្ឋាន មានភាពមិនច្បាស់លាស់ ។

សូមកោតសរសើរចំពោះរាជរដ្ឋាភិបាលកម្ពុជា ដែលបានខិតខំគាំទ្រដល់កំណែទំរង់វិមជ្ឈការនេះ ។ ការរួមចំណែករបស់កម្មវិធីសីលាក្នុងដំណើរការនេះ ក៏មានការទទួលស្គាល់ដែរ ។ ការចូលពាក់ព័ន្ធរបស់គណបក្សនយោបាយបានធ្វើអោយមានបញ្ហាច្រើន។ ជាក់ស្តែង មានក្រុមប្រឹក្សាឃុំខ្លះអាចធ្វើការជាមួយគ្នាបាន ទោះជាមានការមិនចុះសំរុងគ្នាក្នុងរឿងគណបក្សនយោបាយក្តី តែក្រុមប្រឹក្សាឃុំខ្លះទៀត មិនអាចធ្វើបានទេ ។ ការទទួលខុសត្រូវចំពោះថ្នាក់លើនៃគណបក្សរៀងៗខ្លួន និងការមិនសូវមានការទទួលខុសត្រូវចំពោះមុខប្រជាជនបង្កើតបានជាឧបសគ្គយ៉ាងធំ ក្នុងដំណើរការកែទំរង់នេះ។ វិមជ្ឈការ តម្រូវអោយមានទំនាក់ទំនងហ្មត់ចត់រវាងថ្នាក់

កណ្តាល និងថ្នាក់មូលដ្ឋាន ហើយនៅក្នុងបរិយាកាសនយោបាយនៃប្រទេសកម្ពុជា ការនេះត្រូវមានការចូលរួមពាក់ព័ន្ធនៃគណបក្សនយោបាយដែរ ។ ទោះជាយ៉ាងណាក្តី បទពិសោធន៍នៅទូទាំងសកលលោកសង្កត់ធ្ងន់ថា នៅពេលមិនសូវមានការទទួលខុសត្រូវ ជាទូទៅដំណើរការវិមជ្ឈការត្រូវបរាជ័យ[១៨] ។ ដោយហេតុនេះហើយ ទើបការសិក្សាស្រាវជ្រាវពេញលេញមួយរបស់ CDRI ទៅលើដំណើរការវិមជ្ឈការនៅក្នុងប្រទេសកម្ពុជាបានទាមទារថា ច្បាប់បោះឆ្នោត និងច្បាប់ស្តីពីរដ្ឋបាលនិងការគ្រប់គ្រងឃុំ/សង្កាត់ ត្រូវតែមានការកែប្រែដើម្បីធ្វើយ៉ាងណាអោយសមាជិកក្រុមប្រឹក្សាឃុំ/សង្កាត់ ទទួលខុសត្រូវចំពោះមុខប្រជាជនជាជាងការទទួលខុសត្រូវចំពោះគណបក្សនយោបាយរបស់ខ្លួន[១៩] ។

## ការរួមចំណែកកាត់បន្ថយភាពក្រីក្រ និងលទ្ធិប្រជាធិបតេយ្យនៅមូលដ្ឋាន

ដូចដែលបានគូសបញ្ជាក់នៅក្នុងសំរង់អត្ថបទនៃការសិក្សាស្រាវជ្រាវនេះស្រាប់ថា កំណែទំរង់វិមជ្ឈការមិនមែនសុទ្ធតែនាំទៅរកការកាត់បន្ថយភាពក្រីក្រ ឬលទ្ធិប្រជាធិបតេយ្យនៅមូលដ្ឋាននោះទេ ។ ដូច្នេះ គេត្រូវតែសិក្សាវាយតំលៃមើលថា គោលបំណងនេះបានឈានឆ្ពោះទៅរកការសំរេចបានក្នុងកំរិតណា ។ ទាក់ទងនឹងជំនួយផ្នែកអភិវឌ្ឍន៍ដើម្បីកាត់បន្ថយភាពក្រីក្រដែលត្រូវបានផ្តល់ទៅអោយឃុំទាំង៥ដែលស្រាវជ្រាវនេះ មានច្រើនណាស់ដែរ ព្រោះថាអង្គការមិនមែនរដ្ឋាភិបាល និងអង្គការអភិវឌ្ឍន៍ដទៃទៀតផ្តល់ជំនួយបច្ចេកទេស និងសំភារៈបន្ថែមពីលើថវិកាឃុំទៀត ។ ដោយ គិតដោយឡែក ថវិកាឃុំដែលទទួលបានពីរដ្ឋាភិបាលនៅក្នុងឆ្នាំ ២០០២ និង ២០០៣ សំរាប់ជាផ្នែកមួយនៃកម្មវិធីវិមជ្ឈការ គឺមានចំនួនស្តួចស្តើងបន្តិច ។ ការសង្កេតនេះមិនមែនមានបំណងបន្ទុះបង្អាប់ផលប្រយោជន៍ជាក់ស្តែងដែលបានមកពីគំរោងដែលប្រើប្រាស់ថវិកាឃុំនោះទេ តែគ្រាន់តែចង់គូសបញ្ជាក់ថា ការរួមចំណែកពីថវិកាកន្លងមកនេះចំពោះការកាត់បន្ថយភាពក្រីក្រគឺ នៅមានកំរិតទាបណាស់ ។ តែឃុំខ្លះ អាចមិនដូចករណីដែលបានលើកឡើងទេ ព្រោះថា នៅក្នុងឃុំចំនួនបីនៃឃុំទាំង៥ដែលត្រូវបានស្រាវជ្រាវ (មានឃុំចំប៉ី ឃុំច្រេស និង ឃុំផ្ទះរុង) មានសក្តានុពលពោលគឺ បើធ្វើការវិនិយោគក្នុងទ្រង់ទ្រាយធំទៅលើប្រព័ន្ធធារាសាស្ត្របាន អាចកែប្រែជីវភាពរស់នៅរបស់អ្នកជនបទ និងកាត់បន្ថយភាពក្រីក្របាន ។ ផ្ទុយទៅវិញ នៅក្នុងឃុំមួយទៀត ដែលស្រាវជ្រាវដែរនោះ (ឃុំមេទឹក) ជំនួយផ្នែកអភិវឌ្ឍន៍ពីប្រភពជាច្រើន មិនអាចទប់បាននឹងបញ្ហាគ្រោះរាំងស្ងួត និងទឹកជំនន់ដែលមានជាបន្តបន្ទាប់ ហើយជំរើសនៅក្នុងការកាត់បន្ថយភាពក្រីក្រគឺមាន

---

[១៨] J. Manor, *Local Governance.* ឯកសារដែលត្រូវបានយកទៅធ្វើឧទ្ទេសនាមនៅឯសិក្ខាសាលាស្តីពីអភិបាលកិច្ចល្អដែលរៀបចំឡើងដោយអង្គការ SIDA នៅក្រុងស្តុកហូម ខែ កញ្ញា ឆ្នាំ ២០០៣ បានពិពណ៌នានៅក្នុងសៀវភៅ Rusten et al, *The Challenges of the Decentralization Design in Cambodia.*

[១៩] សូមមើលជំរើសគោលនយោបាយ នៅក្នុងសៀវភៅ Rusten et al, *The Challenges of the Decentralization Design in Cambodia.*

ភាពស្មុគ្រស្មាញ ។ ការសង្កេតឃើញទាំងនេះ ទាមទារអោយមានយុទ្ធសាស្ត្រផ្សេងទៀតដើម្បីកាត់បន្ថយភាពក្រីក្រ នៅក្នុងដំណើរការវិមជ្ឈការ ។ មានយុទ្ធសាស្ត្រមួយគឺ ត្រូវបង្កើតលក្ខខ័ណ្ឌ (លើកកំពស់សមត្ថភាពរបស់អ្នកមូលដ្ឋាន និងផ្តល់ជំនួយពីខាងក្រៅ) ដែលអាចធ្វើអោយគេរៀបចំធ្វើផែនការសំដៅសំរេចបានសក្តានុពលពេញលេញ[២០] ។ មានយុទ្ធសាស្ត្រម្យ៉ាងទៀតគឺ ត្រូវបង្កើតអោយមានវេទិកាពិភាក្សារវាងថ្នាក់មូលដ្ឋាន និងថ្នាក់កណ្តាលស្តីពីបញ្ហាភាពក្រីក្រនៅទូទាំងប្រទេស ដើម្បីសំរបសំរួលក្នុងការដោះស្រាយបញ្ហាដែលមានច្រើនសណ្ឋាន។

ទាក់ទងនឹងការជំរុញលទ្ធិប្រជាធិបតេយ្យនៅតាមមូលដ្ឋាន កំណែទំរង់វិមជ្ឈការបានសំរេចសមិទ្ធិផលគួរអោយកត់សំគាល់ ។ ការបោះឆ្នោតឃុំ/សង្កាត់នៅក្នុងខែកុម្ភៈឆ្នាំ ២០០២ ធ្វើអោយពលរដ្ឋខ្មែរបោះឆ្នោតជ្រើសរើសមន្ត្រីថ្នាក់មូលដ្ឋានជាលើកដំបូងនៅក្នុងរយៈពេលរាប់ទសវត្សមកនេះ ។ នៅក្នុងឃុំ៤ ក្នុងចំណោមឃុំទាំង៥នោះ ក្រុមប្រឹក្សាឃុំមានសមាជិកមកពីគណបក្សនយោបាយបី ហើយនៅក្នុងឃុំមួយទៀត ក្រុមប្រឹក្សាមានសមាជិកមកពីគណបក្សនយោបាយតែចំនួនពីរប៉ុណ្ណោះ ។ ទោះបីនៅមានការប្រជែងគ្នារវាងគណបក្សក្តី តែការប្រជុំ និងពិភាក្សាគ្នាទៀងទាត់លើបញ្ហានានា បានបង្កើតឱកាសសំរាប់ធ្វើការផ្លាស់ប្តូរយោបល់គ្នា ដើម្បីធ្វើការសំរេចចិត្ត។ នៅក្នុងពេលជាមួយគ្នានោះដែរ ដំណើរការធ្វើផែនការជាលក្ខណៈចូលរួម កំណត់អោយសមាជិកក្រុមប្រឹក្សាសុំយោបល់ និងការសហការណ៍ពីតំណាងសង្គមស៊ីវិល និងប្រជាជនទូទៅ ។ ក្នុងន័យនេះ ការជំរុញលទ្ធិប្រជាធិបតេយ្យនៅតាមមូលដ្ឋាន និងការកាត់បន្ថយភាពក្រីក្រ ពិតជាមានការទាក់ទងគ្នាទៅវិញទៅមក ។ នៅក្នុងប្រទេសកម្ពុជា ការកាត់បន្ថយភាពក្រីក្រ ទាមទារអោយមានការលុបបំបាត់បញ្ហានៅក្នុងសង្គមជាច្រើនដូចជា ការភ័យខ្លាច ការមិនទុកចិត្តគ្នា អំពើហិង្សា អនក្ខរភាព ហើយនិងភាពព្រងើយកន្តើយ ដែលទាំងអស់នេះគឺជាផ្នែកសំខាន់នៃការលើកកំពស់ជីវភាពរស់នៅ[២១] ។ គេត្រូវរង់ចាំមើលថា តើវប្បធម៌នយោបាយក្នុងប្រទេសកម្ពុជា អាចជួយជំរុញក្នុងការលុបបំបាត់បញ្ហាខាងលើ ឬក៏វាតែធ្វើអោយលក្ខខ័ណ្ឌបច្ចុប្បន្ននេះ ចាក់ឫសកាន់ជ្រៅទៅទៀតឬយ៉ាងណានោះ ព្រោះជារឿងដែលមិនអាចទស្សន៍ទាយបានទេ ។ តាមពិតទៅ ដើម្បីអបអរចំពោះអនាគតនៃលទ្ធិប្រជាធិបតេយ្យនៅតាមមូលដ្ឋាននៅក្នុងប្រទេសកម្ពុជាទៅបាន គេត្រូវប្រមើលមើលការសំរេចបាននូវគោលបំណងនេះ ក្នុងរយៈពេលវែងឆ្ងាយតទៅមុខទៀត[២២] ។ ក្រោយរយៈពេល២ឆ្នាំដំបូងនៃកំណែទំរង់វិមជ្ឈការនេះ គេមើលឃើញថា នៅមានការងារច្រើនទៀតដែលត្រូវធ្វើ តែនៅពេលជាមួយគ្នានោះ ក៏មានអ្វីៗកើតឡើងច្រើនគួរជាទីមោទនៈផងដែរ ។

---

[២០] សូមមើល Rusten et al, *The Challenges of Decentralization Design in Cambodia* សំរាប់ការពិភាក្សាលើចំណុចនេះ ។

[២១] Caroline Rusten និង Joakim Ojendal, "Poverty Reduction through Decentralization? Lessons from Eleswhere and Challenges for Cambodia," *Cambodia Development Review*, October-December 2003, 5.

[២២] David Ayers, សន្ទរកថាដែលត្រូវបានថ្លែងនៅឯកិច្ចប្រជុំប្រចាំឆ្នាំរបស់គណៈកម្មាធិការសហប្រតិបត្តិការ ដើម្បីកម្ពុជា ធ្នូ ២០០១ ។

# អនុសាសន៍រួចសំរាប់អង្គការមិនមែនរដ្ឋាភិបាល

- អង្គការមិនមែនរដ្ឋាភិបាល ត្រូវការបង្កើនការយល់ដឹងរបស់គេលើដំណើរការវិមជ្ឈការ និងផលប៉ះពាល់ទៅលើកម្មវិធីរបស់គេ ។ ដោយក្រុមប្រឹក្សាឃុំ/សង្កាត់ ត្រូវបានបោះឆ្នោតតាមលទ្ធិប្រជាធិបតេយ្យ ហើយដែលមានតួនាទីក្នុងការអភិវឌ្ឍន៍មូលដ្ឋាននោះ អង្គការមិនមែនរដ្ឋាភិបាលលែងមានហេតុផលអ្វីក្នុងការបន្តអនុវត្តន៏កម្មវិធីរបស់ខ្លួន ដែលមានដំណើរទន្ទឹមគ្នានឹងកម្មវិធីរបស់ក្រុមប្រឹក្សាឡើយ ។

- អង្គការមិនមែនរដ្ឋាភិបាល ត្រូវការបង្កើនការចូលរួមរបស់សមាគមសង្គមស៊ីវិលដើម្បីកសាងទំនាក់ទំនងរឹងមាំរវាងក្រុមប្រឹក្សាឃុំ និងប្រជាជនទូទៅ ។ ក្រុមប្រឹក្សាឃុំមិនបានកសាងទំនាក់ទំនងជិតស្និទ្ធជាមួយនឹងប្រជាជនទូទៅក្នុងភូមិឃុំទេ តែមានទំនាក់ទំនងល្អទៅបាន លុះត្រាតែប្រជាជនទាំងនោះ បានចូលជាសមាជិកនៃក្រុមសង្គមស៊ីវិលណាមួយនៅក្នុងភូមិរបស់ខ្លួន ។

- អង្គការមិនមែនរដ្ឋាភិបាល ត្រូវការជួយដល់ការខិតខំរបស់សមាគមនៅមូលដ្ឋាន ក្នុងការធ្វើអោយក្រុមប្រឹក្សាឃុំទទួលខុសត្រូវចំពោះទង្វើរបស់គេ ។ នៅពេលដែលសមាគមនៅមូលដ្ឋានចូលរួមយ៉ាងសកម្មនៅក្នុងដំណើរការធ្វើផែនការនៅតាមមូលដ្ឋាន ពួកគេត្រូវរួមកម្លាំងគ្នាអោយកាន់តែច្រើន ដើម្បីធ្វើអោយក្រុមប្រឹក្សាឃុំ ហ៊ានទទួលខុសត្រូវចំពោះអ្វីដែលក្រុមប្រឹក្សានោះបានធ្វើ ។

- អង្គការមិនមែនរដ្ឋាភិបាល ត្រូវការជំរុញការរៀនសូត្រពីក្រុមប្រឹក្សាឃុំមួយទៅ ក្រុមប្រឹក្សាឃុំមួយនៅក្នុងតំបន់ប្រតិបត្តិការរបស់ខ្លួន ។ អង្គការមិនមែនរដ្ឋាភិបាល មានតួនាទីជំរុញការរៀនសូត្រក្នុងចំណោមក្រុមប្រឹក្សាឃុំបាន ពីព្រោះជាទូទៅ អង្គការធ្វើការគ្រប់ដណ្តប់នៅក្នុងឃុំច្រើន។

- អង្គការមិនមែនរដ្ឋាភិបាល ត្រូវរៀនសូត្រពីគ្នាទៅវិញទៅមកពីអង្គការមួយទៅអង្គការមួយ ។ អង្គការមិនមែនដ្ឋាភិបាល កំពុងតែរៀនសូត្រពីរបៀបប្រាស្រ័យទាក់ទងជាមួយនឹងក្រុមប្រឹក្សាឃុំ ដើម្បីអោយមានប្រសិទ្ធិភាព ហើយការចែករំលែកនូវបទពិសោធន៍ពីគ្នាទៅវិញទៅមក នឹងពិតជានាំមកនូវអត្ថប្រយោជន៍ច្រើន ។

- អង្គការមិនមែនរដ្ឋាភិបាល ត្រូវការធ្វើការតស៊ូមតិដើម្បីអោយមានការកែទំរង់លើការបោះឆ្នោត ដើម្បីធានាថា សមាជិកក្រុមប្រឹក្សា មានការទទួលខុសត្រូវចំពោះប្រជាជនជាម្ចាស់ឆ្នោត ជាជាងចំពោះ

គណបក្សនយោបាយ ។ ច្បាប់នៅពេលបច្ចុប្បន្ននេះ ធ្វើអោយសមាជិកក្រុមប្រឹក្សារឹតតែមានការទទួលខុសត្រូវចំពោគណៈបក្ស ជាជាងចំពោះប្រជាជនដែលជាម្ចាស់ឆ្នោត ។

- អង្គការមិនមែនរដ្ឋាភិបាល ត្រូវការធ្វើការតស៊ូមតិដើម្បីអោយក្រុមប្រឹក្សាឃុំទទួលបានចំណែកនៃថវិកាសំរាប់អភិវឌ្ឍន៍ឃុំ/សង្កាត់អោយបានកាន់តែច្រើនជាងបច្ចុប្បន្ននេះ ។ ក្រុមប្រឹក្សាត្រូវប្រើសិទ្ធិរបស់ខ្លួនដើម្បីប្រមូលថវិកា តាមរយៈការយកពន្ធ និងទទួលបាននូវចំណែកធំនៃថវិកាជាតិ ព្រមទាំងថវិកាពីអង្គការអភិវឌ្ឍន៍ផ្សេងៗ ដើម្បីអោយគំរោងនានារបស់ឃុំ បានចូលរួមចំណែកកាត់បន្ថយភាពក្រីក្រកាន់តែខ្លាំងឡើងថែមទៀត។

- អង្គការមិនមែនរដ្ឋាភិបាល ត្រូវការធ្វើការតស៊ូមតិដើម្បីអោយមានការកែប្រែបញ្ហាសង្គមធំៗ ដែលជាប្រការសំខាន់សំរាប់ភ្ជាប់ទំនាក់ទំនងនៃការកាត់បន្ថយភាពក្រីក្រទៅនឹងការជំរុញលទ្ធិប្រជាធិបតេយ្យនៅមូលដ្ឋាន ។ នៅក្នុងប្រទេសកម្ពុជា ការកាត់បន្ថយភាពក្រីក្រ ទាមទារអោយមានការលុបបំបាត់បញ្ហានៅក្នុងសង្គមជាច្រើន ដើម្បីពង្រីកលទ្ធិប្រជាធិបតេយ្យ ហើយការនេះទាមទារអោយមានវប្បធម៌នយោបាយនៅក្នុងប្រទេសកម្ពុជាដែលងាកឆ្ងាយពីការចាក់ឫសជ្រាលជ្រៅ ដែលបង្កអោយមានលក្ខខ័ណ្ឌដូចពេលសព្វថ្ងៃនេះ ។

ឧបសម្ព័ន្ធ ១

ករណីសិក្សាទី ១:

## ឃុំក្រាំងលាវ ស្រុកបាទី

## ខេត្តតាកែវ

## ជាឃុំដែលត្រូវបានជ្រើសរើស និងផ្តល់ជំនួយដោយអង្គការទស្សនៈពិភពលោក នៅកម្ពុជា

### ប្រវត្តិ

ក្រាំងលាវគឺជាឃុំមួយនៅក្នុងចំណោមឃុំចំនួន១៥នៅក្នុងស្រុកបាទី ខេត្តតាកែវ ។ ភាគច្រើននៃគ្រួសារនៅក្នុងភូមិចំនួន២៣នៅក្នុងឃុំនេះគឺជាកសិករ ទោះបីជាពួកគេមានដីស្រែតូច និងមិនសូវមានជីវជាតិ ក៏ដោយ ។ កត្តាទាំងនេះ បានធ្វើអោយឃុំនេះ ក្រីក្រជាងគេនៅក្នុងស្រុកបាទី ។ មានអាងស្តុកទឹកដ៏ធំមួយ ត្រូវបានជួសជុលចាប់តាំងពីឆ្នាំ ២០០៣។ នៅក្នុងឃុំនេះមានអង្គការអភិវឌ្ឍន៍ចំនួន៧ គឺ អង្គការទស្សនៈពិភពលោក អង្គការ RD/RP អង្គការកុមារ និងអភិវឌ្ឍន៍ អង្គការ HEKS និង អង្គការស្តានកម្ពុជា-ហុល្លង់ដ៏ ។

នៅក្នុងឆ្នាំ២០០១ គណៈកម្មាធិការអភិវឌ្ឍន៍ភូមិជាច្រើន ត្រូវបានបង្កើតឡើងនៅក្នុងឃុំ ដោយកម្មវិធីលា ដែលគាំទ្រដោយអង្គការ UNDP ។ គណៈកម្មាធិការអភិវឌ្ឍន៍ភូមិនីមួយៗដែលមានសមាជិក៥នាក់ ដោយមានសមាជិកនារីម្នាក់ផងនោះ បានសំរបសំរួលសកម្មភាពអភិវឌ្ឍន៍សហគមន៍ជាមួយនឹងប្រជាជននៅក្នុងភូមិ ។ ការងាររបស់គណៈកម្មាធិការនេះរួមមាន ការប្រមូលទិន្នន័យតាមគ្រួសារ និងការកំណត់តម្រូវការអាទិភាព រួចផ្តល់ពត៌មានទាំងនេះទៅដល់កម្មវិធីសីលា និងអង្គការមិនមែនរដ្ឋាភិបាលនានា ដើម្បីជួយដល់គំរោងអភិវឌ្ឍន៍នៅតាមភូមិ ។

អង្គការទស្សនៈពិភពលោកបានចាប់ផ្តើមធ្វើការនៅក្នុងភូមិ១០នៃភូមិទាំង២៣របស់ឃុំក្រាំងលាវនៅក្នុងឆ្នាំ ២០០១ បន្ទាប់មកបានពង្រីកដល់ភូមិចំនួន១៣នៅក្នុងឆ្នាំ ២០០៣ ហើយគ្រោងនឹងពង្រីកដល់ភូមិចំនួន១៥នៅក្នុង ឆ្នាំ ២០០៤ ។ កម្មវិធីរបស់អង្គការនេះផ្តោតទៅលើវិស័យបួនៈ កសិកម្ម ការថែទាំសុខភាពថ្នាក់បឋមនៅតាមរយៈមណ្ឌលសុខភាព តាមសាលាបឋមសិក្សា និងមធ្យមសិក្សា ព្រមទាំងការកសាងសមត្ថភាពក្នុងដំណើរការធ្វើផែនការ និងរៀបចំថវិកា ។

ក្រុមប្រឹក្សាឃុំដែលមានសមាជិកចំនួន ៩នាក់ ត្រូវបង្កើតឡើងក្រោយពីការបោះឆ្នោតនៅខែកុម្ភៈ ឆ្នាំ ២០០២។ សមាជិក៨នាក់មកពីគណបក្សប្រជាជន និងមួយនាក់មកពីគណបក្សហ៊្វុនស៊ិនប៉ិច។ សមាជិកទាំងអស់សុទ្ធតែជាបុរស ។ ចំពោះប្រធានក្រុមប្រឹក្សាឃុំវិញ ធ្លាប់កាន់មុខដំណែងជាមេឃុំកាលពីមុនបោះឆ្នោតក្រុមប្រឹក្សាឃុំ/សង្កាត់ ។

## រដ្ឋបាលឃុំ

*ការប្រែប្រួលចាប់តាំងពីការបង្កើតក្រុមប្រឹក្សាឃុំ*

តាមទស្សនៈរបស់សមាជិកក្រុមប្រឹក្សាឃុំក្រាំងលាវ ការប្រែប្រួលនៅក្នុងរដ្ឋបាលឃុំចាប់តាំងពីការបង្កើតក្រុមប្រឹក្សាមកគឺមានច្រើន ។ នៅមុនពេលបោះឆ្នោតនៅខែកុម្ភៈ ឆ្នាំ ២០០២ មេឃុំនិងរដ្ឋអំណាចឃុំដទៃទៀតត្រូវបានតែងតាំងដោយរដ្ឋ ហើយធ្វើជាតំណាងអោយផលប្រយោជន៍របស់គណបក្សប្រជាជនដែលជាគណបក្សមានសំលេងភាគច្រើន ។ ទំនាក់ទំនងរវាងថ្នាក់ដឹកនាំឃុំ និងមន្ត្រីនៅថ្នាក់លើគឺមានលក្ខណៈជាការបង្គាប់បញ្ជាពីលើចុះមកក្រោម ។ ឧទាហរណ៍ បើសិនជាមានបញ្ហាអ្វីកើតមានឡើងនៅក្នុងឃុំ ដូចជាទឹកជំនន់ ឬមានអគ្គិភ័យ រដ្ឋអំណាចឃុំរាយការណ៍ទៅថ្នាក់កណ្តាល (ថ្នាក់លើ) ដើម្បីសុំការដោះស្រាយ ។ មន្ត្រីថ្នាក់លើធ្វើការសំរេចចិត្តរួចហើយអោយថ្នាក់ដឹកនាំឃុំ និងភូមិអនុវត្តន៍តាម ។ មានតែថ្នាក់ដឹកនាំឃុំ២ ឬ៣នាក់ប៉ុណ្ណោះដែលបានចូលរួមក្នុងដំណើរការធ្វើផែនការ ហើយគ្មាននរណាម្នាក់បញ្ចេញយោបល់ទៅលើផែនការដែលបានទទួលពីថ្នាក់លើទេ ។

សមាជិកក្រុមប្រឹក្សាឃុំបានប្រកាសថា យុទ្ធសាស្ត្រនៅពេលនេះគឺ ការធ្វើការងារពីក្រោមឡើងទៅលើច្រើនជាង ។ ឧទាហរណ៍ សមាជិកក្រុមប្រឹក្សាបានពិភាក្សារួមគ្នាលើបញ្ហានានា ហើយសំរេចធ្វើអ្វីៗដោយផ្អែកលើសេចក្តីត្រូវការរបស់ប្រជាជន ។ នៅពេលគេសំរេចហើយ សមាជិកក្រុមប្រឹក្សាឃុំ និងមេភូមិយកការសំរេចចិត្តនោះទៅអនុវត្តន៍ ។ ដោយធ្វើតាមរបៀបនេះ ក្រុមប្រឹក្សាឃុំលើកហេតុផលថា គេអាចឆ្លើយតបបានទៅនឹងបញ្ហាបានច្រើន ហើយថែមទាំងបានឆាប់រហ័សទៀត ពីព្រោះក្រុមប្រឹក្សាមិនចាំបាច់ទៅឆ្លងដល់ថ្នាក់ណាទេ ។ ពិតមែនតែសមាជិកក្រុមប្រឹក្សាឃុំមានការងារធ្វើច្រើនជាងនៅក្នុងរដ្ឋបាលមុនៗក្តី តែក្រុមប្រឹក្សាក៏មានសមាជិកច្រើនហើយអាចបែងចែកការងារទទួលខុសត្រូវនៅក្នុងចំណោមសមាជិកបានត្រឹមត្រូវ ។ សមាជិកក្រុមប្រឹក្សាឃុំរៀនសូត្រតាមរយៈការអនុវត្តន៍ជាក់ស្តែង ហើយមានការពេញចិត្តនឹងបំពេញភារកិច្ចរបស់ខ្លួនដែរ ។

ទាក់ទងនឹងការធ្វើផែនការអភិវឌ្ឍន៍ ក្រុមប្រឹក្សាឃុំបានធ្វើការប៉ាន់ប្រមាណតម្រូវការ ហើយបានកំណត់នូវអាទិភាពបញ្ហាសំខាន់ៗជាងគេ ។ សមាជិកក្រុមប្រឹក្សាបាននិយាយថា ប្រជាជនភាគច្រើនបានសំដែងនូវ

ការពេញចិត្តនឹងការងាររបស់គេ ពីព្រោះគេបានឃើញលទ្ធផលនៃការងារជាក់ស្តែង ។ តែទន្ទឹមនឹងនោះ ក៏មានប្រជាជនខ្លះ មិនសប្បាយចិត្ត ដោយសារគំរោងសាងសង់ផ្លូវថ្នល់បានប៉ះពាល់ដល់ដើមឈើ ឬដីរបស់គេ ។

តំណាងនៃក្រុមសង្គមស៊ីវិលដែលត្រូវបានសំភាសន៍នៅសាលាឃុំ ក៏បានគាំទ្រនូវការយល់ឃើញជាវិជ្ជមានរបស់សមាជិកក្រុមប្រឹក្សាឃុំទាក់ទងនឹងការប្រែប្រួលដែលបានកើតមានឡើងនោះដែរ ។ តំណាងទាំងនេះបានអះអាងថា ក្នុងរដ្ឋបាលមុន រដ្ឋអំណាចឃុំមានសមាជិកតិច ហើយមិនសូវសកម្មនឹងការងារទេ ។ ការសំរេចចិត្តរបស់គេគឺផ្អែកលើលក្ខណៈលំអៀងមកប្រយោជន៍ផ្ទាល់ខ្លួន ហើយបញ្ហាដែលកើតមាននៅតែមិនអាចដោះស្រាយចេញបាន ។ ដោយសារហេតុផលនេះ ទើបធ្វើអោយឃុំ មានការអភិវឌ្ឍន៍យឺត១ ។ ចាប់តាំងពីការបង្កើតក្រុមប្រឹក្សាឃុំមក មានប្រជាជនច្រើនបានចូលរួមនៅក្នុងការដឹកនាំឃុំ ។ មេឃុំ និងសមាជិកក្រុមប្រឹក្សាឃុំនៅពេលនេះមានភាពសកម្មណាស់ ។ សេចក្តីសំរេចចិត្តគឺផ្អែកលើទស្សនៈរបស់មនុស្សភាគច្រើន ហើយបញ្ហាត្រូវបានដោះស្រាយបានភ្លាម១ ។ ដោយសារមេឃុំមានទំនាក់ទំនងល្អជាមួយនឹងស្ថាប័នអភិវឌ្ឍន៍ពីក្រៅនោះ ក្រុមប្រឹក្សាឃុំ បានទទួលថវិកាដើម្បីយកទៅចាយនៅក្នុងគំរោងអភិវឌ្ឍន៍ជាច្រើន ។ ដូច្នេះ ឃុំមានការរីកចំរើនបានឆាប់រហ័ស ។

*ការប្រជុំ*

ហេតុផលមួយក្នុងចំណោមហេតុផលជាច្រើន ដែលក្រុមប្រឹក្សាឃុំអាចសំរេចបាននូវដំណើរទៅមុខល្អនៅក្នុងឃុំក្រាំងលាវគឺ មានការប្រជុំប្រចាំខែទៀងទាត់ជាមួយនឹងសមាជិកទាំងអស់ចូលរួម ។ ការធ្វើដូច្នេះ ធ្វើអោយគេដោះស្រាយបញ្ហាបានទាន់ពេលវេលា ហើយទស្សនៈផ្សេង១ត្រូវបានលើកយកមកពិភាក្សា និងផ្លាស់ប្តូរយោបល់គ្នាទៅវិញទៅមក ។ នៅទីបំផុត រាល់ការខ្វែងគំនិតគ្នា ត្រូវបានសំរបសំរួលដោយមេឃុំ បន្ទាប់មកបានដាក់ចេញនូវការសំរេចចិត្តជាចុងក្រោយ ។ ក្រៅពីការប្រជុំទៀងទាត់ប្រចាំខែ ក្រុមប្រឹក្សាឃុំក៏បានរៀបចំការប្រជុំក្រៅផ្លូវការដើម្បីដោះស្រាយបញ្ហាជាក់ស្តែងដែលកើតឡើង ។ នៅក្នុងពេលប្រជុំក្រៅផ្លូវការនេះ ក្រុមប្រឹក្សាឃុំក៏បានអញ្ជើញអង្គការ ឬស្ថាប័នដែលពាក់ព័ន្ធអោយមកចូលរួមដែរ ។ ឧទាហរណ៍ បើមានការពិភាក្សាអំពីបញ្ហាសន្តិសុខនៅមូលដ្ឋាន ក្រុមប្រឹក្សាឃុំនឹងអញ្ជើញប្រធានប៉ុស្តិ៍អោយមកចូលរួម ។ តែបើមានពិភាក្សាអំពីបញ្ហាសុខភាពវិញនោះ ក្រុមប្រឹក្សាឃុំនឹងអញ្ជើញបុគ្គលិកមណ្ឌលសុខភាពអោយមកចូលរួមដែរ ។ ក្រុមប្រឹក្សាឃុំកត់ត្រាទុកនូវអ្វីដែលបានពិភាក្សានៅក្នុងអង្គប្រជុំ ហើយប្រកាសថានឹងធ្វើការផ្សព្វផ្សាយពតិមានអោយដល់ប្រជាជននៅក្នុងឃុំបានដឹង ។ ស្មៀនឃុំបាននិយាយថា ក្រុមប្រឹក្សាឃុំបានចេញដីការចំនួន៧មកហើយ តែខ្លឹមសារនៃដីការទាំងនោះមិនបានឃើញច្បាស់ទេ ។

*ទំនាក់ទំនងក្នុងការងារ*

យោងទៅតាមការសំភាសន៍ក្រុមប្រឹក្សាឃុំ សមាជិកមិនបានជួបប្រទះបញ្ហាធំៗនៅក្នុងការធ្វើការជាមួយគ្នាទេ ទោះបីជាមានពេលខ្លះគេមានទស្សនៈផ្ទុយគ្នាក្តី ។ មេឃុំមានតួនាទីសំខាន់នៅក្នុងការសំរួលការខ្វែងមតិគ្នា ហើយធ្វើអោយសមាជិកត្រូវគ្នា ។ នៅពេលដែលត្រូវបានសំភាសន៍ដោយឡែកពីគ្នា សមាជិកក្រុមប្រឹក្សាឃុំម្នាក់ដែលមកពីគណបក្សហ៊្វុនស៊ិនប៉ិចបាននិយាយថា គាត់បានជួបការពិបាកខ្លះ ដោយសារគាត់មានតែម្នាក់ឯងនៅក្នុងចំណោមសមាជិកដែលសុទ្ធតែមកពីគណបក្សប្រជាជន ។ នៅក្នុងករណីតិចតួចប៉ុណ្ណោះ ដែលសមាជិកក្រុមប្រឹក្សាឃុំយល់ស្របជាមួយនឹងគាត់ តែក្នុងករណីឯទៀតជាច្រើន ពួកគេមិនយល់ស្របតាមគាត់ទេ ។ ទោះជាយ៉ាងណាក្តី គាត់មើលឃើញនូវភាពខុសគ្នាធំមួយនៅក្នុងការគ្រប់គ្រងរដ្ឋបាលឃុំពីពេលមុន និងក្រោយការបោះឆ្នោតក្រុមប្រឹក្សាឃុំរួចមក ។ គាត់បាននិយាយថា ឥឡូវនេះ ប្រជាជនហ៊ានឡើងនិយាយ និងទាមទារចំពោះរដ្ឋអំណាចឃុំ ។ ពីមុនគេមិនអាចធ្វើយ៉ាងនេះបានទេ ពីព្រោះមេឃុំត្រូវបានតែងតាំងដោយមន្ត្រីថ្នាក់លើនៅក្នុងរាជរដ្ឋាភិបាល ។ ឥឡូវនេះ ដោយសារប្រជាជនបានបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ គេអាចទាមទារអោយមានការទទួលខុសត្រូវកាន់តែច្រើន ។ ក្នុងពេលជាមួយគ្នានោះដែរ សមាជិកក្រុមប្រឹក្សាដែលមកពីគណបក្សហ៊្វុនស៊ិនប៉ិចបានសរសើរពីការប្តេជ្ញាចិត្តរបស់មេឃុំ ហើយនិងការគាំទ្រដែលមានលក្ខណៈត្រឹមត្រូវនៃកម្មវិធីសីលា ។ គាត់បានកត់សំគាល់ថា ទោះបីជាអំណោយខ្លះរបស់រដ្ឋាភិបាលបានដល់អ្នកមាន ហើយនិងសមាជិកគណបក្សប្រជាជនក្តី តែនៅក្នុងកម្មវិធីសីលា មិនមានករណីដូចនេះទេ ។

បុគ្គលិកអង្គការទស្សនៈពិភពលោកបានយល់ព្រមថា ក្រុមប្រឹក្សាឃុំនៅក្រាំងលាវបានធ្វើការសំរេចចិត្តដែលស្របទៅតាមទស្សនៈរបស់សមាជិកក្រុមប្រឹក្សាឃុំភាគច្រើន និងមិនមែនជាទស្សនៈផ្ទាល់ខ្លួនរបស់មេឃុំដែលធ្វើតាមការបញ្ជាពីថ្នាក់លើទេ ។ តែបុគ្គលិកអង្គការនេះបានគូសបញ្ជាក់ថា សមាជិកក្រុមប្រឹក្សាមកពីគណបក្សប្រជាជនច្រើនតែធ្វើតាមគ្នាក្នុងការសំរេចចិត្ត ។ ដូច្នេះ សមាជិកដែលមកពីគណបក្សហ៊្វុនស៊ិនប៉ិច មិនអាចទាមទារអ្វីប្រឆាំងទៅនឹងគោលជំហររបស់សមាជិកមកពីគណបក្សប្រជាជនទេ ។ ទោះបីជាមានការបើកចំហឡើងនូវដំណើរការសំរេចចិត្តនៅក្រោមរដ្ឋបាលថ្មីនេះក្តី តែមេឃុំនៅក្រាំងលាវមកពីគណបក្សដែលមានសំលេងភាគច្រើន នៅតែមានឥទ្ធិពលច្រើនលើលទ្ធផលនៃការសំរេចចិត្ត ។ ទោះជាយ៉ាងណាក្តី បុគ្គលិករបស់អង្គការទស្សនៈពិភពលោកបានអះអាងថា ការមានតំណាងច្រើននៅក្នុងក្រុមប្រឹក្សាឃុំជួយបង្កើតទំនាក់ទំនងរឹងមាំជាមួយនឹងប្រជាជន ហេតុនេះហើយបានជារដ្ឋអំណាចឃុំដឹងពីអ្វីៗដែលកំពុងតែកើតមានឡើង ។

*ទស្សនៈរបស់ប្រជាជននៅតាមភូមិ*

ដើម្បីយល់បានច្បាស់ពីទស្សនៈរបស់អ្នកភូមិ ក្រុមអ្នកស្រាវជ្រាវបានសំភាសន៍ជាមួយនឹងប្រជាជននៅក្នុងភូមិចំនួនបីរបស់ឃុំដែលស្ថិតនៅឆ្ងាយពីគ្នា គឺភូមិក្រាំងលាវ ទួលស្វែង និងព្រហ៊ូត ។

សមាជិកក្រុមប្រឹក្សាឃុំពីរនាក់រស់នៅក្នុងភូមិក្រាំងលាវ ។ តាមធម្មតា ប្រជាជនមិនមានការពិបាកក្នុងការប្រាស្រ័យជាមួយនឹងសមាជិកក្រុមប្រឹក្សាឃុំទេ ហើយសមាជិកទាំងនេះបានឆ្លើយតបនឹងសំណើរសុំនានាដូចជា សុំពូជស្រូវ និងជី ។ ប្រការសំខាន់គឺ សមាជិកក្រុមប្រឹក្សាឃុំបានបំពេញនូវក្តីសង្ឃឹមរបស់ប្រជាជន ដោយចូលរួមនៅក្នុងបុណ្យខ្មោច និងពិធីបុណ្យដទៃទៀត ។ អ្នកភូមិក្រាំងលាវចាត់ទុករដ្ឋអំណាចឃុំនៅក្នុងពេលអតីតកាល ថាខិតខំធ្វើការងារច្រើន ហើយឥឡូវនេះ សមាជិកក្រុមប្រឹក្សាឃុំក៏ខិតខំធ្វើការដូចគ្នាដែរ។ ចំណុចខុសគ្នាគឺនៅត្រង់ថាក្រុមប្រឹក្សាឃុំមានសមាជិកច្រើនជាងមុន ។ រាល់ខែ ក្រុមប្រឹក្សាអញ្ជើញមេភូមិក្រាំងលាវអោយមកប្រជុំទៀងទាត់ ហើយបើមានការពិភាក្សាលើការងារអភិវឌ្ឍន៍ គណៈកម្មការអភិវឌ្ឍន៍ភូមិ ក៏ត្រូវបានអញ្ជើញអោយចូលរួមដែរ ។ សមាជិកក្រុមប្រឹក្សាឃុំ ពិសេសមេឃុំ បានទាក់ទងជាមួយនឹងអង្គការអភិវឌ្ឍន៍ផ្សេងៗ ដើម្បីរិះរកមធ្យោបាយជួយអភិវឌ្ឍន៍នៅក្នុងឃុំ ។

ប្រជាជននៅភូមិទួលស្លែងអាចរាប់ឈ្មោះសមាជិកក្រុមប្រឹក្សាឃុំបានតែពីរបីនាក់ប៉ុណ្ណោះ ។ ទោះជាយ៉ាងនេះក្តី គេសរសើរទំលាប់របស់សមាជិកក្រុមប្រឹក្សា ពិសេសមេឃុំដែលមកចូលរួមនៅក្នុងពិធីមង្គលការ និងពិធីផ្សេងៗទៀតនៅក្នុងភូមិ ហើយផ្តល់អង្ករដល់អ្នកក្រនៅក្នុងពេលខ្វះខាត ។ មេឃុំដែលជាប់ឆ្នោតនៅពេលនេះ គឺធ្លាប់ជាមេឃុំមុនពេលបោះឆ្នោតក្រុមប្រឹក្សាឃុំដែរ ហើយគាត់បានរក្សានូវប្រជាប្រិយភាពបានល្អ តាំងពីដើមមក។ ប្រជាជននៅភូមិនេះបាននិយាយថា គាត់ជាមនុស្សងាយស្រួលប្រាស្រ័យទាក់ទង ហើយនិងមានភាពស្រស់ស្រាយ រាក់ទាក់ជាមួយនឹងប្រជាជន ។ គេនិយាយថា គាត់មានប្រាជ្ញា មានទំនាក់ទំនងល្អជាមួយនឹងប្រជាជន និងជួយការពារសន្តិសុខបានល្អនៅក្នុងភូមិទៀតផង ។

ប្រជាជននៅភូមិព្រហ៊ូតបាននិយាយថា មេឃុំចុះមើលតាមភូមិទៀងទាត់ និងចូលរួមក្នុងពិធីមង្គលការ បុណ្យខ្មោច និងពិធីឯទៀតៗ ។ មេឃុំគិតគូរពីសេចក្តីត្រូវការរបស់ប្រជាជនដោយប្រមែប្រមូលធនធានពីអង្គការមិនមែនរដ្ឋាភិបាល និងស្ថាប័នឯទៀតៗដើម្បីកសាងផ្លូវថ្នល់ និងជីកអណ្តូង ។ ប្រជាជននៅក្នុងភូមិបានដំណាលថា នៅមុនពេលបោះឆ្នោត មេឃុំធ្លាប់តែធ្វើការសំរេចអ្វីៗតែម្នាក់ឯង តែឥឡូវនេះក្រុមប្រឹក្សាឃុំសំរេចចិត្តដោយយកមតិភាគច្រើនរបស់សមាជិក ។ ប្រជាជនគិតថា ក្រុមប្រឹក្សាឃុំមានការយកចិត្តទុកដាក់ចំពោះការងាររបស់ខ្លួន តែបានបង្ហាញអោយឃើញថា បើគ្មានការជួយពីកម្មវិធីសីលា និងអង្គការមិនមែនរដ្ឋាភិបាលទេនោះ គេក៏មិនអាចសំរេចបានអ្វីៗច្រើនដែរ ។

## ការរៀបចំនិងអនុវត្តន៍ផែនការ

*ដំណើរការធ្វើផែនការ*

ទាក់ទងនឹងការធ្វើផែនការនៃការអភិវឌ្ឍន៍ ក្រុមប្រឹក្សាឃុំបានរាយការណ៍ថា គេបានធ្វើការប៉ាន់ប្រមាណតម្រូវការនៅតាមភូមិនីមួយៗដើម្បីកំណត់នូវតម្រូវការអាទិភាពរបស់ភូមិនីមួយៗ ។ ការងារនេះអាចសំរេចទៅបាន ដោយមានការជួយជ្រោមជ្រែងពីបុគ្គលិកសីលាដែលបានផ្តល់ការបណ្តុះបណ្តាលក្នុងការធ្វើផែនការ និងរៀបចំថវិកា ។ យោងតាមច្បាប់ គណៈកម្មការរៀបចំផែនការ និងថវិកាឃុំ ត្រូវបានបង្កើតឡើងដោយមានសមាសភាពមកពីសមាជិកក្រុមប្រឹក្សាឃុំ មេភូមិ និងសមាជិកគណៈកម្មការអភិវឌ្ឍន៍ភូមិ ។ នៅថ្នាក់ឃុំ បុគ្គលិកសីលាបានផ្តល់ជំនួយដល់គណៈកម្មការនេះក្នុងការកំណត់តម្រូវការអាទិភាព និងបូកសរុបតម្រូវការរួមរបស់ឃុំដោយផ្អែកលើតម្រូវការដោយឡែកៗរបស់ភូមិ ។ ឯកសារបូកសរុប ត្រូវបានសរសេរទៅជាផែនការអភិវឌ្ឍន៍រយៈពេល៥ឆ្នាំរបស់ឃុំ ។

តំណាងរបស់សង្គមស៊ីវិលដែលត្រូវបានសំភាសន៍នៅសាលាឃុំបានអះអាងថា ការប៉ាន់ប្រមាណតម្រូវការអាចធ្វើបាន ដោយមានការចូលរួមយ៉ាងសំខាន់ពីសំណាក់មេភូមិ និងគណៈកម្មការអភិវឌ្ឍន៍ភូមិ។ មេភូមិបានបញ្ជូនលទ្ធផលនៃការប៉ាន់ប្រមាណតម្រូវការទៅអោយក្រុមប្រឹក្សាឃុំដើម្បីយកទៅបូកសរុប និងបញ្ចូលទៅក្នុងផែនការឃុំ៥ឆ្នាំ ។ តម្រូវការដែលអ្នកភូមិបានលើកឡើងរួមមានបង្កន់ អណ្តូងទឹក ប្រឡាយទឹក ប្រព័ន្ធធារាសាស្ត្រ ស្ពាន ផ្ទះ សាលារៀន ដើមឈើហូបផ្លែ និង ទ្រុងជ្រូក ។ នៅពេលដែលក្រុមប្រឹក្សាឃុំបានកំណត់ពីអាទិភាពនៃតម្រូវការរបស់ឃុំសំរាប់យកទៅអនុវត្តន៍រួចហើយ មេភូមិ និងគណៈកម្មការអភិវឌ្ឍន៍ភូមិផ្សព្វផ្សាយផែនការនេះបន្តទៅដល់អ្នកភូមិឱ្យបានយល់ដឹង ។

បុគ្គលិករបស់អង្គការទស្សនៈពិភពលោកបានប៉ាន់ប្រមាណថា ពី ៦៥% ទៅ ៧០%នៃប្រជាជននៅក្នុងភូមិរបស់ឃុំនេះបានចូលរួមនៅក្នុងដំណើរការធ្វើផែនការ ។ បុគ្គលិករបស់សីលាបានជួយនៅក្នុងដំណើរការធ្វើផែនការ និងបានពិភាក្សាលើតម្រូវការដោយឡែកពីគ្នារវាងបុរស និងនារី ។ គណៈកម្មការរៀបចំផែនការ និងថវិកាត្រូវបានបង្កើតឡើងនៅឃុំក្រាំងលាវ ដោយមានមេភូមិជាច្រើនដែលជាអ្នកមានតួនាទីសំខាន់ក្នុងការដឹកនាំ ។ បុគ្គលិករបស់អង្គការទស្សនៈពិភពលោកបាននិយាយថា តាមធម្មតាប្រជាជនទទួលយកផែនការ៥ឆ្នាំ និងផែនការប្រចាំឆ្នាំដោយមានការកែប្រែតិចតួច ។ កម្មវិធីសីលាបានអនុម័តជាចុងក្រោយទៅលើផែនការស្របទៅតាមទំរង់បែបបទដែលត្រូវបានកំណត់ ។ ដំណើរការទាំងមូល ត្រូវការពេលវេលាមួយសប្តាហ៍ ។ បន្ទាប់មក ក្រុមប្រឹក្សាឃុំបានធ្វើឧទ្ទេសនាមផែនការនេះនៅឯសិក្ខាសាលាសមាហរណកម្មថ្នាក់ស្រុកប្រចាំឆ្នាំ ។ អង្គការទស្សនៈពិភពលោកបានយល់ព្រមផ្តល់ថវិកាដល់គំរោងទាំងឡាយណាដែលស្របទៅតាមសកម្មភាពការងារប្រចាំឆ្នាំរបស់ខ្លួន ។

សមាជិកក្រុមប្រឹក្សាឃុំ តំណាងសង្គមស៊ីវិល បុគ្គលិករបស់អង្គការទស្សនៈពិភពលោកដែលត្រូវបានសំភាសន៏ជាមួយ មានយោបល់ច្រើន ហើយជាទូទៅមានការយល់ឃើញដូចគ្នាចំពោះដំណើរការធ្វើផែនការ តែការសំភាសន៏ជាមួយនឹងប្រជាជនវិញបានបង្ហាញថា ពួកគេមានការយល់ឃើញប្លែកៗពីគ្នាទៅលើដំណើរការ និងការចូលរួមរបស់គេនៅក្នុងដំណើរការនោះ ។ នៅក្រាំងលាវ មានប្រជាជនខ្លះបានបង្ហាញពីការយល់ច្រឡំអំពីដំណើរការនៃធ្វើផែនការឃុំ ។ គេបានចូលរួមប្រជុំជាមួយនឹងមេភូមិ គណៈកម្មការអភិវឌ្ឍន៏ភូមិ ព្រមទាំងអង្គការមិនមែនរដ្ឋាភិបាល និងស្ថាប័នអភិវឌ្ឍន៏ផ្សេងៗ តែនៅមិនច្បាស់ថា ការចូលរួមរបស់ពួកគេនោះបានឈានទៅដល់ការដាក់ចេញនូវផែនការ៥ឆ្នាំសំរាប់ឃុំ ឬគំរោងដទៃទៀតនោះទេ ។ ប្រជាជនខ្លះនៅក្រាំងលាវបាននិយាយថា ពួកគេត្រូវបានអញ្ជើញអោយទៅប្រជុំជាមួយនឹងក្រុមប្រឹក្សាឃុំដើម្បីពិភាក្សាពីគំរោងអភិវឌ្ឍន៏ដូចជាការកសាងសាលារៀន និងការចែកចាយជី តែគេបាននិយាយថា គេមិនដឹងពីសកម្មភាពនៃធ្វើផែនការទេ ។

ប្រជាជនមួយក្រុមដែលត្រូវសំភាសន៏ជាមួយនៅភូមិទួលស្វែងបាននិយាយថា គេក៏មិនបានដឹងពីសកម្មភាពធ្វើផែនការដែរ ។ គេចាំបានថា មេភូមិបានប្រាប់គេពីផែនការឃុំ តែមិនចាំចំណុចលំអិតនៅក្នុងផែនការនោះទេ ។

នៅក្នុងភូមិព្រហ៊ូត ប្រជាជនជាច្រើនក្រុមដែលត្រូវបានសំភាសន៏បានដឹងច្រើនពីសកម្មភាពធ្វើផែនការ ។ នៅក្នុងបទសំភាសន៏ដោយឡែក មានពីរក្រុមបានប្រកាសថា គេបានចូលរួមនៅក្នុងការប្រជុំធ្វើផែនការភូមិដើម្បីពិភាក្សាពីតម្រូវការរបស់ប្រជាជន ។ គេបាននិយាយថាមានមនុស្សច្រើនចូលរួមនៅក្នុងការប្រជុំនោះ ហើយត្រូវបានគេសួរអោយលើកឡើង និងកំណត់រកតម្រូវការអាទិភាពរបស់គេ ។ នៅភូមិព្រហ៊ូត សេចក្តីត្រូវការដែលប្រជាជនបានលើកឡើងរួមមាន ផ្លូវថ្នល់ អណ្តូងទឹក ផ្ទះសំរាប់អ្នកក្រ បង្គន់ និងគោ ។ សេចក្តីត្រូវការទាំងនេះត្រូវបានដាក់ជូនទៅក្រុមប្រឹក្សាឃុំ តាមរយៈមេភូមិ និងគណៈកម្មការអភិវឌ្ឍន៏ភូមិ ។ ក្រោយមក មេភូមិ ហើយនិងគណៈកម្មការអភិវឌ្ឍន៏ភូមបានរាយការណ៏មកប្រជាជនវិញ អំពីអ្វីដែលត្រូវបានដាក់បញ្ចូលទៅក្នុងផែនការឃុំ ។

*ការអនុវត្តន៏ការងារ*

នៅក្នុងឆ្នាំ ២០០២ និង ២០០៣ ក្រុមប្រឹក្សាឃុំក្រាំងលាវបានដំណើរការដោយជោគជ័យលើគំរោងដែលមានកំណត់នៅក្នុងផែនការ៥ឆ្នាំរបស់ឃុំ ។ ក្រុមប្រឹក្សាឃុំបានសាងសង់សាលារៀនមួយនៅក្នុងឆ្នាំ ២០០២ ហើយសាងសង់បានបីទៀតក្នុងឆ្នាំ ២០០៣ ។ ក្រុមប្រឹក្សាឃុំថែមទាំងបានជួសជុលផ្លូវមួយដែលមានប្រវែង ៦,២គម ពីភូមិរុងទៅភូមិពញ្ញាគោកដែលតែងតែទទួលរងទឹកជំនន់នារដូវវស្សា ។ ក្រៅពីនេះ ក្រុមប្រឹក្សាឃុំបានធ្វើការជាមួយនឹងអង្គការទស្សនៈពិភពលោកដើម្បីជួសជុលផ្លូវលំមួយដែលមានប្រវែង៤គម ពីភូមិឈើទាលជ្រុំទៅកាន់ភូមិត្បែ ។ គំរោងធំមួយទៀតរបស់ក្រុមប្រឹក្សាឃុំគឺ ជួសជុលជាបន្តលើអាងស្តុកទឹកទំនប់ថ្នល់ដាច់ ដោយមានជំនួយពីមន្ទីរ

ធនធានទឹក និងអង្គការស្ពានកម្ពុជា-ហុល្លងដ៍ ។ បន្ថែមពីលើនេះទៀត ក្រុមប្រឹក្សាបានធ្វើអណ្តូងទឹក និងបង្គន់។ ក្រុមប្រឹក្សាឃុំមិនបានបែងចែកថវិកាសំរាប់គំរោងទាំងនេះដោយខ្លួនឯងទេ តែបានម៉ៅការអោយទៅក្រុមហ៊ុនឯកជន តាមរយៈការដេញថ្លៃ ។ ក្រុមហ៊ុនដែលដេញថ្លៃបានហើយត្រូវអនុវត្តន៍គំរោង ត្រូវបានទូទាត់លុយតាមរយៈរតនគារខេត្ត ។

នៅពេលដំណើរការគំរោងហេដ្ឋារចនាសម្ព័ន្ធ ក្រុមប្រឹក្សាឃុំទាមទារអោយអ្នកភូមិរួមវិភាគទានចំនួន ១០%នៃតម្លៃសរុបរបស់គំរោង ។ តាមធម្មតា ៧%ត្រូវគិតជាពលកម្ម និង៣%ទៀតគិតជាសាច់ប្រាក់ ។ ទោះបីជាប្រជាជនជនចង់បង់ទាំង ១០% ជាសាច់ប្រាក់ក្តី នៅឃុំក្រាំងលាវ ក្រុមប្រឹក្សាឃុំមានការពិបាកក្នុងការប្រមូលវិភាគទានពីប្រជាជនសំរាប់គំរោងដូចជា សាងសង់សាលារៀនជាដើម ។ ក្រុមប្រឹក្សាឃុំ និងបុគ្គលិកសីលាបានទទួលខុសត្រូវក្នុងការតាមដានលើការអនុវត្តន៍គំរោង។ នៅក្នុងភូមិព្រហ៊ូត ប្រជាជនបាននិយាយថា គេបានរួមចំណែកជាកំលាំងពលកម្ម លុយ និងសំភារៈសំរាប់គំរោងដូចជា ផ្លូវថ្នល់ អណ្តូងទឹក និងបង្គន់ ។ នៅក្នុងភូមិក្រាំងលាវ មេភូមិបាននិយាយថា រដ្ឋាភិបាលផ្តល់សំភារៈសំរាប់គំរោងហើយ ដូច្នេះប្រជាជនជួយជាកំលាំងពលកម្ម។

## ភាពជាដៃគូជាមួយនឹងសង្គមស៊ីវិល

*ទំនាក់ទំនងជាមួយនឹងអង្គការប្រជាជននានានៅតាមភូមិ*

នៅក្រាំងលាវ ក្រុមប្រឹក្សាឃុំច្រើនធ្វើការតាមរយៈមេភូមិដូចដែលរដ្ឋអំណាចឃុំនៅក្នុងពេលកន្លងមកបានធ្វើដែរ ។ ជាផ្នែកមួយនៃរចនាសម្ព័ន្ធរបស់រដ្ឋ មេភូមិដែលត្រូវបានតែងតាំងឡើងនោះ មិនមែនជាផ្នែកមួយនៃសង្គមស៊ីវិលទេ។ ក្នុងពេលជាមួយគ្នានោះដែរ ក្រុមប្រឹក្សាឃុំក្រាំងលាវពឹងផ្អែកខ្លាំងលើគណៈកម្មការអភិវឌ្ឍន៍ភូមិដើម្បីជួយធ្វើផែនការ និងសំរបសំរួលការងារអភិវឌ្ឍន៍ ។ គណៈកម្មការអភិវឌ្ឍន៍ភូមិដែលត្រូវបានបោះឆ្នោតជ្រើសឡើងហើយមានលក្ខណៈឯករាជ្យដាច់ចេញពីរដ្ឋ តែជាផ្នែកមួយនៃសង្គមស៊ីវិលដែរនោះ មានការយកចិត្តទុកដាក់ក្នុងការធ្វើការងារជាមួយនឹងក្រុមប្រឹក្សាឃុំ ។ មូលហេតុដែលគេបានសហការបានល្អគឺ ប្រហែលដោយសារថា គណៈកម្មការអភិវឌ្ឍន៍ភូមិ ត្រូវបានបង្កើតឡើងនៅក្រោមកម្មវិធីសីលា ទើបពួកគេត្រូវយកចិត្តទុកដាក់ជួយដល់សកម្មភាពរបស់សីលា ។ បើសិនគណៈកម្មការអភិវឌ្ឍន៍ភូមិ ត្រូវបានបង្កើតឡើងដោយអង្គការមិនមែនរដ្ឋាភិបាលដែលមានកម្មវិធីអភិវឌ្ឍន៍មួយសំរាប់អោយគណៈកម្មការអនុវត្តន៍ដែរនោះ ប្រហែលគណៈកម្មការអភិវឌ្ឍន៍ភូមិមិនសូវជាយកចិត្តទុកដាក់ខ្លាំងដូចដែលកម្មវិធីសីលារៀបចំបង្កើតឡើងនោះទេ ។

*ទំនាក់ទំនងជាមួយនឹងអង្គការមិនមែនរដ្ឋាភិបាល*

ហេតុផលមួយដែលក្រុមប្រឹក្សាឃុំសំរេចបានសមិទ្ធិផលច្រើនក្នុងរយៈពេលខ្លីនេះគឺ ដោយសារបានទទួលជំនួយពីអង្គការមិនមែនរដ្ឋាភិបាល និងស្ថាប័នអភិវឌ្ឍន៍ផ្សេងៗ ។ អង្គការទាំងនេះរួមមានៈ អង្គការទស្សនៈពិភពលោកដែលជួយក្នុងផ្នែកកសិកម្ម អប់រំ និងកសាងផ្លូវថ្នល់ ចំពោះអង្គការ CEDAC ជួយនៅក្នុងផ្នែកកសិកម្ម អង្គការ RACHA ជួយផ្នែកសុខភាព អង្គការ RDRP ជួយផ្នែកកសិកម្ម និងជីអង្គការស្ពានកម្ពុជា-ហុល្លងដ៏ ជួយផ្នែកអប់រំ និងការគ្រប់គ្រងទឹក អង្គការ HERKS ជួយផ្នែកកសិកម្ម និងទឹកស្អាត រីឯអង្គការកុមារ និងអភិវឌ្ឍន៍ជួយផ្នែកសុខាភិបាល ។ គំរោងខ្លះរបស់អង្គការទាំងនេះមិនត្រូវបានបញ្ចូលទៅក្នុងផែនការ៥ឆ្នាំរបស់ឃុំ ឬក៏ត្រូវបានដំណើរការទៅដោយក្រុមប្រឹក្សាឃុំទេ ។ ទោះជាយ៉ាងណាក្តី សមាជិកក្រុមប្រឹក្សាឃុំ ជាពិសេសមេឃុំបានខិតខំស្វែងរកជំនួយពីអង្គការផ្សេងៗ ដើម្បីអភិវឌ្ឍន៍។ គួរកត់សំគាល់ថា ប្រជាជននៅភូមិក្រាំងលាវ ទួលស្លែង និងព្រហ៊ូតបានទទួលស្គាល់ នូវការរួមចំណែករបស់អង្គការមិនមែនរដ្ឋាភិបាល ក្នុងការជួយក្រុមប្រឹក្សាឃុំអោយសំរេចបានការអភិវឌ្ឍន៍នៅក្នុងឃុំ ។

នៅក្នុងករណីភាគច្រើន ទំនាក់ទំនងរវាងក្រុមប្រឹក្សាឃុំ និងអង្គការមិនមែនរដ្ឋាភិបាលមានលក្ខណៈជាការសហការគ្នា ពោលគឺអង្គការមិនមែនរដ្ឋាភិបាល និងក្រុមប្រឹក្សាឃុំប្រាប់គ្នាពីសកម្មភាពនៅក្នុងផែនការរបស់គេ ហើយស្វែងរកមើលវិធីសំរបសំរួលការងារ ។ នៅក្នុងករណីខ្លះទៀត ការទំនាក់ទំនងគ្នាលេចចេញនូវភាពជាដៃគូថ្មីថ្មោង ព្រោះថាអង្គការមិនមែនរដ្ឋាភិបាល និងក្រុមប្រឹក្សាឃុំបានធ្វើការជាមួយគ្នាដើម្បីសំរេចគោលដៅរួម ។ អង្គការមិនមែនរដ្ឋាភិបាលដែលធ្វើការក្នុងឃុំក្រាំងលាវ បានបង្ហាញនូវឆន្ទៈរបស់គេក្នុងការជួយដល់សកម្មភាពដែលមាននៅក្នុងផែនការឃុំ ។ ការធ្វើដូច្នេះ បានជំរុញអោយគេមានទំនាក់ទំនងការងារកាន់តែជិតស្និទ្ធជាមួយនឹងក្រុមប្រឹក្សា ហើយបានបង្ហាញអោយឃើញថា អង្គការមិនមែនរដ្ឋាភិបាលងាកចេញពីកម្មវិធីអភិវឌ្ឍន៍មួយដែលដើរទន្ទឹមគ្នានឹងកម្មវិធីអភិវឌ្ឍន៍នានារបស់ឃុំ ។ នៅត្រង់ចំណុចនេះ សិក្ខាសាលាសមាហរណកម្មនៅថ្នាក់ស្រុកដែលមានធ្វើមួយឆ្នាំម្តង បានផ្តល់ដល់មេឃុំនូវឱកាសដើម្បីឧទ្ទេសនាមពីផែនការថ្មីប្រចាំឆ្នាំសំរាប់អោយអង្គការនានាបានឃើញ និងវិរៈរកមធ្យោបាយដើម្បីជួយគាំទ្រដល់ផែនការរបស់ឃុំនោះ ។

ចំពោះបុគ្គលិករបស់អង្គការទស្សនៈពិភពលោកវិញគិតថា សិក្ខាសាលាសមាហរណកម្មថ្នាក់ស្រុកដែលមានរយៈពេលមួយថ្ងៃ បានបង្ខំអោយអង្គការអភិវឌ្ឍន៍ទទួលយកគំរោងផ្សេងៗដែលបានលើកឡើងក្នុងរយៈពេលដ៏ខ្លី ។ គេគិតថា សិក្ខាសាលានោះមានប្រយោជន៍ច្រើន បើសិនជាក្រុមប្រឹក្សាធ្វើការចរចារពីដំបូងជាមួយនឹងម្ចាស់មូលនិធិណាមួយ ក្រោយពីដំណើរការធ្វើផែនការរួច ដើម្បីអោយដឹងថាគំរោងណាមួយដែលគេអាចទទួលយកបាន ។ អង្គការទស្សនៈពិភពលោក បានធ្វើការជាមួយនឹងក្រុមប្រឹក្សាលើគំរោងដូចជា អណ្តូងទឹក ផ្លូវថ្នល់ ប្រឡាយទឹក បង្គន់ និងការបណ្តុះបណ្តាលខាងកសិកម្ម ។ អង្គការនេះបានចុះកិច្ចព្រមព្រៀងជាមួយនឹង

ក្រុមប្រឹក្សាឃុំដើម្បីដំណើរការគំរោងបែបនេះ ។ គំរោងត្រូវបានដំណើរការដោយអង្គការទស្សនៈពិភពលោក គណៈកម្មការអភិវឌ្ឍន៏ភូមិ ព្រមទាំងប្រជាជន ហើយត្រូវបានតាមដានដោយក្រុមប្រឹក្សាឃុំយ៉ាងយកចិត្តទុកដាក់ ។

**ទំនាក់ទំនងជាមួយនឹងរាជរដ្ឋាភិបាល និងគណបក្សនយោបាយ**

ក្រុមប្រឹក្សាឃុំក្រាំងលាវដឹងច្បាស់ថា ក្រុមប្រឹក្សាត្រូវបានបង្កើតឡើងនៅក្រោមច្បាប់របស់រាជរដ្ឋាភិបាលកម្ពុជា ហើយពួកគេបានធ្វើតាមយ៉ាងខ្ជាប់ខ្ជួនលើមាគ៌ាដែលដាក់ចេញដោយក្រសួងមហាផ្ទៃ ។ ក្រុមប្រឹក្សាឃុំបានរាយការណ៍ពីលទ្ធផលនៃការប្រជុំរបស់គេទៅមន្ត្រីថ្នាក់ស្រុក និងខេត្តតាមរយៈស្មៀនឃុំ ។ រាល់ឆ្នាំនៅក្នុងខែតុលា សមាជិកក្រុមប្រឹក្សាចូលរួមនៅក្នុងសិក្ខាសាលាសមាហរណកម្មនៅថ្នាក់ស្រុក ។ មេឃុំមានទំនាក់ទំនងល្អជាមួយនឹងស្ថាប័នរដ្ឋ ហើយអាចទាក់ទាញអ្នកផ្តល់ជំនួយជាច្រើនអោយជួយដល់ផែនការឃុំដែលគេចង់បាន ។ ក្រុមប្រឹក្សាមានទំនាក់ទំនងដោយផ្ទាល់ជាមួយនឹងតំណាងរាស្ត្រនៅភ្នំពេញ ដែលកត្តានេះបានធ្វើអោយក្រុមប្រឹក្សាអាចទាក់ទងដោយផ្ទាល់ជាមួយនឹងស្ថាប័នថ្នាក់លើនៃរដ្ឋាភិបាលបាន ។

លោកអភិបាលស្រុកបាទីបានលើកឡើងថា ក្រុមប្រឹក្សានៅឃុំក្រាំងលាវមានការប្រជុំទៀងទាត់ម្តងក្នុងមួយខែ ។ គេអនុវត្តន៏បានល្អលើការងារដែលរដ្ឋប្រគល់អោយ ។ សមាជិករបស់ក្រុមប្រឹក្សានៅក្រាំងលាវមានការសហការគ្នាបានល្អ ហើយមានជំនាញគ្រប់គ្រងដើម្បីដឹកនាំឃុំរបស់គេ ។ ក្នុងចំណោមសមាជិកទាំង ៩នាក់ មាន៨នាក់មកពីគណបក្សប្រជាជន លើកលែងតែម្នាក់មកពីគណបក្សដទៃ ដូច្នេះការប្រជែងគ្នារវាងគណបក្សមួយទៅគណបក្សមួយទៀត មិនមានជាបញ្ហាចោទអ្វីទេ ។

**ឧបសម្ព័ន្ធ ២**

**ករណីសិក្សាទី ២**

## ឃុំចំប៉ី ស្រុកអង្គរជ័យ

## ខេត្តកំពត

## ជាឃុំដែលត្រូវបានជ្រើសរើស និងផ្តល់ជំនួយដោយអង្គការ GTZ

**ប្រវត្តិ**

ចំប៉ីគឺជាឃុំមួយក្នុងចំណោមឃុំទាំង១១នៅក្នុងស្រុកអង្គរជ័យ ខេត្តកំពត ។ ឃុំនេះមានភូមិចំនួន៨ ហើយមានប្រជាជនចំនួន១៧៦២គ្រួសារ ។ ប្រភពចំណូលសំខាន់គឺ ការធ្វើស្រែ និងការដាំដំណាំលក់ ។ សន្តិសុខស្បៀងគឺជាបញ្ហាសំខាន់នៅក្នុងឃុំ ដោយសារកសិករធ្វើស្រែខ្វះប្រព័ន្ធធារាសាស្ត្រ ហើយទិន្នផលស្រូវទាប ។ នៅក្នុងឆ្នាំ ២០០១ និង២០០២ ឃុំជួបប្រទះគ្រោះទឹកជំនន់ និងភាពរាំងស្ងួត។ បណ្តាញផ្លូវនៅក្នុងឃុំ ក៏ត្រូវការកែលំអរដែរ ។ អង្គការអភិវឌ្ឍន៍សំខាន់ៗដែលធ្វើការនៅក្នុងឃុំគឺ GTZ ហើយនិងអង្គការស្បៀងអាហារពិភពលោក។

GTZ បានចាប់ផ្តើមធ្វើការនៅក្នុងឃុំនៅក្នុងឆ្នាំ ១៩៩៦ នៅក្រោមកម្មវិធីចំរុះផ្នែកសន្តិសុខស្បៀង ។ កម្មវិធីនេះមានគំរោងចំនួន៥គឺ កសិកម្ម ឥណទានស្រូវ ហេដ្ឋារចនាសម្ព័ន្ធនៅក្នុងភូមិ សុខភាព និងការកែច្នៃអាហារធ្វើពីបន្លែក្នុងទ្រង់ទ្រាយតូច ។ GTZ បានជួយភូមិបង្កើតគណៈកម្មការអភិវឌ្ឍន៍ភូមិដែលមានតួនាទីអនុវត្តន៍ការងារ ក្រោមជំនួយពីអង្គការ GTZ ដូចជា ធនាគារស្រូវ ឥណទានសាច់ប្រាក់ និងសមាគមគុសំរាប់ជូលនៅពេលមានបុណ្យ ឬអាពាហ៍ពិពាហ៍ ។GTZ ក៏បានជួយគំរោងស្បៀងពលកម្មសំរាប់កែលំអរផ្លូវនៅក្នុងភូមិដែរ។ តាំងពីខែមេសា ឆ្នាំ ២០០២ មក GTZ បានបង្វែរការយកចិត្តទុកដាក់នៃកម្មវិធីរបស់ខ្លួន ទៅរកការងារអភិវឌ្ឍន៍សហគមន៍ និងវិមជ្ឈការ ។ កម្មវិធីនេះកសាងសមត្ថភាពរបស់មន្ត្រីថ្នាក់ស្រុក និងថ្នាក់ខេត្ត ដើម្បីជួយដល់ការធ្វើវិមជ្ឈការនៅកំរិតថ្នាក់ឃុំ ។

ក្រុមប្រឹក្សាឃុំចំប៉ីរួមមានសមាជិកចំនួន៦នាក់ដែលសុទ្ធតែជាបុរស ។ មេឃុំ និងសមាជិកក្រុមប្រឹក្សាបីនាក់ទៀតមកពីគណបក្សប្រជាជន ។ មានសមាជិកក្រុមប្រឹក្សាម្នាក់មកពីគណបក្សហ៊្វុនស៊ិនប៉ិច ហើយនិងម្នាក់ទៀត មកពីគណបក្សសមរង្ស៊ី។ (សមាជិកទី ៧ ដែលមកពីគណបក្សហ៊្វុនស៊ិនប៉ិចបានស្លាប់តាំងពីពេលបោះឆ្នោតម្ល៉េះ) ។ មេឃុំដែលបានជាប់ឆ្នោតមកនេះ គឺជាមេឃុំដែលត្រូវបានតែងតាំងពីឆ្នាំ ១៩៨០ រហូតមកទល់នឹងការបោះឆ្នោតខែកុម្ភៈ ឆ្នាំ ២០០២ ។

## វត្តបាឈាយ៉ុ

*ការប្រែប្រួលតាំងពីបានបង្កើតក្រុមប្រឹក្សាឃុំ*

ទោះបីជាក្រុមប្រឹក្សាឃុំបានបំពេញការងារមិនដល់២ឆ្នាំផង តែសមាជិកបានមើលឃើញការប្រែប្រួលគួរអោយកត់សំគាល់ ចាប់តាំងពីក្រុមប្រឹក្សាត្រូវបានបង្កើតឡើង ។ ពីមុន រដ្ឋអំណាចឃុំពឹងផ្អែកលើមន្ត្រីថ្នាក់លើអោយនាំផ្លូវ និងធ្វើផែនការ ។ ឥឡូវនេះ សមាជិកក្រុមប្រឹក្សាមានតួនាទីច្បាស់លាស់ ហើយអាចទទួលខុសត្រូវបានច្រើន ។ គេកត់សំគាល់ថា គេអាចដោះស្រាយបញ្ហារបស់ប្រជាជនដោយផ្ទាល់បានច្រើន ។ ដោយសារមានសមាជិកមកពីគណបក្សហ៊្វុនស៊ិនប៉ិច និងគណបក្សសមរង្ស៊ីនៅក្នុងជួរអ្នកដឹកនាំផងនោះ ទើបគេមើលឃើញថាជាការជួយបន្ថយលំអៀងដែលតែងតែងាកទៅរកសមាជិកដែលមកពីគណបក្សប្រជាជន ។

តំណាងនៃក្រុមសង្គមស៊ីវិលដែលត្រូវបានសំភាសន៍នៅសាលាឃុំបាននិយាយថា ក្រុមប្រឹក្សាឥឡូវនេះមានការទទួលខុសត្រូវច្រើនចំពោះអ្វីដែលកើតឡើងនៅតាមភូមិ ។ ពីមុន មេឃុំចាំតែផ្តល់ការយល់ព្រមចំពោះសំណើរដែលត្រូវបានដាក់ជូនពីមេភូមិប៉ុណ្ណោះ ។ ឥឡូវនេះ សមាជិកក្រុមប្រឹក្សាមានតួនាទីដោយផ្ទាល់នៅក្នុងការធានាថាសន្តិសុខត្រូវបានថែរក្សា ហើយធនធានធម្មជាតិត្រូវបានការពារ។ ការលួចគោក្របី និងការឆក់ត្រីត្រូវបានកាត់បន្ថយ។ មេឃុំលែងជាអ្នកសំរេចអ្វីៗទាំងអស់ហើយ ។ របៀបធ្វើការនៅពេលបច្ចុប្បន្នគឺមានលក្ខណៈចូលរួមដោយមានសមាជិកមកពីគណបក្សផ្សេងៗចូលរួមនៅក្នុងការធ្វើការសំរេចចិត្ត ។ អភិបាលស្រុកអង្គរជ័យបានកត់សំគាល់ឃើញថា ពីមុនមានតែមេឃុំទេដែលជាអ្នកមានអំណាច ។ ដំណើរការវិមជ្ឈការនៅពេលនេះ លើកទឹកចិត្តអោយមានការចូលរួមរបស់ប្រជាជន និងការសំរេចចិត្តរួមជាមួយនឹងតំណាងមកពីគណបក្សផ្សេងៗ ។

បុគ្គលិករបស់ GTZ បានគូសបញ្ជាក់ថា ពីមុនរដ្ឋអំណាចឃុំមិនបានទទួលការបណ្តុះបណ្តាលដើម្បីអោយខ្លួនគេអាចបំពេញការងារបានល្អទេ ។ ឥឡូវនេះ GTZ ហើយនិងក្រុមអ្នកសំរបសំរួលថ្នាក់ស្រុក និងថ្នាក់ខេត្តបានផ្តល់ការបណ្តុះបណ្តាលដល់ក្រុមប្រឹក្សាស្តីពីការតំរង់ទិស ការរៀបចំផែនការភូមិ ការរៀបចំគំរោង ការគ្រប់គ្រងហិរញ្ញវត្ថុ ការធ្វើផែនការលើការវិនិយោគ និងការរៀបចំដេញថ្លៃ ។ ដោយសារក្រុមប្រឹក្សាមានការទទួលខុសត្រូវកាន់តែច្រើនឡើង បុគ្គលិករបស់ GTZ គិតថា សមាជិកក្រុមប្រឹក្សានៅត្រូវការការបណ្តុះបណ្តាលបន្ថែមខាងការគ្រប់គ្រងរដ្ឋបាលឃុំ ការធ្វើផែនការ និងគ្រប់គ្រងហិរញ្ញវត្ថុ ការទុកដាក់ឯកសារ និងការប្រាស្រ័យទាក់ទងជាមួយនឹងប្រជាជន និងរដ្ឋអំណាចថ្នាក់លើ ។ អភិបាលស្រុកអង្គរជ័យបានគូសបញ្ជាក់ពីការខិតខំរបស់រាជរដ្ឋាភិបាលក្នុងការកសាងសមត្ថភាពរបស់សមាជិកក្រុមប្រឹក្សាខាងការគ្រប់គ្រងគំរោង ការធ្វើផែនការហិរញ្ញវត្ថុ និងគ្រប់គ្រងរដ្ឋបាល ។

*ការអនុវត្តន៍ការងារ*

ក្រុមប្រឹក្សាបាននិយាយថា ខ្លួនមានការប្រជុំទៀងទាត់ប្រចាំខែ ហើយនៅក្នុងអង្គប្រជុំនេះ សមាជិកអាចបន្ថែមរបៀបវារៈរបស់ខ្លួន ហើយសុំការដោះស្រាយចំពោះបញ្ហាតាមរយៈការពិភាក្សាគ្នា ។ សមាជិកក៏នៅមានការប្រជុំពិសេសផងដែរ នៅពេលមានចេញដីការ និងនៅពេលរៀបចំធ្វើផែនការ ។ ក្រុមប្រឹក្សាបញ្ជូនរបាយការណ៍ទៅសាលាស្រុកនិងក្រុមសំរបសំរួលថ្នាក់ស្រុក តែមិនបានអោយផ្តល់របាយការណ៍នេះដល់មជ្ឈដ្ឋានច្រើនទេ ។ តំណាងសង្គមស៊ីវិលនិយាយថា ត្រូវបង្កើនការទាក់ទង នឹងការចែករំលែកពត៌មានអោយបានច្រើនទៀតរវាងមន្ត្រីឃុំ និងប្រជាជននៅតាមភូមិ ។ បុគ្គលិកនៅថ្នាក់ស្រុករបស់ GTZ បាននិយាយថា ក្រុមប្រឹក្សាគួរតែចែករំលែកពត៌មានដល់ប្រជាជនអោយបានច្រើន ។ គេបានកត់សំគាល់ថា ឃើញមានតម្លាភាពកាន់តែច្រើន តែក៏នៅតែមានខ្វះចន្លោះខ្លះដែរ ។ ឧទាហរណ៍ មានតែមេឃុំ និងស្មៀនឃុំទេដែលកាន់ និងប្រើប្រាស់លុយរបស់ឃុំ ហើយការធ្វើដូច្នេះ អាចផ្តល់លទ្ធភាពអោយមានអំពើពុករលួយបាន ។

ក្រុមប្រឹក្សាឃុំចំប៉ីមានភាពសកម្ម ក្នុងការដាក់ចេញនូវដីការរបស់ឃុំ ។ ដីការខ្លះទាក់ទងនឹងការបង្កើតគណៈកម្មការរៀបចំផែនការ និងថវិការបស់ឃុំ ហើយនិងបែបបទការងារសំរាប់សមាគមផ្សេងៗនៅក្នុងភូមិដូចជាធនាគារស្រូវ និងក្រុមអ្នកផ្តល់គុជួលសំរាប់អាពាហ៍ពិពាហ៍ ។ ដីការខ្លះទៀតទាក់ទងនឹងបញ្ហាក្នុងសហគមន៍ដូចជាការឆក់ត្រីនៅក្នុងស្រែនិងបឹង ការការពារកុំអោយសត្វបំផ្លាញដំណាំ និងការដោះស្រាយទំនាស់នៅក្នុងចំណោមមនុស្សដែលរស់នៅក្នុងឃុំ ។ ទោះបីជាការអនុវត្តន៍តាមដីការទាក់ទងនឹងបញ្ហារបស់សហគមន៍មានការពិបាក តែភាគច្រើន ក្រុមប្រឹក្សាអាចដាក់ចេញច្បាប់ដែលខ្លួនប្រកាសឡើង ។ ទាក់ទងនឹងការផ្សព្វផ្សាយនីតិរដ្ឋ ក្រុមប្រឹក្សាបានប្រកាសពីការចុះអត្រានុកូលដ្ឋាន តែរហូតមកទល់នឹងពេលនេះ មានមនុស្សតិចណាស់ដែលបានមកចុះនៅសាលាឃុំ ។ នៅក្នុងពេលជាមួយគ្នានោះ ច្បាប់ភូមិបាលរបស់ជាតិ ត្រូវបានក្រុមប្រឹក្សាឃុំយកទៅផ្សព្វផ្សាយដល់ប្រជាជនទូទៅដែរ ។

*ទស្សនៈប្រជាជននៅតាមភូមិ*

ដើម្បីយល់ច្បាស់ពីទស្សនៈរបស់អ្នកភូមិ ក្រុមអ្នកស្រាវជ្រាវបានសំភាសន៍ជាក្រុមតូចៗនៅក្នុងភូមិចំនួនបីដែលស្ថិតនៅដាច់ពីគ្នានៅក្នុងឃុំ គឺភូមិទន្លេនាម ដើមពោធិ និង ខ្វាវ ។

ជាទូទៅ អ្នករស់នៅក្នុងភូមិទន្លេនាមមានចិត្តរីករាយចំពោះការដែលភូមិមានសន្តិសុខល្អ តាំងពីមានក្រុមប្រឹក្សាឃុំមក ហើយគេមានការខិតខំបញ្ឈប់ការនេសាទខុសច្បាប់ និងការទប់ស្កាត់កុំអោយសត្វបំផ្លាញដំណាំ ។ ក្រុមតូចៗភាគច្រើន ដែលត្រូវបានសំភាសន៍ដឹងថា មានសមាជិកក្រុមប្រឹក្សាឃុំពីរនាក់រស់នៅក្នុងភូមិរបស់គេ ។

មានក្រុមមួយបានបញ្ជាក់យ៉ាងច្បាស់ថា ភារកិច្ចសំខាន់របស់ក្រុមប្រឹក្សាឃុំគឺការពារប្រជាជន បង្ក្រាបបទល្មើស អភិវឌ្ឍន៍ភូមិនិងឃុំ ហើយចេញដីការដូចជាការហាមឆក់ត្រីជាដើម ។ តែភាគច្រើននៃក្រុមដែលត្រូវបានសំភាសន៍ មិនមានការយល់ច្បាស់លាស់អំពីដំណើរការវិមជ្ឈការ និងការទាក់ទិនរបស់ក្រុមប្រឹក្សាឃុំក្នុងដំណើរការនេះទេ ។

មួយចំណែកនៃបញ្ហាគឺ សមាជិកក្រុមប្រឹក្សាឃុំមិនសូវមានការប្រាស្រ័យទាក់ទងជាមួយនឹងប្រជាជននៅភូមិទន្លេនាមទេ។ គេចូលចិត្តប្រាប់អ្វីៗទៅដល់ប្រជាជនតាមរយៈប្រធានភូមិ និងគណៈកម្មការអភិវឌ្ឍន៍ភូមិ ហើយពត៌មានខ្លះមិនបានដឹងឮដល់ប្រជាជនទេ ។ ទោះបីជាប្រធានភូមិបានចូលរួមប្រជុំទៀងទាត់ នៅក្នុងអង្គប្រជុំរបស់ក្រុមប្រឹក្សាឃុំ ហើយគណៈកម្មការអភិវឌ្ឍន៍ភូមិបានចូលរួមយ៉ាងសកម្ម នៅក្នុងដំណើរការធ្វើផែនការក្តី តែគេនៅតែមិនទាន់ធ្វើបានគ្រប់គ្រាន់ ក្នុងការលើកកំពស់ការយល់ដឹងរបស់ប្រជាជននៅភូមិទន្លេនាមលើវិមជ្ឈការ និងការចូលរួមដោយផ្ទាល់នៅក្នុងដំណើរការកំណែទំរង់រដ្ឋបាលនោះទេ ។ ការបណ្តុះបណ្តាលដែលផ្តល់អោយដោយអង្គការ GTZ តាមរយៈក្រុមសំរបសំរួលថ្នាក់ស្រុក និងខេត្តផ្តោតតែទៅលើសមាជិកក្រុមប្រឹក្សាឃុំប៉ុណ្ណោះ ។

នៅភូមិដើមពោធិ សមាជិកនៃសមាគមនៅតាមភូមិដែលត្រូវបានសំភាសន៍នៅក្នុងក្រុមតូចមួយ មានទឹកចិត្តសប្បាយរីករាយចំពោះការផ្លាស់ប្តូរដែលមានឡើងដោយសារក្រោមក្រុមប្រឹក្សាឃុំ ។ គេបានលើកឡើងពីការមានសន្តិសុខល្អ ការអភិវឌ្ឍន៍ឃុំ តម្លាភាពនៅក្នុងការគ្រប់គ្រងលុយកាក់ និងទំនាក់ទំនងជិតស្និទរវាងក្រុមប្រឹក្សាឃុំ និងប្រជាជន។ គេបាននិយាយថា សមាគមនៅក្នុងភូមិជាញឹកញាប់ជួបជាមួយនឹងសមាជិកនៃក្រុមប្រឹក្សាឃុំដើម្បីពិភាក្សាពីការអភិវឌ្ឍន៍មូលដ្ឋាន ។ ក្រុមនេះបានកត់សំគាល់ឃើញថា ក្រុមប្រឹក្សាឃុំបានរាយការណ៍ជូនប្រជាជនពីសកម្មភាពនៅក្នុងគំរោងសាងសង់ផ្លូវថ្នល់ បានចេញដីការស្តីពីការបង្កើតគណៈកម្មការនានា និងដីការហាមប្រាមការនេសាទខុសច្បាប់ និងការពារសត្វពាហនៈបំផ្លាញដំណាំ ។ ប៉ុន្តែគេនៅតែនិយាយថា សមត្ថភាពរបស់សមាជិកក្រុមប្រឹក្សាឃុំនៅមានកំរិត ហើយថាក្រុមប្រឹក្សាច្រើនអនុវត្តន៍តាមរបៀបជាការចាំតែស្តាប់ និងធ្វើតាមថ្នាក់លើ ។

ប្រធាន និងអនុប្រធានភូមិដើមពោធិមានការសប្បាយចិត្ត ដោយសារការផ្លាស់ប្តូរដែលកើតមានឡើង ។ គេបាននិយាយថា រដ្ឋបាលបច្ចុប្បន្នមានការចូលរួមច្រើនពីប្រជាជន ចំណែកឯរដ្ឋបាលមុនក្តោបក្តាប់ដោយប្រធានឃុំតែម្នាក់ឯង ។ ចំណុចនេះគួរអោយកត់សំគាល់ដែរ ពីព្រោះមេឃុំនៅពេលមុន និងនៅពេលនេះគឺជាមនុស្សតែមួយ។ តែជំទប់ទី២គឺជាសមាជិករបស់គណបក្សសមរង្ស៊ីដែលរស់នៅក្នុងភូមិនោះ ។ ទន្ទឹមគ្នានឹងការដែល

គេគាំទ្រដល់ការខិតខំរបស់ក្រុមប្រឹក្សាឃុំដើម្បីហាមប្រាមការនេសាទខុសច្បាប់ ប្រធាននិងអនុប្រធានភូមិបាន តូញត្អែរពីអាកប្បកិរិយារបស់នគរបាលឃុំដែលមិនគោរពតាមដីការ ហើយនៅតែបន្តដើរឆក់ត្រីដដែល ។

ក្រុមតូចៗផ្សេងទៀតដែលត្រូវបានសំភាសន៍នៅភូមិដើមពោធិ មានយោបល់ផ្សេងៗពីគ្នាទៅនឹង សមិទ្ធិផលរបស់ក្រុមប្រឹក្សាឃុំ។ មួយក្រុមនិយាយថា ជំទប់ទី២ដែលរស់នៅក្នុងភូមិនោះចូលរួមបានទៀងទាត់ នៅក្នុងប្រជុំរបស់សមាគមអភិវឌ្ឍន៍ភូមិនានា ។ ក្រុមនេះបានកត់សំគាល់ឃើញផងដែរថា ក្រុមប្រឹក្សាឃុំមាន ភាពសកម្មជាងរដ្ឋបាលមុនក្នុងការងារគំរោងអភិវឌ្ឍន៍ដូចជា ការកសាងផ្លូវថ្នល់ជាដើម ។ ក្រុមមួយទៀត បានទទួលស្គាល់អត្ថប្រយោជន៍ នៃការងារផ្នែកហេដ្ឋារចនាសម្ព័ន្ធដែលធ្វើដោយក្រុមប្រឹក្សាឃុំ តែគេគិតថា គំរោងមិនបានឆ្លើយតបទៅនឹងសេចក្តីត្រូវការពិតប្រាកដរបស់ប្រជាជនលើផ្នែកសន្តិសុខស្បៀងទេ ។ ក្រុមមួយ ទៀតនិយាយថា គេមិនឃើញមានការផ្លាស់ប្តូរអ្វីច្រើននៅក្នុងរដ្ឋបាលឃុំទេ ដោយគេនិយាយថា សមទ្ធិផលផ្លូវថ្នល់ និងសាលារៀនបានមកពី អង្គការអន្តរជាតិជាអ្នកជួយ ។ ជាទូទៅ ប្រជាជននៅភូមិដើមពោធិដែលមិនមែន ជាសមាជិកនៃសមាគមណាមួយនៅក្នុងភូមិ មិនសូវបានដឹងពីតួនាទីរបស់ក្រុមប្រឹក្សាឃុំ និងដំណើរការវិមជ្ឈការ ទេ ។ គេធ្វើការប្រាស្រ័យ ជាមួយនឹងសមាជិកក្រុមប្រឹក្សាឃុំ តែនៅពេលណាមានបុណ្យទាន និងពិធីរៀបមង្គល ការតែប៉ុណ្ណោះ ។

នៅក្នុងភូមិខ្វាវ សមាជិកនៃសមាគមភូមិមួយក្រុមនិយាយថា ក្រុមប្រឹក្សាឃុំមានភាពសកម្មច្រើននៅក្នុង ការងារអភិវឌ្ឍន៍ជាងរដ្ឋអំណាចឃុំមុន ។ មេឃុំបានចុះតាមភូមិដើម្បីធ្វើផែនការ និងតាមដានគំរោងអភិវឌ្ឍន៍ តែពីមុន គាត់នៅតែផ្ទះប៉ុណ្ណោះ ។ ក្រុមនេះនៅតែតូញត្អែថា ផែនការរបស់សមាគមនានានៅក្នុងភូមិ មិនត្រូវបាន បញ្ចូលទៅក្នុងផែនការអភិវឌ្ឍន៍ឃុំទេ ។ គេនិយាយថា គេមិនបានចូលរួមពេញលេញក្នុងដំណើរការធ្វើផែនការ ហើយបានដឹងតិចតួចពីសកម្មភាពការងាររបស់ក្រុមប្រឹក្សាឃុំ ដោយសារក្រុមប្រឹក្សាឃុំពឹងតែទៅលើមេភូមិនៅក្នុង ការទាក់ទងផ្ទាល់ជាមួយនឹងប្រជាជន ។ តែក្រុមនោះសរសើរនូវការខិតខំរបស់ក្រុមប្រឹក្សាឃុំនៅក្នុងការចេញដីការ ដើម្បីការពារដំណាំ និងមច្ឆាក្នុងធម្មជាតិ ហើយនិងការកាត់បន្ថយអំពើហឹង្សាក្នុងគ្រួសារ ។

ក្រុមតូចៗដទៃទៀតនៅក្នុងភូមិខ្វាវក៏បានដឹងដែរអំពី ដីការដែលចេញដោយក្រុមប្រឹក្សាឃុំទាក់ទងនឹង សន្តិសុខ ការការពារដំណាំពីសត្វពាហនៈ ហើយនិងការហាមប្រាមលើការនេសាទខុសច្បាប់ ។ តែជាទូទៅ ភាគ ច្រើនអ្នកដែលត្រូវបានសំភាសន៍គិតថា ក្រុមប្រឹក្សាឃុំមិនមានភាពជិតស្និទ្ធជាមួយនឹងប្រជាជន ហើយគេមិនស្គាល់ សមាជិកក្រុមប្រឹក្សាឃុំ ឬអ្វីដែលគេធ្វើនោះទេ។ អ្នកភូមិដែលបានចូលរួមប្រជុំបាននិយាយថា គេទទួលបាននូវ ការណែនាំអោយធ្វើអ្វីមួយ តែមិនត្រូវបានគេសុំមតិយោបល់អ្វីឡើយ ។

## ការរៀបចំ និងអនុវត្តន៍ផែនការ

*ដំណើរការធ្វើផែនការ*

ក្រុមប្រឹក្សាឃុំបានប្រាប់ថា គេបានបង្កើតគណៈកម្មការរៀបចំផែនការ និងថវិកាដោយមានសមាជិកចំនួន៤០នាក់មកពីភូមិចំនួន៨ដែលត្រូវបានគេជ្រើសរើសឡើងនៅក្នុងឃុំ ។ នៅក្នុងគណៈកម្មការនេះមានសមាជិកក្រុមប្រឹក្សាឃុំចំនួន៨នាក់ មេភូមិ និងតំណាងមកពីសង្គមស៊ីវិលដូចជា គណៈកម្មការអភិវឌ្ឍន៍ភូមិ ។ ដោយមានការជួយជ្រោមជ្រែងពីសំណាក់បុគ្គលិកសីលា និងក្រុមសំរបសំរួលថ្នាក់ស្រុក គណៈកម្មការនេះបានប្រមូលពត៌មានទាក់ទងនឹងសេចក្តីត្រូវការរបស់ភូមិនីមួយៗ ។ លទ្ធផលនៃការអង្កេតនេះ ត្រូវបានលើកយកទៅពិភាក្សានៅក្នុងពេលប្រជុំនៅក្នុងភូមិ ហើយតម្រូវការត្រូវបានចាត់ជាលំដាប់អាទិភាព ។ បន្ទាប់មក សមាជិករបស់គណៈកម្មការបានចូលរួមនៅក្នុងសិក្ខាសាលាស្តីពី ការធ្វើផែនការជាមួយនឹងសមាជិកក្រុមប្រឹក្សាឃុំ ។ នៅក្នុងសិក្ខាសាលានេះ គេបូកសរុបតម្រូវការអាទិភាពនានារបស់ភូមិ ដើម្បីដាក់បញ្ចូលទៅក្នុងផែនការឃុំ ស្របទៅតាមការសន្យាផ្តល់ថវិកាពីរាជរដ្ឋាភិបាល ។ សមាជិកនៃក្រុមប្រឹក្សាឃុំបានលើកឡើងថា ឯកសារផែនការ៥ឆ្នាំ ត្រូវបានទុកដាក់ និងសរសេរដោយស្មៀនឃុំ ហើយមានចម្លងជូនទៅភូមិនីមួយៗ ក្រុមសំរបសំរួលថ្នាក់ស្រុក រដ្ឋអំណាចខេត្ត និងអង្គការ GTZ ។ ភូមិនីមួយៗទទួលខុសត្រូវក្នុងការផ្សព្វផ្សាយ ពីលទ្ធផលនៃផែនការទៅដល់ប្រជាជននៅតាមភូមិ និងអំពីគំរោងអ្វីដែលត្រូវយកមកអនុវត្តន៍នៅតាមភូមិនីមួយៗ ។

បន្ទាប់មក សមាជិករបស់ក្រុមប្រឹក្សាឃុំ និងគណៈកម្មការរៀបចំផែនការនិងថវិកា ចូលរួមនៅក្នុងសិក្ខាសាលាសមាហរណកម្មថ្នាក់ស្រុកដើម្បីឧទ្ទេសនាមពីផែនការឃុំចំពោះទៅមន្ត្រីថ្នាក់ស្រុក ស្ថាប័នដែលពាក់ព័ន្ធ អង្គការមិនមែនរដ្ឋាភិបាល និងស្ថាប័នអភិវឌ្ឍន៍ដទៃទៀត ។ សមាជិករបស់គណៈកម្មការនេះដែលមកពីភូមិនីមួយៗ បានចូលរួមនៅក្នុងសិក្ខាសាលាសមាហរណកម្មប្រចាំឆ្នាំថ្នាក់ស្រុកដើម្បីពន្យល់ពីបញ្ហា និងតម្រូវការរបស់ភូមិនីមួយៗអោយបានច្បាស់លាស់ ។ សមាជិកគណៈកម្មការគិតថា សិក្ខាសាលាសមាហរណកម្មថ្នាក់ស្រុក មានប្រយោជន៍ ពីព្រោះបានធ្វើអោយអង្គការ ឬស្ថាប័ននានាមានការយកចិត្តទុកដាក់មកលើស្ថានភាពនៅតាមភូមិឃុំ ហើយទទួលបាននូវការគាំទ្រចំពោះគំរោងផ្សេងៗ ។ ក្រោយពីបញ្ចប់សិក្ខាសាលា ស្ថាប័នរដ្ឋ និងអង្គការអភិវឌ្ឍន៍នានាសន្យាជួយដល់គំរោងផ្សេងៗ ដូចជាការបណ្តុះបណ្តាលសុខភាព ការជីកអណ្តូង និងការជួសជុលផ្លូវថ្នល់ ។

តំណាងរបស់សង្គមស៊ីវិលដែលត្រូវបានសំភាសន៍នៅសាលាឃុំទទួលស្គាល់ថា គេបានចូលរួមក្នុងដំណើរការធ្វើផែនការឃុំ ។ តម្រូវការជាអាទិភាពត្រូវបានគេកំណត់នៅថ្នាក់ភូមិ ហើយនិងអនុម័តដោយថ្នាក់ឃុំ ។

អ្នកដឹកនាំសមាគមនៅតាមភូមិ មេភូមិ សមាជិកគណៈកម្មការរៀបចំផែនការ និងថវិកា និងសមាជិកក្រុមប្រឹក្សាឃុំបានចូលរួមយ៉ាងសកម្មនៅក្នុងដំណើរការធ្វើផែនការ ។ ប៉ុន្តែ អ្នកដឹកនាំសង្គមស៊ីវិលបានគូសបញ្ជាក់ថាការចូលរួមរបស់ប្រជាជនគឺ មិនស្មើគ្នាទេ ។

នៅក្នុងភូមិទន្លេនាម សមាជិកគណៈកម្មការអភិវឌ្ឍន៍ភូមិ និងសមាគមភូមិដែលត្រូវបានសំភាសន៍ជាមួយមានការចូលរួមយ៉ាងសកម្មនៅក្នុងការប្រជុំធ្វើផែនការ ។ ប៉ុន្តែ ប្រជាជនទូទៅមិនចាំរបៀបវារៈនៃការប្រជុំទេ ហើយនិយាយថា គេទៅធ្វើការសង្កេតជាជាងចូលរួមយ៉ាងសកម្មក្នុងការពិភាក្សា ។ ប្រជាជនជាច្រើនតែងតែលើកឡើងពីការយល់ច្រឡំទៅលើការប្រជុំទាក់ទងទៅនឹងការធ្វើផែនការ និងការប្រជុំពិភាក្សាគ្នារិះរកមធ្យោបាយសំរាប់អនុវត្តន៍ ។

នៅភូមិដើមពោធិ គណៈកម្មការអភិវឌ្ឍន៍ភូមិ និងសមាជិកនៃសមាគមនៅតាមភូមិចូលរួមច្រើន នៅក្នុងការតាក់តែងផែនការឃុំ ។ នៅក្នុងពេលសំភាសន៍ជាក្រុមជាមួយនឹងសមាជិកសមាគមនៅក្នុងភូមិដើមពោធិ អ្នកឆ្លើយអាចរៀបរាប់លំអិតពីដំណើរដើមទង ហើយអាចប្រាប់ពីគំរោងជាអាទិភាពដែលគេបានកំណត់ ។ តែប្រជាជននៅក្នុងក្រុមខ្លះទៀតដែលត្រូវបានសំភាសន៍ មានការពិបាកនៅក្នុងការចែកអោយដាច់ពីគ្នារវាងការប្រជុំដើម្បីធ្វើផែនការគំរោង និងការប្រជុំដើម្បីវែអង្គាសបដិភាគសំរាប់ដំណើរការគំរោង ។ នៅមានការយល់ច្រឡំផងដែរពីការប្រជុំដើម្បីធ្វើផែនការអភិវឌ្ឍន៍ឃុំ និងប្រជុំដើម្បីធ្វើផែនការគំរោងរបស់អង្គការមិនមែនរដ្ឋាភិបាល។

នៅក្នុងភូមិខ្វារ ប្រជាជនមួយក្រុមដែលត្រូវបានសំភាសន៍បានរៀបរាប់ច្បាស់ពីការចូលរួមរបស់គេនៅក្នុងសកម្មភាពធ្វើផែនការ និងគំរោងអាទិភាពដែលត្រូវបានគេសំរេចយក ។ ផ្ទុយទៅវិញ ក្រុមមួយទៀត មានភាពមិនច្បាស់អំពីការចូលរួមរបស់គេនៅក្នុងការប្រជុំធ្វើផែនការនោះឡើយ ។

*ការអនុវត្តន៍ការងារ*

យោងតាមក្រុមប្រឹក្សាឃុំ គំរោងដែលត្រូវបានអនុវត្តន៍កន្លងមកនៅក្រោមផែនការ៥ឆ្នាំរបស់ឃុំរួមមានៈ ផ្លូវ៣ខ្សែរ និងអណ្តូង២នៅភូមិចំប៉ី ផ្លូវមួយ និងលូមួយកន្លែងនៅភូមិទន្លេនាម ផ្លូវពីរខ្សែរនៅភូមិស្រែជា លូមួយនៅភូមិអង្គជោត ផ្លូវពីរនៅភូមិដើមពោធិ ផ្លូវពីរនិងអណ្តូងស្នប់មួយនៅភូមិលាងសាហែក ហើយនិងផ្លូវមួយនៅភូមិក្រសាំង ។ ក្រុមប្រឹក្សាឃុំបានអោយដឹងថា គេបានទទួលលុយសំរាប់រយៈពេលមួយឆ្នាំចំនួន ៣៣.៤២ លាន

វៀលពីរដ្ឋាភិបាលសំរាប់អនុវត្តន៍ផែនការនោះ ។ កម្មវិធីសីលាជួយផ្នែកហេដ្ឋារចនាសម្ព័ន្ធ (ផ្លូវថ្នល់ ទ្វារទឹក អណ្តូង) ហើយនិងកសិកម្ម (គ្រាប់ពូជ ការប្រើប្រាស់ជី ការចិញ្ចឹមសត្វ និងការបណ្តុះបណ្តាលជំនាញ) តាមរយៈថវិកាឃុំ។ ប្រជាជនផ្តល់ប្រាក់បដិភាគសំរាប់គំរោងហេដ្ឋារចនាសម្ព័ន្ធដែរ។ GTZ និងទស្ថាប័នអភិវឌ្ឍន៍ដទៃទៀតបានរួមចំណែកថវិកា ព្រមទាំងសប្បុរសជននៅបរទេស និងនៅភ្នំពេញបានផ្តល់ថវិកាដែរ ។ ថវិការបស់អង្គការអភិវឌ្ឍន៍ និងសប្បុរសជនបានជួយដល់គំរោងនានាដូចជា ការបណ្តុះបណ្តាលកសិកម្ម ពេទ្យសត្វ ធារាសាស្ត្រ ឥណទាន ការថែទាំសុខភាព និងអាហារូបត្ថម្ភ ។ ក្រុមប្រឹក្សាឃុំក៏បានប្រមូលចំណូលបន្ថែមពីការប្រមូលថ្លៃសេវាអត្រានុកូលដ្ឋាន ។ លុយនេះគេយកទៅទុកនៅឯរតនាគារខេត្តកំពត ។

ក្រុមប្រឹក្សាឃុំបានពន្យល់ថា គំរោងហេដ្ឋារចនាសម្ព័ន្ធធំៗដែលផ្តល់ថវិកាតាមរយៈផែនការឃុំត្រូវបានប្រគល់ដល់អ្នកម៉ៅការតាមរយៈការដេញថ្លៃ ។ ក្រុមប្រឹក្សាឃុំ និងក្រុមអ្នកសំរបសំរួលថ្នាក់ស្រុកជាអ្នកចាត់ចែងដំណើរការដេញថ្លៃ ។ អ្នកដេញថ្លៃបានគឺជាអ្នកដកលុយដោយផ្ទាល់ពីរតនាគារ ។ ដោយមានការជួយពី GTZ ហើយនិងក្រុមអ្នកសំរបសំរួលថ្នាក់ស្រុក ក្រុមប្រឹក្សាឃុំអះអាងថា ខ្លួននិងគណៈកម្មការរៀបចំផែនការ និងថវិកាពិនិត្យមើលដំណើរការអនុវត្តន៍គំរោងដើម្បីធ្វើអោយអ្នកម៉ៅការធ្វើទៅតាមអ្វីដែលមានចែងក្នុងកិច្ចព្រមព្រៀង ។ ក្រុមប្រឹក្សាឃុំរាយការណ៍ថា ខ្លួននិងគណៈកម្មការរៀបចំផែនការនិងថវិកា ក៏បានតាមដានលើគំរោងដែរ ។ ប្រជាជនដែលជាអ្នកទទួលផល ទទួលខុសត្រូវថែទាំគំរោងអោយបានល្អ។ នៅក្នុងករណីខ្លះ ក្រុមប្រឹក្សាឃុំមានការពិបាកក្នុងការប្រមូលបដិភាគពីប្រជាជន និងក្នុងការដោះស្រាយជាមួយនឹងអ្នកដែលទទួលរងនូវការប៉ះពាល់ដល់ទ្រព្យសម្បត្តិរបស់គេ ដោយសារការសាងសង់ផ្លូវថ្នល់ ។

តំណាងរបស់សង្គមស៊ីវិលដែលត្រូវបានសំភាសន៍នៅថ្នាក់ឃុំបានកត់សំគាល់ដោយមោទនភាពថា ប្រជាជនបានចូលរួមធនធានដល់ការអនុវត្តន៍គំរោងអភិវឌ្ឍន៍ឃុំ ។ ការចូលរួមនេះជួយកសាងស្មារតីម្ចាស់ការទទួលខុសត្រូវរបស់គេចំពោះគំរោង ។ គំរោងខ្លះទៀតត្រូវបានដំណើរការតាមរបៀបស្បៀងពលកម្មដែលជួយអោយប្រជាជនមានសន្តិសុខស្បៀងល្អប្រសើរឡើង ដោយនៅពេលជាមួយគ្នានោះដែរក៏ជួយអោយគេមានផ្លូវដើរ ឬមានលូទឹកនៅក្នុងភូមិ ។ នៅពេលជាមួយគ្នានោះដែរ សង្គមស៊ីវិលមានការត្អូញត្អែរថា ការគ្រប់គ្រងថវិការបស់ក្រុមប្រឹក្សាឃុំ មិនមែនសុទ្ធតែមានតម្លាភាពនោះទេ ។ លើសពីនេះទៀត ដំណើរការគំរោងច្រើនតែមានការយឺតយ៉ាវដោយសារលុយកម្រធ្លាក់មកពីរតនាគារជាតិ ។ ក្រុមសង្គមស៊ីវិលនិយាយថា ក្រុមប្រឹក្សាឃុំត្រូវការរៀនសូត្រថែមទៀតលើការគ្រប់គ្រងថវិកា ។

## *ភាពជាដៃគូរវាងក្រុមប្រឹក្សាឃុំ និងសង្គមស៊ីវិល*

### *ទំនាក់ទំនងជាមួយនឹងសមាគមប្រជាជននៅតាមភូមិ*

ក្រុមប្រឹក្សាឃុំបាននិយាយថា គេបានអោយសមាជិកម្នាក់ៗធ្វើការជិតស្និទ្ធជាមួយគណៈកម្មការអភិវឌ្ឍន៍ភូមិ និងសមាគមនានានៅតាមភូមិ ដូចជាធនាគារស្រូវ ឥណទាន និងក្រុមជួលគុអាពាហ៍ពិពាហ៍ ។

តំណាងនៃសង្គមស៊ីវិលដែលត្រូវបានសំភាសន៍ជាមួយនៅថ្នាក់ឃុំបានអោយដឹងថា សមាជិកសមាគមនៅក្នុងភូមិ និងសមាជិកក្រុមប្រឹក្សាឃុំមានការប្រាស្រ័យជាមួយគ្នា នៅក្នុងពេលបើកការប្រជុំនៅក្នុងភូមិម្តង ។ សមាជិកនៃក្រុមប្រឹក្សាឃុំបានចូលរួមក្នុងអង្គប្រជុំរបស់ក្រុមធនាគារស្រូវ តែមិនមានវត្តមានក្នុងការប្រជុំឯទៀតទេ ។ ថ្នាក់ដឹកនាំសង្គមស៊ីវិលនិយាយថា សមាជិកក្រុមប្រឹក្សាឃុំ គួរតែចូលរួមនៅក្នុងការប្រជុំទាំងឡាយអោយបានច្រើនជាងនេះ ។ ក្រុមសង្គមស៊ីវិលលើកឡើងថា សមាគមនៅក្នុងភូមិបានរាយការណ៍ទៅមេឃុំ និងក្រុមប្រឹក្សាឃុំបានទៀងទាត់ បើទោះបីជាគេមិនចូលរួមនៅក្នុងការប្រជុំរបស់ក្រុមប្រឹក្សាឃុំក្តី ។ សមាគមនៅក្នុងភូមិចង់ចូលរួមនៅក្នុងការប្រជុំនៅសាលាឃុំដើម្បីផ្សព្វផ្សាយពត៌មានស្តីពីគំរោងអភិវឌ្ឍន៍របស់គេ ។ មានរឿងមួយគួរអោយចាប់អារម្មណ៍គឺ ក្រុមប្រឹក្សាឃុំពិនិត្យមើលឯកសារលុយកាក់របស់បណ្តាក្រុម ឬសមាគមនអភិវឌ្ឍន៍នានាក្នុងភូមិ និងសកម្មភាពផ្សេងៗរបស់គេដែរ ។ តាមទស្សនៈរបស់ក្រុមអ្នកស្រាវជ្រាវ ការធ្វើដូច្នេះ បង្ហាញអោយឃើញនូវភាពច្របូកច្របល់គ្នា រវាងសង្គមស៊ីវិល និងអាជ្ញាធរមូលដ្ឋាន ។

ក្រុមសង្គមស៊ីវិលអះអាងថា សមាគមអភិវឌ្ឍន៍នៅតាមភូមិបានរួមចំណែកក្នុងការតាក់តែងផែនការឃុំ ។ គេក៏បានចូលរួមផងដែរជាមួយនឹងប្រជាជនឯទៀត ក្នុងសកម្មភាពអភិវឌ្ឍន៍ឃុំដូចជាការកសាងផ្លូវថ្នល់ជាដើម ។ បើសិនជាមានការស្នើសុំ ក្រុមប្រឹក្សាឃុំអាចជួយដល់សមាគមនានានៅតាមភូមិបាន ។ ឧទាហរណ៍ សមាគមគុបានដាក់សំណើរសុំថវិកាទៅកាន់ក្រុមប្រឹក្សាឃុំសំរាប់ធ្វើរោងការ ។

នៅភូមិទន្លេនាម ក្រុមប្រឹក្សាឃុំបានអនុម័តលើការអនុវត្តន៍គំរោងជាអាទិភាពពីរ ។ គំរោងទីមួយគឺការធ្វើផ្លូវក្រាលគ្រួសក្រហម រីឯគំរោងទីពីរគឺ ការដាក់លូទឹក ។ សមាគមអភិវឌ្ឍន៍នៅតាមភូមិ បានផ្តល់ថវិកាបដិភាគសំរាប់គំរោងទាំងពីរនេះ ។ ថវិកានេះបានមកពីគំរោងឥណទាន និងគណៈកម្មការសាងសង់នៅក្នុងភូមិ ។

នៅក្នុងភូមិដើមពោធិ ថ្នាក់ដឹកនាំសង្គមស៊ីវិលមួយក្រុមបាននិយាយថា រវាងសមាគមភូមិ និងក្រុមប្រឹក្សាឃុំ គឺមានការសហការគ្នាល្អ មិនជ្រៀតជ្រែកកិច្ចការគ្នា ហើយមានការទាក់ទងគ្នាប្រកបដោយការបើកចំហ។

នៅក្នុងភូមិខ្វាវ សមាជិកសង្គមស៊ីវិលមួយក្រុមបាននិយាយថា មានការសហការគ្នាល្អរវាងសមាគមនានា ហើយនិងក្រុមប្រឹក្សាឃុំ ។ ក្រុមប្រឹក្សាឃុំបានជួយពិនិត្យបញ្ជី និងឯកសាររបស់ក្រុមធនាគារស្រូវ ។ ចំណែកក្រុមធនាគារស្រូវវិញបានចូលរួមថវិកាបដិភាគដើម្បីយកទៅធ្វើផ្លូវ ។ GTZ បានផ្តួចផ្តើមគំនិតរបៀបនេះដើម្បីប្រមូលថវិកាបដិភាគ ។ ក្រុមប្រឹក្សាឃុំតំណាងអោយផលប្រយោជន៍របស់សមាគម ហើយពេលខ្លះដោះស្រាយបញ្ហានៃការមិនសងបំណុល ។ តាមទស្សនៈរបស់ក្រុមអ្នកស្រាវជ្រាវ បញ្ហានេះបង្ហាញអោយឃើញពីការបញ្ចូលនូវការទទួលខុសត្រូវមិនសមស្រប រវាងសង្គមស៊ីវិល និងរដ្ឋអំណាចនៅថ្នាក់មូលដ្ឋាន ។

*ទំនាក់ទំនងជាមួយនឹងអង្គការមិនមែនរដ្ឋាភិបាល*

ក្រុមប្រឹក្សាឃុំទទួលស្គាល់ថា គេបានសហការជាមួយនឹងអង្គការអភិវឌ្ឍន៍នានាដូចជា GTZ និង RACHA នៅក្នុងគំរោងផ្នែកសុខភាពតាមរយៈមណ្ឌលសុខភាពឃុំ ។ GTZ បានផ្តល់ការបណ្តុះបណ្តាលដល់ភ្នាក់ងារសុខភាពស្ម័គ្រចិត្តភូមិ។ GTZ ក៏នៅបានផ្តល់លុយចំនួន៩លានរៀលសំរាប់ធ្វើផ្លូវដោយបន្ថែមគ្រួសក្រហមលើផ្លូវដែលមានស្រាប់ ។ អង្គការ SVA ក៏បានជួយសាលារៀនចំនួន ២ ខ្នងដែរ។

**ទំនាក់ទំនងជាមួយនឹងរដ្ឋាភិបាល និងគណបក្សនយោបាយ**

មេឃុំបានចូលរួមប្រជុំនៅថ្នាក់ស្រុក នៅពេលត្រឡប់មកវិញ គាត់ផ្តល់ពត៌មានទៅសមាជិកក្រុមប្រឹក្សាឃុំដែលមកពីគណបក្សទាំងបី ។ ក្រុមប្រឹក្សាឃុំបានធ្វើ និងដាក់របាយការណ៍ជូនទៅថ្នាក់ស្រុក ។

អភិបាលស្រុកធ្វើជាប្រធានគណៈកម្មការអភិវឌ្ឍន៍ស្រុក ។ សិលាបានផ្តល់ថវិកាសំរាប់អភិវឌ្ឍន៍ឃុំ ដោយផ្ទាល់តាមរយៈឃុំ មិនមែនតាមថ្នាក់ស្រុកទេ ។ ថវិកាទាំងនេះគឺសំរាប់ចំណាយលើរដ្ឋបាល និងការអភិវឌ្ឍន៍។ សាលាស្រុកសហការជាមួយនឹងកម្មវិធីសីលា ពីព្រោះមន្ត្រីថ្នាក់ស្រុកខ្លះ កំពុងតែធ្វើការផ្ទាល់ជាមួយនឹងកម្មវិធីសីលាស្រាប់ ។ តែអភិបាលស្រុកមិនបានចូលរួមនៅក្នុងកម្មវិធីសីលាទេ ។ មន្ទីរកសិកម្ម និងសុខាភិបាលខេត្ត បានបើកការបណ្តុះបណ្តាលនៅថ្នាក់ភូមិ។ ក្រុមប្រឹក្សាឃុំបានផ្សព្វផ្សាយពត៌មានដល់គណបក្សនយោបាយ ភាគច្រើនតាមរយៈសមាជិករបស់គណបក្សរៀងៗខ្លួន នៅក្នុងក្រុមប្រឹក្សាឃុំ ។

ឧបសម្ព័ន្ធ ៣

ករណីសិក្សាទី ៣

# ឃុំច្រេស ស្រុកជុំគីរី

## ខេត្តកំពត

## ជាឃុំដែលត្រូវបានជ្រើសរើស និងផ្តល់ជំនួយដោយអង្គការ ស៊ីដសេ

### ប្រវត្តិ

ច្រេសគឺជាឃុំមួយក្នុងចំណោមឃុំចំនួន៧នៅក្នុងស្រុកជុំគីរី ខេត្តកំពត ។ ឃុំនេះមានភូមិចំនួនបួនដែលមានមនុស្សចំនួន១.១៤១គ្រួសារ ។ ប្រភពចំណូលសំខាន់គឺ ការធ្វើស្រែ ។ ការនេសាទគឺជា មុខរបរបន្ទាប់បន្សំ ។ ក្នុងមួយគ្រួសារមានដីគិតជាមធ្យមកន្លះហិកតា ហើយទិន្នផលស្រូវគិតជាមធ្យមគឺ ១.៥តោន ។ ដោយសារតែការធ្វើស្រែតែម្តងក្នុងមួយឆ្នាំ ដូច្នេះជាធម្មតា គេមិនមានហូបចុកគ្រប់គ្រាន់ទេ ។

អង្គការអភិវឌ្ឍន៍ពិសេសអង្គការស៊ីដសេ ព្រមទាំងអង្គការស្បៀង និងកសិកម្មរបស់អង្គការសហប្រជាជាតិ (FAO) បានជួយលើការងារអភិវឌ្ឍន៍នៅក្នុងភូមិចំនួនបួននៅក្នុងវិស័យអប់រំ ការថែទាំសុខភាព កសិកម្ម និង ឥណទាន ។ គំរោងដោយឡែក១រួមមាន ធនាគារស្រូវ ធនាគារជ្រូក ធនាគារគោ ក្រុមជួយខ្លួនឯង ថ្នាក់អក្ខរកម្ម បណ្ណាល័យតាមភូមិ ឆ្មបបូរាណ ពេទ្យសត្វ សួនបន្លែ ស្រែបង្ហាញ ការថែទាំសុខភាព ទឹកស្អាត បង្គន់អនាម័យ ដី ឥណទាន លូ និងផ្លូវថ្នល់ ។ តែនៅខ្វះផ្លូវថ្នល់ពីភូមិមួយទៅភូមិមួយ ខ្វះប្រព័ន្ធស្រោចស្រព និងខ្វះសេវាសុខភាពគ្រប់គ្រាន់ ។ នៅក្នុងឃុំនេះ គេអាចធ្វើស្រែពីរដងក្នុងមួយឆ្នាំ បើសិនជាមានការសាងសង់ទំនប់ដ៏ធំមួយ ។

នៅក្នុងឆ្នាំ ១៩៩៤ ស៊ីដសេបានចាប់ដំណើរការកម្មវិធីអភិវឌ្ឍន៍ចំរុះតាមជនបទនៅក្នុងភូមិចំនួនបួនក្នុងឃុំច្រេស ។ ក្រោយពីធ្វើការសិក្សាវាយតំលៃនៅតាមជនបទដោយមានការចូលរួម (PRA) រួចមក ស៊ីដសេបានបង្កើតគណៈកម្មការអភិវឌ្ឍន៍ភូមិដើម្បីអោយគ្រប់គ្រង និងសំរបសំរួលការងារអភិវឌ្ឍន៍ដែលរួមមាន ការលើកកំពស់ការងារកសិកម្ម ក្រុមជួយខ្លួនឯង និងគំរោងហេដ្ឋារចនាសម្ព័ន្ធដូចជា ការដាក់លូ បណ្ណាល័យ និងសាលារៀន។ នៅពេលថ្មី១នេះ ស៊ីដសេបានជួយដល់ការធ្វើផែនការអភិវឌ្ឍន៍សំរាប់គំរោងអភិវឌ្ឍន៍សហគមន៍ចំរុះដែលខ្លួនបានជួយថវិកា ។

ក្រុមប្រឹក្សាឃុំច្រេសមានសមាជិកចំនួន៥នាក់ ។ ៣នាក់មកពីគណបក្សប្រជាជន ១នាក់មកពីគណបក្ស ហ៊្វុនស៊ិនប៉ិច និងម្នាក់ទៀតមកពីគណបក្សសមរង្ស៊ី ។ មេឃុំគឺជាអ្នកដែលមកពីគណបក្សប្រជាជន ។ សមាជិកទាំងអស់របស់ក្រុមប្រឹក្សាឃុំគឺ ជាបុរស ។ ស្មៀនឃុំគឺជានារី ។

## រដ្ឋបាលឃុំ

*ការប្រែប្រួលចាប់តាំងពីការបង្កើតក្រុមប្រឹក្សាឃុំ*

ការប្រែប្រួលធំជាងគេបំផុត ក្រោយពីបង្កើតបាននូវក្រុមប្រឹក្សាឃុំមកគឺ ការបោះឆ្នោតជ្រើសរើសបានមេឃុំថ្មី ។ ប្រជាជនជាច្រើនមិនសប្បាយចិត្តនឹងរបៀបដែលមេឃុំមុនធ្វើចំពោះការកាន់កាប់ដីឃុំដោយទាហាន ។ ការបោះឆ្នោតនេះ បានផ្តល់ដល់ប្រជាជនមូលដ្ឋាននូវឱកាសធ្វើការផ្លាស់ប្តូរមេឃុំចេញ (មេឃុំចាស់ និងថ្មីគឺជាអ្នកដែលមកពីគណបក្សប្រជាជនដូចគ្នា) ។ ទោះបីជាមេឃុំមុនបាត់បង់តំណែងខ្ពស់ក្តី ក៏គាត់នៅទទួលបានសំលេងគ្រប់គ្រាន់ដើម្បីនៅធ្វើជាសមាជិកក្រុមប្រឹក្សាឃុំដែរ ។ ចំពោះលក្ខណៈនៃការផ្លាស់ប្តូរដូចជា ការដាក់ជំនួសសមាជិកម្នាក់មកពីគណបក្សសំលេងភាគច្រើន ដោយមនុស្សម្នាក់ទៀតដែលមកពីគណបក្សដដែលនោះ មើលទៅហាក់ដូចជាមិនមានបញ្ហាអ្វីធំដុំទេ តែប្រជាជនមានឱកាសធ្វើការជ្រើសរើសតំណាងរបស់គេដែលនៅក្នុងរដ្ឋបាលមុន គេមិនមានឱកាសដូចនេះទេ ។

សមាជិកក្រុមប្រឹក្សាឃុំនិយាយថា ឥឡូវនេះមានតម្លាភាពច្រើនជាងកាលពីរដ្ឋបាលមុន ។ ពត៌មានស្តីពីបញ្ហានៅក្នុងឃុំហើយនិងប្រាក់ដែលគេបែងចែកអោយសំរាប់គំរោងអភិវឌ្ឍន៍ឥឡូវត្រូវបានគេអោយប្រជាជនដឹង ។ ការចូលរួមរបស់សមាជិកមកពីគណបក្សហ៊្វុនស៊ិនប៉ិច និងសមរង្ស៊ីនៅក្នុងក្រុមប្រឹក្សាឃុំបើកអោយមានមតិប្រឆាំងបាន ទោះបីជាថាសមាជិកមកពីគណបក្សប្រជាជន ជាពិសេសមេឃុំនៅតែមានអំណាចលើសលប់ក្តី ។ លើសពីនេះទៀត ក្រុមប្រឹក្សាឃុំបានចូលរួមនៅក្នុងការធ្វើផែនការ និងការអនុវត្តន៍គំរោងអភិវឌ្ឍន៍ ។ ក្រៅពីនេះសមាជិកក្រុមប្រឹក្សាឃុំបានសារភាពថា រដ្ឋបាលឃុំមានការប្រែប្រួលតិចតួចប៉ុណ្ណោះ ។

តំណាងរបស់សង្គមស៊ីវិលដែលត្រូវបានសំភាសន៍នៅសាលាឃុំបានសង្កត់ធ្ងន់ថា មានការប្រែប្រួលចំពោះការចូលរួមរបស់ក្រុមប្រឹក្សាឃុំនៅក្នុងសកម្មភាពអភិវឌ្ឍន៍ ។ កាលពីរដ្ឋបាលមុន មិនមានការធ្វើផែនការជាលក្ខណៈចូលរួមទេ។ ទាក់ទងនឹងរដ្ឋបាលឃុំនិងសន្តិសុខឃុំ សង្គមស៊ីវិលដែលបានសំភាសន៍បានសង្កេតឃើញថាមិនមានការប្រែប្រួលអ្វីច្រើនទេ ។ មានពេលខ្លះថ្នាក់ដឹកនាំសង្គមស៊ីវិលត្រូវបានគេអញ្ជើញអោយចូលរួម នៅក្នុងអង្គប្រជុំស្តីពីកម្មវិធីអភិវឌ្ឍន៍ តែមិនដែលត្រូវបានអញ្ជើញអោយចូលរួមប្រជុំស្តីពី បញ្ហាទាក់ទងនឹងការគ្រប់គ្រង

រដ្ឋបាលឡើយ ។ ដូចគ្នានេះដែរ តំណាងរបស់សង្គមស៊ីវិលមិនដឹងពីសេចក្តីសំរេចចិត្ត និងសារាចររបស់ថ្នាក់លើទេ ពីព្រោះ ក្រុមប្រឹក្សាឃុំមិនដែលផ្សព្វផ្សាយជាសាធារណៈទេ ។

*ការបំពេញការងារ*

ក្រុមប្រឹក្សាឃុំធ្វើការប្រជុំទៀងទាត់ប្រចាំខែហើយធ្វើរបាយការណ៍ប្រចាំខែទៅថ្នាក់ស្រុក ។ នៅពេលខ្លះ ក្រុមប្រឹក្សាបើកការប្រជុំពិសេសស្តីពីគំរោងអភិវឌ្ឍន៍ឃុំ ។ ការិយាល័យខេត្តទទួលបន្ទុកខាងការគ្រប់គ្រងរដ្ឋបាលមូលដ្ឋាន (POLA) និងនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន (DOLA) បានធ្វើការបណ្តុះបណ្តាលដល់ក្រុមប្រឹក្សាឃុំលើការតំរង់ទិស ការធ្វើផែនការ និងគ្រប់គ្រងថវិកា ។ ស៊ីដសេ និងគំរោងគាំទ្រក្រុមប្រឹក្សាឃុំសង្កាត់ (CCSP) ក៏បានបើកការបណ្តុះបណ្តាលដើម្បីកសាងសមត្ថភាពរបស់ក្រុមប្រឹក្សាឃុំដែរ ។ អភិបាលស្រុកបានកត់សំគាល់ឃើញថា សមាជិកក្រុមប្រឹក្សាឃុំខ្លះនៅស្រុកជុំគីរី មិនសូវមានការសិក្សាខ្ពស់ ហើយការនេះធ្វើអោយគេមានការពិបាកនៅក្នុងការបំពេញតួនាទីរបស់គេ ។

ក្រុមប្រឹក្សាឃុំច្រេសបានចេញដីការឃុំមួយចំនួន ។ តែសមាជិកក្រុមប្រឹក្សាឃុំមិនចាំដីការទាំងនេះទេ ។ តែគេបានដឹងថា ដីការមួយទាក់ទងទៅនឹងការបង្កើតគណៈកម្មការរៀបចំផែនការ និងថវិកា ត្រូវបានអនុម័ត ។ សមាជិកក្រុមប្រឹក្សាឃុំបានទទួលស្គាល់ថា ដីការទាំងនេះរួមជាមួយនឹងសេចក្តីសំរេចរបស់ក្រុមប្រឹក្សាឃុំ និងបទបញ្ជាពីថ្នាក់លើ មិនត្រូវបានគេផ្សព្វផ្សាយអោយប្រជាជនបានដឹងទេ ។ គេសង្កេតឃើញថា ក្រុមប្រឹក្សាឃុំជួបជាមួយនឹងប្រជាជននៅនឹងមូលដ្ឋានរបស់គេ ដោយគ្រាន់តែធ្វើការពិភាក្សាពីគំរោងអភិវឌ្ឍន៍ និងការចូលរួមបដិភាគពីប្រជាជនចំពោះគំរោងទាំងនេះតែប៉ុណ្ណោះ ។

*ទស្សនៈរបស់ប្រជាជននៅតាមភូមិ*

ដើម្បីដឹងច្បាស់ពីទស្សនៈរបស់អ្នកភូមិ ក្រុមអ្នកស្រាវជ្រាវបាននិយាយទៅកាន់ប្រជាជននៅក្នុងភូមិចំនួនបីដែលស្ថិតនៅដាច់ៗពីគ្នា គឺភូមិច្រេស ត្រពាំងឈើទាល និងតាទែន ។

នៅក្នុងភូមិច្រេស ក្រុមតូចៗដែលត្រូវបានសំភាសន៍មើលឃើញការប្រែប្រួលតិចតួចនៅក្នុងរដ្ឋបាលឃុំចាប់តាំងពីការបង្កើតក្រុមប្រឹក្សាឃុំមក ។ គេដឹងថា ឥឡូវនេះមានមន្ត្រីឃុំច្រើនជាងមុន ហើយគេមកពីគណបក្សផ្សេងៗ ។ តែគេមិនស្គាល់សមាជិកក្រុមប្រឹក្សាឃុំច្បាស់ទេ ពីព្រោះសមាជិកក្រុមប្រឹក្សាឃុំមិនដែលពិភាក្សាពីតួនាទីរបស់គេជាសាធារណៈ រាយការណ៍ពីការងាររបស់គេ ឬផ្សព្វផ្សាយការណែនាំ និងសារាចរពីថ្នាក់លើទេ ។ ជាទូទៅ ប្រជាជននៅតាមភូមិប្រាស្រ័យទាក់ទងជាមួយនឹងក្រុមប្រឹក្សាឃុំតាមរបៀបដូចដែលគេប្រាស្រ័យជាមួយ

នឹងរដ្ឋអំណាចឃុំនៅក្នុងពេលអតីតកាលដូច្នោះដែរ ។ ឧទាហរណ៍ គេបានសុំអោយក្រុមប្រឹក្សាឃុំជួយដោះស្រាយជំលោះរវាងប្ដីប្រពន្ធ ប្រាប់ពីចោរលួចគោ និងសុំការដោះស្រាយចំពោះជំលោះដីធ្លី ។ ដូចកាលកន្លងទៅដែរ ប្រជាជនមិនមែនសុទ្ធតែសប្បាយចិត្តនឹងរបៀបដែលមន្ត្រីឃុំដោះស្រាយបញ្ហាទាំងនេះនោះទេ ។

នៅក្នុងភូមិច្រេស គេបានពន្យល់ថា គោលបំណងសំខាន់ដែលក្រុមប្រឹក្សាឃុំបើកការប្រជុំ នៅក្នុងភូមិគឺដើម្បីពិភាក្សាពីការចូលរួមបដិភាគពីប្រជាជនចំពោះគំរោងអភិវឌ្ឍន៍ ។ សមាជិកក្រុមប្រឹក្សាឃុំគិតពីការងារអនុវត្តន៍គំរោងជាក់ស្ដែង ហើយបានសួរទៅអ្នកភូមិថា តើគេអាចជួយជាកំលាំងពលកម្មបានយ៉ាងម៉េចខ្លះសំរាប់ការធ្វើផ្លូវ សាលារៀន និងប្រឡាយស្រោចស្រពជាដើម។ សមាជិកក្រុមប្រឹក្សាឃុំមិនបានចូលរួមសកម្មនៅក្នុងការធ្វើផែនការភូមិទេ តែពឹងផ្អែកលើក្រុមសំរបសំរួលថ្នាក់ស្រុកនៃកម្មវិធីសីលា និងអង្គការមិនមែនរដ្ឋាភិបាលដូចជា ស៊ីដសេ អោយធ្វើការងារនេះ ។ ក្រុមប្រឹក្សាឃុំបានបញ្ជូនពត៌មានទៅកាន់ប្រជាជននៅតាមភូមិតាមរយៈមេភូមិ ។

នៅភូមិត្រពាំងឈើទាល ក្រុមតូចមួយដែលត្រូវបានសំភាសន៍បានធ្វើការកត់សំគាល់ថា នៅក្នុងរដ្ឋបាលមុនមេឃុំធ្វើការសំរេចអ្វីៗតែម្នាក់ឯង ដោយមិនពិគ្រោះយោបល់ទេ ។ ឥឡូវនេះសមាជិកក្រុមប្រឹក្សាឃុំច្រើននាក់ចូលរួមនៅក្នុងការសំរេចអ្វីៗ ហើយក្រុមប្រឹក្សាពិគ្រោះយោបល់ជាមួយនឹងប្រជាជននៅតាមភូមិទាក់ទងនឹងគំរោងអភិវឌ្ឍន៍ជាច្រើន ។ មានមួយក្រុមទៀតបានគិតថា ក្រុមប្រឹក្សាឃុំបានជួយកែលំអរសន្តិសុខ ដោយកាត់បន្ថយការលួច និងប្លន់ ។ ក្រុមផ្សេងទៀតនិយាយថា ក្រុមប្រឹក្សាឃុំតែងតែមានវត្តមាននៅក្នុងការអនុវត្តន៍គំរោងផ្នែកហេដ្ឋារចនាសម្ព័ន្ធដូចជា ផ្លូវថ្នល់ និងការសាងសង់សាលារៀន។ ភាគច្រើននៃក្រុមតូចៗដែលត្រូវបានសំភាសន៍នោះបាននិយាយថា តាមធម្មតា ក្រុមប្រឹក្សាឃុំជួបជាមួយនឹងអ្នកភូមិដើម្បីពិភាក្សាពីការចូលរួមបដិភាគចំពោះគំរោងអភិវឌ្ឍន៍ ។ ក្រៅពីការរៀបរាប់ទាក់ទងទៅនឹងគំរោងអភិវឌ្ឍន៍ ភាគច្រើននៃក្រុមតូចៗទាំងនេះមានការយល់ដឹងតិចតួចពីសកម្មភាពរបស់ក្រុមប្រឹក្សាឃុំ ។ មានម្នាក់នៅក្នុងក្រុមមួយបានប្រកាសថា បើសិនជាក្រុមប្រឹក្សាឃុំធ្វើការមិនបានល្អ គាត់នឹងបោះឆ្នោតអោយអ្នកផ្សេងនៅអាណត្តិក្រោយ ។

នៅក្នុងភូមិតាទែន គេបាននិយាយថា ក្រុមប្រឹក្សាឃុំចូលរួមជួយគំរោងអភិវឌ្ឍន៍ដូចជា ផ្លូវថ្នល់ ទំនប់ទឹក សាលារៀន។ ភាគច្រើននៃក្រុមតូចៗទាំងនោះនិយាយថា ក្រុមប្រឹក្សាឃុំបានជួបជាមួយនឹងអ្នកភូមិដើម្បីពិភាក្សាពីការចូលរួមបដិភាគ ។ ក្រុមតូចៗទាំងនេះមិនដឹងពីដីការដែលក្រុមប្រឹក្សាបានដាក់ចេញ ឬទិដ្ឋភាពផ្សេងទៀតនៃការងាររបស់ក្រុមប្រឹក្សានោះទេ។ ជាទូទៅ ក្រុមតូចៗនៅតាមភូមិដែលត្រូវបានសំភាសន៍ពឹងមកលើ ក្រុមប្រឹក្សាឃុំ ដូចដែលគេបានពឹងមកលើរដ្ឋអំណាចឃុំកាលពីអតីតកាលដែរ ដើម្បីសុំការជួយដោះស្រាយនៅក្នុងជំលោះ

រវាងប្តីប្រពន្ធ រវាងអ្នកភូមិ ហើយអោយជួយស្រាវជ្រាវកែរលើលួចគោ ។ ទាក់ទងនឹងការងារអភិវឌ្ឍន៍ មានការយល់ច្រឡំខ្លះស្តីពីគំរោងដែលមាននៅក្នុងផែនការឃុំ ដែលត្រូវបានអនុវត្តន៍ដោយក្រុមប្រឹក្សាឃុំ ហើយនិងគំរោងនានាដែលអនុវត្តន៍ដោយអង្គការមិនមែនរដ្ឋាភិបាល ដូចជា អង្គការស៊ីដសេ ។

## ការធ្វើផែនការនិងការអនុវត្តន៍ការងារ

*ដំណើរការធ្វើផែនការ*

គណៈកម្មាធិការរៀបចមផែនការនិងថវិកាឃុំច្រេស មានសមាសភាពសមាជិកមកពីក្រុមប្រឹក្សាឃុំ ចំនួន៥នាក់ មេភូមិ ៤នាក់ សមាជិកគណៈកម្មការអភិវឌ្ឍន៍ភូមិ ៤នាក់ និងតំណាងភូមិ ២នាក់ ។ គណៈកម្មាធិការនេះ រៀបចំផែនការ៥ឆ្នាំរបស់ឃុំ ដោយមានការជួយរបស់អង្គការស៊ីដសេ FAO និងក្រុមសំរបសំរួលថ្នាក់ស្រុក ។ នៅក្នុងការសំភាសន៍ដោយឡែកជាមួយក្រុមសំរបសំរួលថ្នាក់ស្រុកបានពន្យល់ថាមាន ៥ដំណាក់កាល និង ១១ជំហ៊ាន នៅក្នុងដំណើរការធ្វើផែនការ ។ ជំហ៊ានទាំងនោះរួមមាន: ការប្រមូលនិងវិភាគទិន្នន័យ ការកំណត់ពីតំរូវការជាមួយនឹងអ្នកភូមិ ធ្វើសមាហរណកម្មសេចក្តីត្រូវការរបស់ភូមិទៅក្នុងអាទិភាពរបស់ឃុំ ដាក់ចេញគោលដៅជាយុទ្ធសាស្ត្រ រៀបចំគំរោងសំរាប់ឃុំដោយមានកំណត់ពីសោហ៊ុយប៉ាន់ស្មាន ហើយរកមើលថវិកាសំរាប់គំរោង របស់ឃុំ ។

យោលទៅតាមសមាជិករបស់គណៈកម្មាធិការរៀបចំផែនការនិងថវិកា ការចូលរួមរបស់ប្រជាជននៅក្នុងដំណើរការធ្វើផែនការត្រូវបានលើកទឹកចិត្ត ។ ដំបូងមេភូមិ និងគណៈកម្មការអភិវឌ្ឍន៍ភូមិ ជួយអ្នកភូមិក្នុងការកំណត់រកមើលសេចក្តីត្រូវការនិងគំរោងជាអាទិភាពសំរាប់លើកយកទៅពិភាក្សាជាមួយនឹងគណៈកម្មការរៀបចំផែនការនិងថវិកា ។ បន្ទាប់មកការប្រជុំនៅថ្នាក់ឃុំត្រូវបានធ្វើឡើងដើម្បីកំណត់អាទិភាព និងបូកសរុបគំរោងបញ្ចូលទៅក្នុងផែនការឃុំ ។ អ្នកសំរបសំរួលជួយសរសេរផែនការអោយរួចជាស្រេចដើម្បីដាក់អោយអនុម័តដោយក្រុមប្រឹក្សាឃុំរួចហើយ នឹងត្រូវដាក់ជូនទៅអាជ្ញាធមិស្រុកនិងខេត្ត ។

បញ្ហាខ្លះត្រូវបានជួបប្រទះនៅក្នុងការអនុវត្តន៍គំរោង ដោយសារនៅពេលខ្លះអ្នកភូមិមិនចង់បង់ប្រាក់វិភាគទានបដិភាគនិងវិភាគទានជាពលកម្ម ។ មួយចំណែកនៃមូលហេតុគឺ ដោយសារសមាជិកក្រុមប្រឹក្សាឃុំមានការពាក់ព័ន្ធជាមួយនឹងគណបក្សនយោបាយ ។ សមាជិកនៃគណៈកម្មាធិការរៀបចំផែនការនិងថវិកា ដែលបានសំភាសន៍ និយាយថា ការសហការគ្នានៅខ្សោយនៅឡើយនៅក្នុងចំណោមសមាជិកនៃក្រុមប្រឹក្សាឃុំ គណៈកម្មាធិការ សង្គមស៊ីវិល និងប្រជាជន ។

ក្រោយពីផែនការ៥ឆ្នាំត្រូវបានសរសេរចេញហើយ មេឃុំច្រេសឧទ្ទេសនាមផែនការនោះនៅឯសិក្ខាសាលាសមាហរណកម្មនៅថ្នាក់ស្រុក ដើម្បីសុំការជួយជាថវិកាពីអង្គការមិនមែនរដ្ឋាភិបាលនិងទីភ្នាក់ងារអភិវឌ្ឍន៍ជាបន្ថែមលើថវិកាដែលឃុំទទួលបានពីរដ្ឋាភិបាល ។ អង្គការស៊ីដសេហើយនិង FAO បានយល់ព្រមជួយដល់គំរោងមួយចំនួននៅក្នុងផែនការ ។ តាមធម្មតា មេឃុំចូលរួមនៅក្នុងសិក្ខាសាលាសមាហរណកម្មថ្នាក់ស្រុកជាមួយតែជំទប់ទីមួយឬទីពីរ ។ សមាជិកគណៈកម្មការផែនការនិងថវិកាវិញ មិនបានចូលរួមនៅក្នុងសិក្ខាសាលានេះទេ ។

*ការនុវត្តន៏ការងារ*

នៅក្នុងឃុំច្រេសគំរោងដែលត្រូវបានអនុវត្តន៏ (ចេញពីផែនការ ៥ឆ្នាំ) ភាគច្រើនជាគំរោងផ្នែកហេដ្ឋារចនាសម្ព័ន្ធ ។ នៅក្នុងឆ្នាំ ២០០២ ក្រុមប្រឹក្សាឃុំច្រេសបានកសាងសាលារៀនមួយខ្នងមានពីរបន្ទប់ ផ្លូវលំមួយខ្សែនិងទ្វារទឹកមួយ ។ ថវិកាសំរាប់គំរោងទាំងនេះគឺមាន៣១លានរៀល ។ អ្នកភូមិរួមវិភាគទានបន្ថែម ៣លានរៀលទៀត ។ សូមបញ្ជាក់ថា មិនមែនគ្រប់គ្រួសារនៅឃុំច្រេសចូលរួមវិភាគទានបដិភាគតាមការតំរូវរបស់អាជ្ញាធមិមូលដ្ឋានទេ ។ គ្រួសារនៅ ភូមិដែលមានគំរោងត្រូវបានគេសុំអោយបង់៥០០០រៀល ចំណែកគ្រួសារនៅក្នុងភូមិដទៃទៀតត្រូវបានគេសុំអោយបង់ចំនួន២៥០០រៀល ។ គណៈកម្មការផែនការនិងថវិកាបានត្អូញត្អែរ ថាពិតមែនតែប្រជាជនយល់ព្រមអនុវត្តន៏គំរោង តែគេមិនចង់ជួយជាកំលាំងពលកម្មឬជាថវិកាទេ ។ ក្រុមប្រឹក្សា ឃុំខិតខំប្រមូលថវិកាបដិភាគពីប្រជាជននៅរដូវច្រូតកាត់ ដើម្បីអោយដឹងថាតើគេមានប្រាក់ប៉ុន្មានសំរាប់យកទៅអនុវត្តន៏ផែនការ ។

នៅក្នុងឆ្នាំ ២០០៣ ឃុំច្រេសទទួលបាននូវថវិកាបន្ថែមចំនួន២៨លានរៀលពីមូលនិធិអភិវឌ្ឍន៏ឃុំហើយនិង ២.៥លានរៀលពីការបង់វិភាគទានរបស់អ្នកស្រុក ។ អង្គការស៊ីដសេហើយនិង FAO បានផ្តល់ថវិកាផ្សេងទៀតតាមរយៈអង្គការរបស់គេ ។ ថវិកាឃុំត្រូវបានទុកនៅឯរតនាគារខេត្ត ។ អ្នកម៉ៅការគំរោងត្រូវបានស្នើរសុំអោយធ្វើការដេញថ្លៃ បើអ្នកម៉ៅការណាដេញថ្លៃឈ្នះ ក្នុងការសាងសង់សាលារៀនបាន នោះគេត្រូវដកលុយពីរតនាគារខេត្ត ។ នៅក្នុងពេលជាមួយគ្នានោះ គណៈកម្មាធិការរៀបចំផែនការនិងថវិកា ត្រូវតាមដានការអនុវត្តន៏ការងារ តែសមាជិករបស់គណៈកម្មាធិការនេះបានត្អូញត្អែរថាគេមិនបានដឹងលំអិតពីការចំណាយរបស់គំរោង ។

យោលទៅតាមសមាជិករបស់គណៈកម្មាធិការរៀបចំផែនការនិងថវិកា ក្រុមប្រឹក្សាឃុំមិនបានផ្សព្វផ្សាយការចំណាយរបស់ឃុំ ។ សមាជិករបស់គណៈកម្មាធិការរៀបចំផែនការនិងថវិកា បាននិយាយថា គេចង់ដឹងអំពីការចំណាយផ្សេងៗ និងចង់អោយប្រពន្ធ័តាមដានថវិកា ។ សមាជិករបស់គណៈកម្មាធិការរៀបចំផែនការ

និងថវិកា បាននិយាយថា ពួកគេបានតាមដានសកម្មភាព គំរោងទៀងទាត់ហើយទទួលខុសត្រូវលើការថែទាំ ។ សមាជិកគណៈកម្មាធិការបាន និយាយថាសំណង់ខ្លះមិនត្រូវបានធ្វើទៅតាមបទដ្ឋានបច្ចេកទេសត្រឹមត្រូវទេ ។

សមាជិកនៃគណៈកម្មាធិការរៀបចំផែនការនិងថវិកា ដែលត្រូវបានសំភាសន៏មានកង្វល់ថា ការចូលរួមរបស់ប្រជាជនមិនបានល្អ ហើយថាផែនការមិនត្រូវបានគេអនុវត្តន៏បានពេញលេញល្អទេ ។ គណៈកម្មាធិការមានការបារម្ភចំពោះលទ្ធផលនៅពេលខាងមុខ ។ តែគណៈកម្មាធិការសប្បាយ ដោយឃើញប្រជាជននៅក្នុងឃុំទទួលបានផលដែលគេមើលឃើញនឹងភ្នែកពីការងាររបស់គំរោង ។ សមាជិកគណៈកម្មាធិការដែលត្រូវបានសំភាសន៏បានសង្កត់ធ្ងន់ លើសារៈសំខាន់នៃភាពស្មោះត្រង់ហើយនិងការចូលរួមរបស់ប្រជាជន ។ គេនិយាយថាបញ្ជីចំណូលចំណាយរបស់ឃុំ គួរតែអោយប្រជាជនដឹងទាំងអស់ ។

## ភាពជាដៃគូរវាងក្រុមប្រឹក្សាឃុំហើយនឹងសង្គមស៊ីវិល

*ទំនាក់ទំនងជាមួយនឹងសមាគមប្រជាជន*

ចំពោះបញ្ហាភាគច្រើនផ្នែករដ្ឋបាល ក្រុមប្រឹក្សាឃុំបានធ្វើការតាមរយៈប្រធានភូមិ ។ ចំពោះការធ្វើផែនការនិងការអនុវត្តន៏ការងារអភិវឌ្ឍន៏ ក្រុមប្រឹក្សាឃុំធ្វើការជិតស្និទ្ធជាមួយនឹងគណៈកម្មាធិការរៀបចំផែនការនិងថវិកា ។ គណៈកម្មាធិការនេះមានសមាជិក៩នាក់មកពីអាជ្ញាធមិមូលដ្ឋានដោយរួមទាំងក្រុមប្រឹក្សាឃុំផង និងមេភូមិ តំណាងចំនួន៦នាក់មកពីសមាគមប្រជាជន ដែលភាគច្រើនជាសមាជិកគណៈកម្មការអភិវឌ្ឍន៏ភូមិ ។ នៅក្នុងជួរគណៈកម្មាធិការរៀបចំផែនការនិងថវិកានេះ សមាជិកដែលចេញពីសង្គមស៊ីវិលនិយាយថា កិច្ចសហប្រតិបត្តិការជាមួយនឹងអាជ្ញាធមិមូលដ្ឋាន គឺនៅខ្សោយនៅឡើយ តែគំរោងដែលបានរៀបចំផែនការហើយត្រូវបានអនុវត្តន៏។ គណៈកម្មការអភិវឌ្ឍន៏ភូមិហើយនិងសមាគមន៏នៅតាមភូមិរបស់ឃុំ បានចូលរួមយ៉ាងសកម្មនៅក្នុង ដំណើរការធ្វើផែនការឃុំ ហើយបានជួយរួមចំណែកជាពលកម្មនិងថវិកា ដល់ការអនុវត្តន៏គំរោង ។

ប្រហែលជាការខកចិត្តរបស់សមាគមប្រជាជន លើទំនាក់ទំនងរបស់គេជាមួយនឹងសមាជិកក្រុមប្រឹក្សាឃុំ ឆ្លុះបញ្ចាំងពីការរំពឹងទុកដ៏ច្រើនរបស់គេទៅលើទំនាក់ទំនងនេះ ។ នៅក្នុងកម្មវិធីអភិវឌ្ឍន៏ចំរុះតាមសហគមន៏របស់អង្គការស៊ីដសេ មេដឹកនាំសមាគមន៏នៅតាមភូមិក្នុងឃុំច្រេសបានទទួលការបណ្តុះបណ្តាល និងចូលរួមក្នុងសិក្ខាសាលាជាច្រើន ហើយគ្រប់គ្រងគំរោងអភិវឌ្ឍន៏របស់គេផ្ទាល់ ។ ការមិនសប្បាយចិត្តរបស់គេចំពោះភាពយឺតយ៉ាវនៃការអភិវឌ្ឍន៏ បញ្ហាគណបក្សនយោបាយ ហើយនិងកង្វះតម្លាភាពពេញលេញ ។ ថ្វីបើភាពជាដៃគូនេះទើបតែនៅថ្មីថ្មោង និងស្ថិតក្នុងដំណាក់កាលសាកល្បងនៅឡើយក្តី ក៏ទំនាក់ទំនងការងាររវាងអាជ្ញាធមិ

មូលដ្ឋានហើយនឹងសមាគមប្រជាជន មានភាពល្អប្រសើរច្រើនដែលជាទីសង្ឃឹមសំរាប់ពេលអនាគត។ អង្គការស៊ីដសេ បង្កើតគណៈកម្មការអភិវឌ្ឍន៍ភូមិ ដើម្បីជួយពង្រឹងសំលេងរបស់សង្គមស៊ីវិលក្នុងការសហការការងារជាមួយនឹងក្រុមប្រឹក្សាឃុំ ។

*ទំនាក់ទំនងជាមួយនឹងអង្គការមិនមែនរដ្ឋាភិបាល*

ទាក់ទងជាមួយនឹងស៊ីដសេ ក្រុមប្រឹក្សាឃុំច្រេសបានសំរបសំរួលជាមួយនឹងស៊ីដសេក្នុងការធ្វើផែនការអភិវឌ្ឍន៍ភូមិ ហើយគេថែមទាំងបានធ្វើសមាហរណកម្មផែនការអភិវឌ្ឍន៍ចំរុះតាមសហគមន៍របស់ស៊ីដសេទៅក្នុងផែនការឃុំទៀតផង ។ លើសពីនេះទៀត ការងារអភិវឌ្ឍន៍របស់ស៊ីដសេនៅក្នុងឃុំច្រេសមានច្រើនជាងការងារដែលមាននៅក្នុងផែនការ ៥ឆ្នាំរបស់ឃុំ បើមើលជារួមការងាររបស់ស៊ីដសេ វាដូចគ្នាជាមួយនឹងកម្មវិធីរបស់ការងារអាជ្ញាធមិមូលដ្ឋានដែរ ។ ជាទូទៅអ្នកភូមិមិនអាចចែកដាច់ពីគ្នាថាតើគំរោងណាដែលស្ថិតនៅក្រោមផែនការរបស់ឃុំ ហើយគំរោងណាដែលស្ថិតនៅក្រោមផែនការរបស់ស៊ីដសេ ។ គេអាចមើលឃើញប្រការនេះច្បាស់ពីព្រោះគំរោងខ្លះនៅក្នុងផែនការរបស់ឃុំទទួលថវិកាពីស៊ីដសេ ។ នៅពេលជាមួយគ្នានោះ អាជ្ញាធមិខេត្តនិងស្រុកបានកែលំអរផ្លូវថ្នល់នៅក្នុងឃុំនេះមុនពេលបង្កើតក្រុមប្រឹក្សាឃុំទៅទៀត ហើយសមិទ្ធិផលទាំងនេះច្រើនតែគេយល់ថាជាលទ្ធផលនៃការងាររបស់ក្រុមប្រឹក្សាឃុំ ។ គេមើលឃើញច្បាស់ថាឃុំច្រេសមិនជាធំប៉ុន្មានទេ តែបានទទួលផលពីគំរោងអភិវឌ្ឍន៍ជនបទជាច្រើន ។ និយាយជារួមទៅសមិទ្ធិផលទាំងអស់នេះ វាបានមកពីការបំពេញអោយគ្នាទៅវិញទៅមករវាងអាជ្ញាធមិស្រុក ក្រុមប្រឹក្សាឃុំ អង្គការមិនមែនរដ្ឋាភិបាល និងទីភ្នាក់ងារអភិវឌ្ឍន៍នានា ។

នៅក្នុងកម្មវិធីឆ្នាំ ២០០៣-២០០៥ របស់ខ្លួនស៊ីដសេមានគោលបំណងមួយគឺ កសាងសមត្ថភាពរបស់ក្រុមប្រឹក្សាឃុំនៅក្នុងឃុំទាំង៧ នៅស្រុកជុំគីរី ។ នេះគឺជាការខិតខំមួយដើម្បីជួយដល់ដំណើរការអភិបាលកិច្ចមូលដ្ឋាន ។ ទោះបីជាមិនទាន់មានចក្ខុវិស័យយូរអង្វែងក៏ដោយ ស៊ីដសេបានអនុវត្តន៏កម្មវិធីអភិវឌ្ឍន៍សហគមន៍ចំរុះរបស់ខ្លួនតាមរយៈគណៈកម្មការអភិវឌ្ឍន៍ភូមិ ក្រុមជួយខ្លួនឯង ឬក្រុមឥណទាន ។ ស៊ីដសេថែមទាំងជួយក្រុមប្រឹក្សាឃុំនៅក្នុងការងារអភិវឌ្ឍន៍តាមរយៈមេភូមិ ។ ការជួយដល់សមាគមប្រជាជនតាមរយៈសមាគមភូមិ និងគណៈកម្មការអភិវឌ្ឍន៍ភូមិ ហើយការជួយដល់ដំណើរការអភិបាលកិច្ចមូលដ្ឋានតាម រយៈក្រុមប្រឹក្សាឃុំ និងមេភូមិ មិនមែនជាការងារដែលប្រឆាំងឬផ្ទុយគ្នានោះទេ តែទិសដៅយូរអង្វែងទៅមុខរបស់កម្មវិធីស៊ីដសេគឺមិនច្បាស់ចំពោះរឿងរ៉ាវខាងលើនេះ ។ មានសំណួរលើកឡើងជាច្រើនដូចជាៈ តើគេ (ស៊ីដសេ) មានបំណងកាត់បន្ថយថវិកាសំរាប់កម្មវិធីអភិវឌ្ឍន៍របស់គេផ្ទាល់ ហើយបង្កើនវិភាគទានដល់មូលនិធិឃុំឬ? តើគេមានបំណងរក្សាអោយមានតុល្យភាពជំនួយសំរាប់សមាគមប្រជាជន និង ជំនួយសំរាប់អាជ្ញាធមិមូលដ្ឋានឬ? តើគេបានចាត់វិធាន

ការគ្រប់គ្រាន់អ្វីខ្លះ ដើម្បីលើកកំពស់សមត្ថភាពរបស់សមាគមប្រជាជនទាំងនោះ អោយមានលទ្ធភាពអាចធ្វើអោយ ក្រុមប្រឹក្សាឃុំទទួលខុសត្រូវចំពោះទង្វើរបស់គេដែរឬទេ? តើគេយល់ច្បាស់ពីផលប្រយោជន៍នៃការទំនាក់ទំនងរវាងសមាគមប្រជាជននិងអាជ្ញាធមិមូលដ្ឋានទេ?

## ទំនាក់ទំនងជាមួយនឹងរដ្ឋាភិបាលហើយនិងគណបក្សនយោបាយ

នៅមុនពេលបោះឆ្នោតឃុំ អភិបាលស្រុកជុំគីរីសកម្មនៅក្នុងការកសាងផ្លូវថ្នល់នៅក្នុងស្រុក ។ នៅពេលដែលក្រុមប្រឹក្សាឃុំច្រេសត្រូវបានបង្កើតឡើងហើយ អភិបាលស្រុកជួយពេញលេញដល់សកម្មភាពអភិវឌ្ឍន៍នៅក្នុងឃុំ ។ អភិបាលស្រុកថែមទាំងធ្វើសហប្រតិបត្តិការជាមួយនឹងកម្មវិធីសីលា ហើយកោះប្រជុំរវាងបុគ្គលិកសីលាហើយនិងសមាជិកក្រុមប្រឹក្សាឃុំដើម្បីដោះស្រាយបញ្ហាដែលកើតមានឡើងនៅក្នុងការអនុវត្តន៍គំរោង ។ មន្ត្រីថ្នាក់ស្រុក តាមដានការអនុវត្តន៍គំរោងហេដ្ឋារចនាសម្ព័ន្ធដែលដំណើរការនៅក្នុងឃុំ ហើយឧស្សាហ៍ចុះជាមួយនឹងសមាជិកក្រុមប្រឹក្សាឃុំដើម្បីប្រមូលវិភាគទានបដិភាគរបស់ប្រជាជន ។ អ្នកគ្រប់គ្រងនៅថ្នាក់ខេត្តដែលមានការពាក់ព័ន្ធ ជាពិសេសអ្នកមកពីមន្ទីរកសិកម្ម ក៏បានចុះត្រួតពិនិត្យមើលគំរោងទំនប់ទឹកហើយនិងផ្លូវថ្នល់នៅក្នុងឃុំដែរ ។

ពិតមែនតែសមាជិកក្រុមប្រឹក្សាឃុំដែលមកពីគណបក្សនយោបាយធំទាំងបី មានទំនាក់ទំនងការងារជាមួយគ្នាបានជាប់លាប់ល្អក្តី តែការប្រកាន់តាមខ្សែគណបក្សនៅតែជាកត្តាចោទជាបញ្ហាក្នុងការអនុវត្តនីការងាររបស់ពួកគេ ។ មេឃុំហើយនិងសមាជិក២នាក់ដែលមកពីគណបក្សប្រជាជន ដែលជាគណបក្សមានសំលេងភាគច្រើនអាចសំរេចលើមតិរបស់សមាជិកពីរនាក់ទៀតដែលមកពីគណបក្សសំលេងភាគតិច ។ សមាជិកក្រុមប្រឹក្សាឃុំទាំងអស់ខិតខំបញ្ចុះបញ្ចូលអោយប្រជាជនកាន់ខាងគណបក្សរបស់គេ ។ តាមធម្មតា ប្រជាជនទាក់ទងនឹងសមាជិកក្រុមប្រឹក្សាឃុំដែលកាន់ខាងគណបក្សរបស់គេ ។ អភិបាលស្រុកបាននិយាយថាមានការគាបសង្កត់ពីមន្ត្រីគណបក្សដើម្បីជាប្រយោជន៍ដល់គណបក្ស ដែលនាំអោយសមាជិកក្រុមប្រឹក្សាធ្វើការប្រមូលវិភាគទាន បដិភាគពីអ្នកភូមិ សូម្បីតែនៅក្នុងរដូវខ្វះស្បៀងក៏ដោយ ។

**ឧបសម្ព័ន្ធ ៤**

**ករណីសិក្សាទី ៩**

## ឃុំផ្ទះរុង ស្រុកក្រវ៉ាញ

## ខេត្តពោធិសាត់

### ត្រូវបានជ្រើសរើស និងជួយដោយផែន ដើម្បីអភិបាលកិច្ចមូលដ្ឋាន (PLG)

**ប្រវត្តិ**

ផ្ទះរុង គឺជាឃុំមួយនៅក្នុងចំណោមឃុំចំនួន៧នៅក្នុងភ្នំស្រុកក្រវ៉ាញខេត្តពោធិសាត់ ។ ឃុំផ្ទះរុងមានភូមិទាំងអស់ចំនួន ១៣ ។ ប្រភពចំណូលសំខាន់របស់អ្នកភូមិគឺ ការធ្វើស្រែនិងការដាំដំណាំលក់ដូចជា ឪឡឹក សណ្ដែកដី និងពោត ។ ក្រៅពីនេះ អ្នកភូមិទៅបោចវល្លិ ផ្ដៅ បេះក្រវាញនិងរើសថ្មកែវលក់ ។ នៅក្នុងរយៈពេល ៣ឆ្នាំកន្លងទៅនេះ កសិករជួបប្រទះនូវគ្រោះរាំងស្ងួត និងធ្វើស្រែមិនបានផល ។ អ្នកខ្លះត្រូវបង្ខំចិត្តលក់ដីស្រែ ហើយទៅធ្វើការនៅតំបន់ព្រំដែនខ្មែរ-ថៃ ។ សេចក្ដីត្រូវការចាំបាច់របស់គេគឺប្រព័ន្ធធារាសាស្ត្រ ទំនប់ប្រឡាយ និងទ្វារទឹក ។ ដោយនៅក្នុងតំបន់នោះមានស្ទឹង គេអាចធ្វើអាងស្តុកទឹកបាន ។

នៅក្នុងឆ្នាំ ១៩៩៦ អង្គការ UNDP/CARERE បានជួយកម្មវិធីសីលាដោយបង្កើតអោយមានគណៈកម្មការអភិវឌ្ឍន៍ភូមិនៅក្នុងឃុំ ។ សមាគមនានានៅតាមភូមិដូចជាក្រុមផលិតកម្ម ក្រុមចិញ្ចឹមសត្វ ហើយនិងក្រុមឥណទានខ្នាតតូចក៏ត្រូវបានបង្កើតឡើង ។ ក្រុមផលិតកម្មទទួលបានគ្រាប់ពូជស្រូវ ជ្រូក មាន់ ជីគីមីហើយនិងការបណ្ដុះបណ្ដាលកសិកម្ម ។ សីលាជួយកសាងសាលារៀន ធ្វើផ្លូវថ្នល់ ធ្វើស្ពាននៅក្នុងឃុំ ។ អង្គការមិនមែនរដ្ឋាភិបាល ហើយនិងទីភ្នាក់ងារអភិវឌ្ឍន៍ក៏បានផ្ដល់ជំនួយផងដែរ ។ អង្គការ Concern Worldwide បានជួយធ្វើផ្លូវថ្នល់ ចាក់លូ ជីកអណ្ដូង ហើយនិងផ្ដល់ក្របី ។ អង្គការ RACHA បានផ្ដល់ឥណទាន និងការបណ្ដុះបណ្ដាលលើការពន្យាកំណើត ការចាក់ថ្នាំការពារ ហើយនិងការ លើកកំពស់ការយល់ដឹងនិងការការពារជំងឺអេដស៍ ។ អង្គការកម្មវិធីស្បៀង អាហារពិភពលោកជួយគាំពារស្បៀងពលកម្មនៅក្នុងការកសាងផ្លូវ។

នៅក្នុងឆ្នាំ ២០០១ UNDP បានបង្កើតគំរោងដៃគូសំរាប់អភិបាលកិច្ចមូលដ្ឋាន (PLG) ដើម្បីជួយដំណើរការវិមជ្ឈការ ។ នៅផ្ទះរុង PLG ធ្វើការជាមួយនឹងក្រុមសំរបសំរួលថ្នាក់ស្រុករបស់សីលាដើម្បីជួយក្រុមប្រឹក្សាឃុំនៅក្នុងការធ្វើផែនការនិងអនុវត្តន៍គំរោង ។

ក្រុមប្រឹក្សាឃុំផ្ទះរុងមានសមាជិក ១១នាក់គឺ ៨នាក់មកពីគណបក្សប្រជាជន ២នាក់មកពីគណបក្សហ៊្វុនស៊ិនប៉ិច និងម្នាក់មកពីគណបក្សសមរង្ស៊ី ។ មេឃុំមកពីគណបក្សប្រជាជន ។ មានសមាជិកក្រុមប្រឹក្សាឃុំម្នាក់ជានារី ។ ស្មៀនឃុំបានជួយការងាររដ្ឋបាលដល់ក្រុមប្រឹក្សា ។

## រដ្ឋបាលឃុំ

*ការប្រែប្រួលតាំងពីការបង្កើតក្រុមប្រឹក្សាឃុំ*

តាំងពីការបោះឆ្នោតឃុំនៅក្នុងខែកុម្ភៈឆ្នាំ ២០០២មក សមាជិកក្រុមប្រឹក្សាឃុំបានកត់សំគាល់ឃើញចំណុចប្លែកមួយចំនួននៅក្នុងរដ្ឋបាលឃុំ ។ នៅមុនពេលបោះឆ្នោត រដ្ឋអំណាចឃុំមានមនុស្សបីនាក់ដែលសុទ្ធតែមកពីគណបក្សសំលេងភាគច្រើន ។ មេឃុំអាចសំរេចលើអ្វីៗសព្វបែបយ៉ាងតែម្នាក់ឯង ហើយទទួលខុសត្រូវតែចំពោះមុខមន្ត្រីថ្នាក់លើដែលតែងតាំងគាត់តែប៉ុណ្ណោះ ។ រដ្ឋអំណាចឃុំមិនមានមុខងារចែងច្បាស់ពីការទទួលខុសត្រូវរបស់គេទេ ហើយមិនមានផែនការច្បាស់លាស់ទេ ។ លទ្ធផលនៃការងាររបស់គេមិនមានតម្លាភាព ។ ក្រោយការបោះឆ្នោត ក្រុមប្រឹក្សាឃុំមានសមាជិកចំនួន ១១នាក់ដែលមកពីគណបក្សបីផ្សេងគ្នា ។ សមាជិកក្រុមប្រឹក្សាឃុំបានប្រកាសថា មេឃុំឥឡូវសំរេចអ្វីដោយឆ្លងការពិភាក្សាជាមួយនឹងសមាជិកដទៃទៀតនៃក្រុមប្រឹក្សា ។ សមាជិកក្រុមប្រឹក្សាឃុំមានមុខងារទទួលខុសត្រូវច្បាស់លាស់ហើយការងាររបស់ក្រុមប្រឹក្សាឃុំមានតម្លាភាព ។

តំណាងរបស់អង្គការប្រជាជនដែលមកពីភូមិផ្សេងៗដែលត្រូវបានសំភាសន៍ បានគាំទ្រគំនិតអោយមានក្រុមប្រឹក្សាឃុំនេះ ។ គេបាននិយាយថានៅក្នុងអតីតកាល រដ្ឋអំណាចឃុំស្ថិតនៅក្រោមតែគណបក្សមួយ ហើយថាការ សំរេចចិត្តនានាមានការលំអៀងទៅរកគណបក្សនោះ ដូច្នេះមន្ត្រីឃុំប្រើប្រាស់អំណាចរបស់គេមិនត្រឹមត្រូវទេ ។ ឧទាហរណ៍: គេសំរេចចិត្តលើបញ្ហាអភិវឌ្ឍន៍ ដោយយោលតាមការបង្គាប់ពីរដ្ឋអំណាចថ្នាក់លើ។ ការសំរេចចិត្តបែបនេះច្រើនត្រូវបានផាត់អ្នកក្រចេញពីការទទួលផលប្រយោជន៍ ។ ក្រោយពីការបង្កើតក្រុមប្រឹក្សាឃុំមក ការចូលរួមនៅក្នុងការសំរេចចិត្តកាន់តែមានច្រើន ហើយសេចក្តីសំរេចផ្អែកលើការពិភាក្សាគ្នានៅក្នុងចំណោមសមាជិកក្រុមប្រឹក្សាឃុំដែលមកពីគណបក្សខុសគ្នា ការលំអៀងមានការកាត់បន្ថយ ហើយអំណាចត្រូវបានគេប្រើបានសមស្របជាងមុន ។ ការរៀបចំផែនការលើការអភិវឌ្ឍន៍ត្រូវបានធ្វើ ដោយមានការចូលរួមរបស់ប្រជាជន ហើយអាទិភាពត្រូវបានកំណត់ទៅតាមសេចក្តីត្រូវការ ។ ឧទាហរណ៍ ទោះបីជាភូមិដែល

មេឃុំរស់នៅស្នើសុំផ្លូវថ្នល់ក្តី តែគំរោងធ្វើផ្លូវត្រូវបានកំណត់សំរាប់ភូមិផ្សេងទៀតដែលត្រូវការជាង ។ ពីមុនមេឃុំជាអ្នកសំរេចតែម្នាក់ឯង ហើយសំរេចអោយទៅភូមិរបស់គាត់ច្រើនជាងគេ ។

*ស្នាដៃការងារ*

តាំងពីបានបង្កើតក្រុមប្រឹក្សាឃុំមក ពួកគេបានទទួលការបណ្តុះបណ្តាលពីសីលាហើយនិង POLA ។ ការបណ្តុះបណ្តាលនេះមាន វគ្គស្តីពីវិមជ្ឈការ ប្រព័ន្ធហិរញ្ញវត្ថុ ដំណើរការធ្វើផែនការ៥ឆ្នាំ ការរៀបចំនិងការអនុវត្តន៍គំរោង និតិវិធីដេញថ្លៃ ហើយនិងការធ្វើផែនការលើការវិនិយោគ ។ ក្រុមប្រឹក្សាបានសុំការបណ្តុះបណ្តាលបន្ថែមទៀតទាក់ទងនឹងតួនាទីនិងការទទួលខុសត្រូវរបស់គេ ហើយនិងទិដ្ឋភាពផ្នែកច្បាប់លើជំលោះដីធ្លីហើយនិងអំពើហិង្សានៅក្នុងគ្រួសារ ។ ក្រុមប្រឹក្សាឃុំប្រជុំរាល់ខែហើយសំរេចចិត្តតាមរយៈការលើកដៃ ។ សមាជិកក្រុមប្រឹក្សាបាននិយាយថាគេធ្វើការទាំងអស់គ្នា ហើយការសំរេចចិត្តរបស់គេផ្អែកទៅលើផលប្រយោជន៏របស់ប្រជាជនមិនមែនលើគណបក្សរបស់គេទេ ។ ការសំភាសន៏ដោយឡែកមួយជាមួយនឹងសមាជិកក្រុមប្រឹក្សាឃុំដែលមកពីគណបក្សហ៊្វុនស៊ិនប៉ិចមិនបានបង្ហាញអោយឃើញអ្វីផ្ទុយពីនេះទេ ទោះបីជាបញ្ហានយោបាយមានកើតឡើងរវាងគណបក្សមានសំលេងភាគច្រើន និងអ្នកមានសំលេងភាគតិចក្តី ។

ក្រុមប្រឹក្សាឃុំបានអោយដឹងថា ខ្លួនបានផ្ញើរបាយការណ៍ទៅអោយអភិបាលស្រុកនិងអភិបាលខេត្ត សីលានិង POLA ហើយនិងមេភូមិ ។ សមាជិកក្រុមប្រឹក្សាឃុំនិយាយថា មេភូមិជាអ្នកផ្សព្វផ្សាយពតិមានទាក់ទងនឹងឃុំ ហើយនិងបទបញ្ជាពីរដ្ឋាភិបាលដែលគេទទួលបានទៅដល់ប្រជាជននៅពេលមានការប្រជុំនៅក្នុងភូមិ ។ ក្រុមប្រឹក្សា ឃុំផ្ទះរុងមិនបាននិយាយពីការចេញ ឬអនុម័តដីការឃុំទេ ។ តំណាងពីអង្គការប្រជាជនដែលត្រូវបានសំភាសន៏បាន និយាយថាសមាជិកក្រុមប្រឹក្សាឃុំ មិនដែលរាយការណ៍ដោយផ្ទាល់ពីសកម្មភាពរបស់គេទៅប្រជាជនទេ ។ គេគ្រាន់តែផ្តល់ពតិមានតាមរយៈគណកម្មាធិការអភិវឌ្ឍន៏ភូមិ ។ ប៉ុន្តែ សមាជិកក្រុមប្រឹក្សាឃុំ បានចូលរួមនៅក្នុងការប្រជុំនៅតាមភូមិ បើសិនជាមានការអញ្ជើញ ។

*ទស្សនះរបស់ប្រជាជនក្នុងភូមិ*

ដើម្បីយល់អោយច្បាស់ពីទស្សនះរបស់អ្នកភូមិ ក្រុមអ្នកស្រាវជ្រាវបានសំភាសប្រជាជននៅក្នុងភូមិចំនួនបីស្ថិតនៅក្នុងភូមិសាស្ត្រខុស១គ្នាក្នុងឃុំនេះ គឺភូមិដំណាក់កន្សែង បត់រំដួល និង កោះស្វាយ ។

ជាទូទៅ ក្រុមប្រជាជននៅក្នុងភូមិដំណាក់កន្សែងគិតថាមិនមានការប្រែប្រួលអ្វីច្រើនទេ ចាប់តាំងពីការបោះឆ្នោតឃុំមក ។ សំណើរសុំថវិការសំរាប់គំរោងនៅតាមភូមិនៅតែត្រូវសំរេចដោយថ្នាក់លើ ។ ក្រុមដែលត្រូវ

បានសំភាសន៍ទាំងអស់ មិនបានបង្ហាញអោយដឹងថាគេបានចូលរួមនៅក្នុងការប្រជុំធ្វើផែនការទេ ។ អ្នកភូមិខ្លះបានចូលរួមនៅក្នុងគំរោងស្បៀងពលកម្មដែលធ្វើផ្លូវថ្នល់ យោលទៅតាមចំលើយពីប្រធានភូមិ ហើយគាត់ថាគំរោងនេះគឺជាផ្នែកមួយនៃផែនការរបស់ឃុំ ។ គណៈកម្មការអភិវឌ្ឍន៍ភូមិ បានចូលរួមប្រជុំជាមួយនឹងក្រុមប្រឹក្សាឃុំដើម្បីពិភាក្សាពីគំរោងធ្វើផ្លូវថ្នល់ តែជាទូទៅ នៅពេលដែលគំរោងត្រូវបានអនុម័តហើយនោះ ពួកគេកំរបានចូលរួមប្រជុំណាស់ ។ យ៉ាងហោចណាស់មានពីរក្រុមបាននិយាយថា ក្រុមប្រឹក្សាឃុំបានផ្តល់ថវិកាសំរាប់កសាងអាគារនៅក្នុងវត្ត ។

ក្រុមជាច្រើនដែលត្រូវបានសំភាសន៍នៅភូមិដំណាក់កន្សែងបាននិយាយថា ក្រុមប្រឹក្សាឃុំមិនរាយការណ៍ប្រាប់ប្រជាជននៅក្នុងភូមិទេ ដូច្នេះប្រជាជនមិនដឹងថាតើក្រុមប្រឹក្សាធ្វើអ្វីទេ ។ មានមួយក្រុមបាននិយាយថាគេបានដឹងពីការហាមកាប់ឈើកាលពីគេចូលទៅក្នុងព្រៃ ។ ជាច្រើនក្រុមចង់អោយក្រុមប្រឹក្សាដោះស្រាយចំពោះបញ្ហាខ្វះស្បៀងដែលបណ្តាលមកពីភាពរាំងស្ងួត ។ អ្នកខ្លះគិតថាសមាជិកក្រុមប្រឹក្សាឃុំគួរចុះមើលប្រជាជនអោយបានញឹកញាប់បន្តិច ។ អ្នកឆ្លើយខ្លះនិយាយថាមានការប្រជុំច្រើនដងដែរនៅក្នុងភូមិនៅក្នុងអំឡុងពេលយុទ្ធនាការបោះឆ្នោត ។ តែក្រោយមកកំរឃើញសមាជិកក្រុមប្រឹក្សាឃុំចុះមកដោះស្រាយបញ្ហាណាស់ នៅពេលជួបការពិបាកប្រជាជនច្រើនទៅពឹងពាក់ប្រធានភូមិ ។ មិនមានសមាជិកក្រុមប្រឹក្សាឃុំរស់នៅក្នុងភូមិនេះទេ ។

ជារួម ក្រុមប្រជាជនដែលត្រូវបានសំភាសន៍ នៅភូមិបត់រំដួលមិនឃើញមានការប្រែប្រួលនៅក្នុងស្ថានភាពនៅមុននិងក្រោយការបោះឆ្នោតឃុំទេ ។ ក្រុមភាគច្រើនមិនដឹងពីអ្វីដែលក្រុមប្រឹក្សាឃុំធ្វើ ។ អ្នកខ្លះទៀតមិន ទាំងដឹងថាមានសមាជិកក្រុមប្រឹក្សាឃុំរស់នៅក្នុងភូមិរបស់គេផង ។ មានពីរ បីក្រុមប្រជាជនដែលត្រូវបានសំភាសន៍បានចូលរួមនៅក្នុងការធ្វើផែនការឃុំនៅឯវត្ត ។ ក្រុមផ្សេងទៀតមិនបានចូលរួមទេ ។ តែក្រុមខ្លះដឹងថាផ្លូវថ្នល់ដែលបានសាងសង់គឺជាផ្នែកមួយនៃផែនការឃុំ ។ អ្នកខ្លះទៀតមិនត្រូវបានគេប្រាប់អោយដឹង ពីគំរោងដែលត្រូវបានធ្វើតាមផែនការ ហើយមិនបានបង់វិភាគទានបដិភាគ ជាលុយឬជាពលកម្មទេ ។

ស្ទើរតែគ្រប់ក្រុមទាំងអស់ដែលត្រូវបានសំភាសន៍នៅភូមិបត់រំដួលបាននិយាយថា គេមិនដឹង មិនឃើញឬឮរបាយការណ៍ពីក្រុមប្រឹក្សាឃុំទេ ។ គេមិនដឹងពីបទបញ្ជាឬការណែនាំដែលចេញមកពីក្រុមប្រឹក្សាទេ ។ មានច្រើននាក់ណាស់ដែលរំពឹងមកលើក្រុមប្រឹក្សាឃុំអោយជួយដោះស្រាយបញ្ហាខ្វះស្បៀង តាមរយៈការផ្តល់គ្រាប់ពូជ ជី និងម៉ាស៊ីនបូមទឹក តែមិនបានដូចបំណងទេ ។ ផ្ទុយទៅនឹងប្រជាជនភាគច្រើនដែលត្រូវបានសំភាសន៍មានក្រុមពិសេសមួយមានការយល់ច្បាស់ហើយសរសើរសកម្មភាពផលិតកក្សកសិកម្មរបស់សីលា និងសកម្មភាពគំរោងស្បៀងពលកម្មរបស់អង្គការកម្មវិធីស្បៀងអាហារពិភពលោក នៅក្នុងការកសាងផ្លូវហើយនិងស្ពាន ។

ក្រុមនេះមានការយល់ច្បាស់ពីសមិទ្ធិផលរបស់ក្រុមប្រឹក្សាឃុំ ហើយនិងការប្រែប្រួលដែលកើតមាននៅក្រោមរដ្ឋបាលនៃក្រុមប្រឹក្សានេះ ។

ក្រុមប្រជាជនដែលត្រូវបានសំភាសន៍នៅភូមិកោះស្វាយ យល់ឃើញថាមានការប្រែប្រួលបានកើតឡើងតាំងតែពីការបោះឆ្នោតឃុំមក ។ ក្រុមខ្លះនិយាយថាមេឃុំឥឡូវមានការទាក់ទងច្រើនជាមួយនឹងអង្គការអភិវឌ្ឍន៍ស្ថាប័នរដ្ឋ ហើយការនេះនាំអោយមានការកសាងផ្លូវថ្នល់ និងសាលារៀន ។ ក្រុមផ្សេងទៀតនិយាយថាសមាជិកក្រុមប្រឹក្សាក្នុងនាមជាមន្ត្រីជាប់ឆ្នោតធ្វើការដោយស្មោះត្រង់ ហើយមានការយកចិត្តទុកដាក់ចំពោះសន្តិសុខ និងសុខុមាលភាពរបស់ប្រជាជន ។ អ្នកខ្លះនិយាយថា ឥឡូវនេះប្រជាជនមានការចូលរួមនៅក្នុងការធ្វើផែនការអភិវឌ្ឍន៍ ។ សូមបញ្ជាក់ថា មេឃុំរស់នៅក្នុងភូមិកោះស្វាយ ។

ក្រុមប្រជាជនខ្លះនៅភូមិកោះស្វាយបាននិយាយថា ក្រុមប្រឹក្សាឃុំបានជំរាបប្រាប់ប្រជាជនពីការសំរេចចិត្តរបស់គេនៅក្នុងអង្គប្រជុំ ។ ឧទាហរណ៍ នៅក្នុងការប្រជុំនេះប្រជាជនបានដឹងពីផែនការស្តារប្រឡាយ ហើយនិងការហាមកាប់ឈើ ។ ប៉ុន្តែ គេដឹងតិចតួចពីការងារជាក់ស្តែងរបស់ក្រុមប្រឹក្សាឃុំ ។

## សកម្មភាពធ្វើផែនការនិងអនុវត្តន៍

*ដំណើរការធ្វើផែនការ*

ក្រុមប្រឹក្សាឃុំផ្ទះរុងបាននិយាយថា គេបានដើរតាមជំហ៊ានទាំង ១១ នៅក្នុងការតាក់តែងផែនការឃុំ ។ សីលាហើយនិងក្រុមសំរបសំរួលថ្នាក់ស្រុកបានជួយសំរបសំរួលដំណើរការនេះ ក្នុងនោះមានការសិក្សាវាយតំលៃពីសេចក្តីត្រូវការរបស់ប្រជាជនដោយមានការចូលរួមពីប្រជាជននៅក្នុងភូមិចំនួន ១៣របស់ឃុំ ។ គំរោងជាអាទិភាពនៅក្នុងផែនការឃុំរួមមានការកសាងសាលារៀន ធ្វើផ្លូវថ្នល់ ស្ពាន ទំនប់ ប្រឡាយ ទ្វារទឹក ការអប់រំសុខភាព ការការពារជំងឺអេដស៍ ការកាត់បន្ថយអំពើហឹង្សា ការបណ្តុះបណ្តាលវិជ្ជាជីវៈសំរាប់អ្នកក្រ ឥណទានសាច់ប្រាក់ ឥណទានជារបស់ (ជ្រូក មាន់ សត្វពាហនៈ) ពូជស្រូវ ដើមឈើហូបផ្លែ ហើយនិងការជួយដល់មុខរបរតូចតាច ។ ការសរសេរផែនការគឺត្រូវបានធ្វើដោយក្រុមប្រឹក្សាឃុំ និងមានការជួយជ្រោមជ្រែងពីសីលាហើយនិង POLA ។

គណៈកម្មាធិការរៀបចំផែនការនិងថវិកា ជួយបំផុសអោយប្រជាជនចូលរួមនៅក្នុងដំណើរការធ្វើផែនការ។ នៅក្នុងគណៈកម្មាធិការនេះមានមេភូមិចំនួន ១៣នាក់ដោយមានមេឃុំធ្វើជាប្រធាន ។ សមាជិកគណៈកម្មាធិការនេះ ទទួលបានការបណ្តុះបណ្តាលលើការរៀបចំផែនការនិងគ្រប់គ្រងថវិកា ពីសីលា ។ ក្រោយពីបើកការប្រជុំធ្វើផែន ការនៅតាមថ្នាក់ភូមិ សមាជិកគណៈកម្មាធិការ បានបូកសរុបផែនការភូមិនៅ

ថ្នាក់ឃុំ ។ នៅពេលគេសំរេចយកជាចុងក្រោយលើផែនការឃុំហើយ គណៈកម្មាធិការវិលត្រឡប់ទៅភូមិវិញ ដើម្បីជំរាបប្រាប់ប្រជាជនពីលទ្ធផល ។ គេថែមទាំងដើរប្រមូលវិភាគទានបដិភាគរបស់អ្នកភូមិ ។ ថវិកាសំរាប់គំរោងអាទិភាពនៅក្នុងផែនការ ៥ឆ្នាំ របស់ឃុំ ត្រូវបានកំណត់ចែកចាយរាល់ឆ្នាំ ។ នៅក្នុងពេលជាមួយគ្នានោះ គណៈកម្មាធិការស្វែងរកជំនួយលុយកាក់សំរាប់គំរោងពីអង្គការអភិវឌ្ឍន៍នានា ដូចជាអង្គការ Concern Worldwide ហើយនិងអង្គការស្បៀងអាហារពិភពលោក ។

*ការអនុវត្តន៍ការងារ*

នៅក្នុងឆ្នាំ ២០០២ គំរោងអភិវឌ្ឍន៍ឃុំត្រូវបានអនុវត្តន៍នៅក្នុងភូមិចំនួន ១១ នៅឃុំផ្ទះរុង ។ ជាទូទៅគឺជាគំរោងផ្នែកហេដ្ឋារចនាសម្ព័ន្ធ ដូចជាអណ្តូងទឹក ផ្លូវថ្នល់ សាលារៀនហើយនិងបំពង់បង្ហូរ ។ ក្នុងមួយឆ្នាំភូមិមួយទទួលបានតែគំរោងអាទិភាពមួយទេ ។ ថវិកាត្រូវបានដកពីរតនាគារខេត្តពោធិសាត់ ដើម្បីយកទៅប្រើសំរាប់គំរោងរបស់សីលានិងរបស់រដ្ឋ ។ គំរោងនៅក្នុងផែនការដែលទទួលថវិកាពីអង្គការកម្មវិធីស្បៀងអាហារពិភពលោក ហើយនិង Concern Worldwide ត្រូវបានដំណើរការដោយផ្ទាល់ដោយអង្គការទាំងនេះ ។ នៅក្នុងឆ្នាំ ២០០៣ ឃុំបានទទួលប្រាក់ចំនួន ៤១.២៥លានរៀលសំរាប់គំរោងអភិវឌ្ឍន៍ ។ គំរោងទាំងនេះច្រើនតែជាគំរោងហេដ្ឋារចនាសម្ព័ន្ធតូចៗ ។ សីលាដោយមានការជួយរបស់ PLG បានដាក់សំណើសុំសំរាប់ឃុំនូវទំនប់ទឹកមួយទៅរដ្ឋាភិបាល ពីព្រោះទំនប់ទឹកហួសពីសមត្ថភាពរបស់ថវិកាខេត្ត ។

នៅពេលគេសំរេចលើគំរោងអាទិភាពហើយ ក្រុមសំរបសំរួលថ្នាក់ស្រុកជួយសំរួលដំណើរការដេញថ្លៃជាមួយនឹងអ្នកម៉ៅការដែលមានការយល់ព្រមជាមុនពីអាជ្ញាធមិខេត្ត ។ បន្ថែមពីលើនេះ បុគ្គលិកសីលាផ្តល់ជំនួយបច្ចេកទេសដើម្បីធ្វើយ៉ាងណាអោយគំរោងសាងសង់ត្រូវបានបំពេញទៅតាមកំរិតបទដ្ឋាន ។ ថវិកាកំណត់សំរាប់ចាយវាយនោះមិនត្រូវបានគេធ្វើតាមគោលការណ៍កំណត់នោះទេ ពោលគឺគេច្រើនតែដកថវិកាពីគំរោងមួយទៅគំរោងមួយទៀត ។ ការប្រមូលវិភាគទានបដិភាគពីអ្នកភូមិនៅពេលខ្លះមានការពិបាក ។ អនុគណៈកម្មាធិការត្រូវបានបង្កើតឡើងដើម្បីថែទាំគំរោងដែលត្រូវបានអនុវត្តន៍ ដោយសារមិនមានថវិកាសំរាប់ការថែទាំនិងជួសជុល។ ចំណែកឯអង្គការមិនមែនរដ្ឋាភិបាលហើយនិងទីភ្នាក់ងារអភិវឌ្ឍន៍ គេតាមដានមើលគំរោងរបស់គេផ្ទាល់ ។

អ្នកដែលត្រូវបានសំភាសន៍ភាគច្រើនបាននិយាយថា ប្រជាជននៅក្នុងមូលដ្ឋានបានទទួលផលពីគំរោងនេះ ពោលគឺសោហ៊ុយលើការដឹកជញ្ជូនមានការថយចុះ ហើយសកម្មភាពលក់ដូរនៅទីផ្សារក៏មានការកើនឡើង ។ សាលារៀនថ្មីៗផ្តល់ជាប្រយោជន៍ដល់កូនអ្នកភូមិ ។ ការជីកអណ្តូងផ្តល់ទឹកដល់គ្រួសារនៅក្នុងភូមិ ។ ពិតមែនតែគ្រួសារទាំងអស់នៅក្នុងឃុំ មិនទទួលបានប្រយោជន៍ស្មើគ្នាក្តី តែគំរោងទាំងនេះពិតជាបានរួមចំណែកដល់ការអភិវឌ្ឍន៍ឃុំជារួម ។

## ភាពជាដៃគូរវាងក្រុមប្រឹក្សាឃុំហើយនិងសង្គមស៊ីវិល

*ទំនាក់ទំនងជាមួយនឹងអង្គការនានានៅតាមភូមិ*

ទំនាក់ទំនងរបស់ក្រុមប្រឹក្សាឃុំផ្ទះរុងជាមួយនឹងបណ្តាសមាគមនៅតាមភូមិ នៅខ្សោយនៅឡើយ ។ ការនេះដោយសារក្រុមប្រឹក្សាឃុំច្រើនធ្វើការតាមរយៈមេភូមិ ហើយមិនសូវចុះតាមភូមិដោយផ្ទាល់ទេ ។ ជាទូទៅ ទំនាក់ទំនងរបស់ក្រុមប្រឹក្សាឃុំជាមួយនឹងក្រុមមនុស្សនៅតាមភូមិ មានភាពប្រហាក់ប្រហែលនឹងទំនាក់ទំនងរវាងអ្នកភូមិនិងរដ្ឋអំណាចឃុំកាលពីអតីតកាលដែរ ។ អ្នកភូមិភាគច្រើនមើលមកក្រុមប្រឹក្សាឃុំថា ស្ថិតនៅឆ្ងាយពីពួកគេ ទោះបីជាថាក្រុមប្រឹក្សាឥឡូវនេះមានការចូលរួមច្រើន នៅក្នុងការកសាងគំរោងហេដ្ឋារចនាសម្ព័ន្ធក្តី ។ ពិតមែនតែក្រុមប្រឹក្សាឃុំ បានអញ្ជើញសមាជិកគណៈកម្មការអភិវឌ្ឍន៍ភូមិអោយចូលរួមការប្រជុំធ្វើផែនការ ហើយបានពឹងអាស្រ័យមកលើពួកគេក្នុងការប្រមូលថវិកាបដិភាគក្តី ក៏ក្រុមប្រឹក្សាចាត់ទុកគណៈកម្មការអភិវឌ្ឍន៍ភូមិត្រឹមតែជាអន្តរការីប៉ុណ្ណោះ ជាជាងដៃគូពិតប្រាកដ ។ ជាទូទៅ អ្នកភូមិបានចូលរួមតែនៅដំណាក់ចុងបញ្ចប់ប៉ុណ្ណោះ ពោលគឺនៅពេលដែលគេសុំអោយ ពួកគាត់ជួយចូលរួមចំណែកក្នុងគំរោងដែលត្រូវបានថ្នាក់លើគេសំរេចហើយ ។ រហូតមកដល់ពេលនេះ ក្រុមប្រឹក្សាឃុំផ្ទះរុងមិនបានខិតខំអោយបានខ្លាំងក្លា នៅក្នុងការជំរុញអោយអ្នកភូមិចូលរួម នៅក្នុងការងារអភិបាលកិច្ចមូលដ្ឋាន ឬក្នុងការរៀបចំនិងអនុវត្តន៍ផែនការអភិវឌ្ឍន៍ទេ ។

*ទំនាក់ទំនងជាមួយនឹងអង្គការមិនមែនរដ្ឋាភិបាល*

ក្រុមប្រឹក្សាឃុំស្វែងរកជំនួយពីអង្គការមិនមែនរដ្ឋាភិបាលដើម្បីដំណើរការងារគំរោង និងសំរបសំរួលជាមួយអង្គការមិនមែនរដ្ឋាភិបាលដើម្បីកុំអោយមានការជាន់សកម្មភាពគ្នា ។ តែទោះបីមានការសហការ និងសំរបសំរួលល្អរវាងភាគីទាំងពីរក្តី គេមិនទាន់ឃើញមានភាពជាដៃគូពិតប្រាកដកើតមានទេ ។ ការរកថវិកាអនុវត្តន៍គំរោងនិងការតាមដានរបស់ក្រុមប្រឹក្សាឃុំហើយនិងអង្គការមិនមែនរដ្ឋាភិបាលគឺធ្វើដូចគ្នា ។ ផ្ទុយទៅវិញ ក្រុមប្រឹក្សាឃុំមានទំនាក់ទំនងរឹងមាំជាមួយនឹងកម្មវិធីសីលាដែលទទួលថវិកាពី PLG ។ សីលាបានផ្តល់មិនត្រឹមតែជំនួយបច្ចេកទេសដល់ការធ្វើផែនការនិងអនុវត្តន៍ប៉ុណ្ណោះទេ តែថែមទាំងបានបង្កើតគណៈកម្មការអភិវឌ្ឍន៍ភូមិ និងរួមចំណែកធនធានច្រើនដល់ការអភិវឌ្ឍន៍កសិកម្ម និងគំរោងហេដ្ឋារចនាសម្ព័ន្ធតូចៗថែមទៀតផង ។ វត្តមានរបស់សីលានៅក្នុងឃុំមានន័យថា គំរោងនិងឥទ្ធិពលរបស់អង្គការមិនមែនរដ្ឋាភិបាលមិនសូវសំខាន់ណាស់ណាទេ ។ ប៉ុន្តែដោយសារជាកម្មវិធីរបស់រដ្ឋាភិបាល ហើយអនុវត្តន៍ដោយបុគ្គលិករដ្ឋាភិបាល ដូចនេះ សីលាមិនសូវជាមានសំភារៈនិងឆន្ទៈក្នុងការបង្កើតសង្គមស៊ីវិលនៅក្នុងភូមិ ឬជំរុញអោយមានភាពជាដៃគូជាមួយនឹងបណ្តាអង្គការមិនមែនរដ្ឋាភិបាលនៅក្នុងឃុំទេ ។

**ទំនាក់ទំនងជាមួយនឹងរដ្ឋាភិបាលថ្នាក់លើ និងគណបក្សនយោបាយ**

ទំនាក់ទំនងរបស់ក្រុមប្រឹក្សាឃុំផ្ទះរុងជាមួយនឹងអាជ្ញាធមិខេត្តនិងស្រុកគឺមានភាពរឹងមាំល្អ ។ ការនេះគឺដោយសារកម្មវិធីសីលាបានផ្តល់ជំនួយអភិវឌ្ឍន៍ដល់ឃុំតាំងពីឆ្នាំ ១៩៩៦ ហើយផ្តល់បច្ចេកទេសដល់ក្រុមប្រឹក្សាឃុំតាំងពីក្រុមប្រឹក្សានេះត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ ២០០២ ។ គំរោងរបស់ UNDP/CARERE បានជួយសីលាពីឆ្នាំ ១៩៩៦ ដល់ ២០០១ ហើយគំរោង UNDP/PLG បានជួយដល់សីលាតាំងពីឆ្នាំ ២០០១ ។

ក្រុមប្រឹក្សាឃុំរួមមានសមាជិកមកពីគណបក្សធំៗទាំងបី តែគណបក្សប្រជាជនមានសំលេងលើសលុប ។ ជាទូទៅសមាជិកក្រុមប្រឹក្សាឃុំខិតខំជំនះការខ្វែងគំនិតគ្នា តាមខ្សែគណបក្សដើម្បីបំរើផលប្រយោជន៍របស់រាស្ត្រ ។ តែយ៉ាងណាក្តីការប្រជែងគ្នានៅក្នុងចំណោមគណបក្ស ដើម្បីបង្កើនអំណាចនិងឥទ្ធិពលរបស់គេបានបង្កើតអោយមានការមិនសប្បាយចិត្តនៅក្នុងចំណោមសមាជិកក្រុមប្រឹក្សាឃុំហើយប៉ះពាល់ដល់ការធ្វើការរួម គ្នារបស់គេ ។

**<u>ឧបសម្ព័ន្ធ ៥</u>**

**ករណីសិក្សាទី ៥**

## ឃុំមេទឹក ស្រុកបាកាន

## ខេត្តពោធិសាត់

## ត្រូវបានជ្រើសរើសនិងជួយដោយអង្គការ Concern Worldwide

### ប្រវត្តិ

មេទឹកគឺជាឃុំមួយនៅក្នុងចំណោមឃុំចំនួន ១០នៅក្នុងស្រុកបាកាន ខេត្តពោធិសាត់ ។ ឃុំមេទឹកមានភូមិចំនួន១៥ ហើយមានប្រជាជនសរុបចំនួន ២៤៤៦គ្រួសារ ។ ភូមិចំនួនបីនៅក្នុងចំណោមភូមិទាំង ១៥នេះស្ថិតនៅតាមដងទន្លេសាបហើយលិចទឹកជាច្រើនខែក្នុងមួយឆ្នាំ ។ ភាគច្រើនប្រជាជននៅក្នុងភូមិនេះជាអ្នកធ្វើស្រែ ។ ក្រៅពីនេះ គេនេសាទ ដាំដំណាំលក់ ហើយនិងជួញដូរតូចតាច ។ នៅក្នុងរយៈពេល ៥ឆ្នាំកន្លងទៅ ឃុំនេះទទួលរងនូវភាពរាំងស្ងួតហើយនិងទឹកជំនន់ ។ ការនេះបង្ខំអោយប្រជាជនជាច្រើនត្រូវចាកចេញទៅធ្វើការនៅប្រទេសថៃនិងតំបន់ព្រំដែនខ្មែរថៃ ។ ស្ត្រីក្មេងៗខ្លះមករកការងារធ្វើតាមរោងចក្រកាត់ដេរនៅភ្នំពេញ ។ គេត្រឡប់ទៅភូមិវិញដោយមានជំងឺដូចជាគ្រុនចាញ់និងអេដស៍ ។

Concern Worldwide បានចាប់ផ្តើមការងារអភិវឌ្ឍន៍នៅក្នុងឃុំមេទឹកនៅក្នុងឆ្នាំ១៩៩៩ ។ អង្គការនេះបានជួយលើកកំពស់សមត្ថភាពលើផ្នែកអភិវឌ្ឍន៍ជនបទ ហើយនៅក្នុងពេលថ្មីៗនេះជួយដល់ដំណើរការវិមជ្ឈការ ។ អង្គការបានផ្តល់ការបណ្តុះបណ្តាលដល់គណៈកម្មការអភិវឌ្ឍន៍ភូមិ លើការអភិវឌ្ឍន៍សហគមន៍និងការគ្រប់គ្រងគំរោងដើម្បីជួយដល់ការងារធនាគារស្រូវ ធនាគារជ្រូក និងធនាគារគោ ។ អង្គការបានផ្តល់ការបណ្តុះបណ្តាលដល់សមាជិកក្រុមប្រឹក្សាឃុំលើអភិបាលកិច្ចល្អនិងការធ្វើកម្មវិធីអភិវឌ្ឍន៍ ។

ក្រុមប្រឹក្សាឃុំមេទឹកមានសមាជិកចំនួន ៩នាក់ ។ ៦នាក់មកពីគណបក្សប្រជាជន ២នាក់មកពីគណបក្សហ៊្វុនស៊ិនប៉ិច និងម្នាក់មកពីគណបក្សសមរង្ស៊ី ។ មេឃុំមកពីគណបក្សប្រជាជន ជំទប់ទី១ មកពីគណបក្សហ៊្វុនស៊ិនប៉ិច និងជំទប់ទី២មកពីគណបក្សសមរង្ស៊ី ។ សមាជិកក្រុមប្រឹក្សាឃុំទាំងអស់នោះសុទ្ធតែជាបុរស ។

**រដ្ឋបាលឃុំ**

*ការប្រែប្រួលចាប់តាំងពីការបង្កើតក្រុមប្រឹក្សាឃុំមក*

យោលទៅតាមសមាជិកក្រុមប្រឹក្សាឃុំ និយាយថាមានការផ្លាស់ប្តូរច្រើនចាប់តាំងពីការបោះឆ្នោតក្រុមប្រឹក្សាឃុំមក ។ ពីមុនមេឃុំដែលត្រូវបានតែងតាំងនោះសំរេចអ្វីៗតែម្នាក់ឯង ផ្អែកតាមការបញ្ជាពីថ្នាក់លើ ។ ឥឡូវ ក្រុមប្រឹក្សាឃុំដែលកើតឡើងមកតាមការបោះឆ្នោតរួមមានសមាជិកចំនួន ៩នាក់មកពីគណបក្សបីផ្សេងគ្នា គេពិភាក្សាគ្នាលើបញ្ហានានាមុននឹងសំរេចចិត្ត ។ តួនាទីនិងការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាឃុំឥឡូវត្រូវបានកំណត់ច្បាស់ ។ សមាជិកក្រុមប្រឹក្សាឃុំបាននិយាយថា ការប្រើប្រាស់ថវិកាអភិវឌ្ឍន៍គឺមានតម្លាភាពពីព្រោះលុយត្រូវបានទុកដាក់ និងបញ្ចេញតាមរយៈរតនាគារខេត្ត ។

តំណាងរបស់អង្គការប្រជាជនបានកត់សំគាល់ថា មានការប្រែប្រួលនៅក្នុងរដ្ឋបាលឃុំ ។ គេនិយាយថានៅមុនពេលបង្កើតក្រុមប្រឹក្សាឃុំមេឃុំទទួលខុសត្រូវលើអ្វីៗគ្រប់យ៉ាង ដូច្នេះការងារនិងការផ្សព្វផ្សាយពតិមានមានភាពយឺតយ៉ាវ ។ រដ្ឋបាលឃុំមុនមិនមានរចនាសម្ព័ន្ធចាត់តាំង គ្មានសកម្មភាពធ្វើផែនការ ហើយមិនមានធ្វើគំរោងអ្វីត្រូវបានអនុវត្តន៏ទេ ។ ឥឡូវនេះ ក្រុមប្រឹក្សាឃុំមានសមាជិក ៩នាក់ ការងារលឿនជាងមុន ហើយការចែករំលែកពតិមានក៏បានទាន់ពេលវេលា ។ មានរចនាសម្ព័ន្ធចាត់តាំងហើយប្រជាជនចូលរួមនៅក្នុងការធ្វើផែនការនិងអនុវត្តន៏ ។ ទោះជាយ៉ាងណាក្តី ក៏នៅមានបញ្ហាលំអៀងនិងការរើសអើងទៅតាមគណបក្សនយោបាយដែរ ។

បុគ្គលិករបស់អង្គការ Concern Worldwide ទទួលស្គាល់ថាមានការផ្លាស់ប្តូរនៅក្នុងរចនាសម្ព័ន្ធរដ្ឋបាលដោយមាន សមាជិកច្រើននៅក្នុងក្រុមប្រឹក្សាហើយនិងមានការផ្ទេរអំណាចច្រើននៅក្នុងចំណោមពួកគេ ។ សមាជិកក្រុមប្រឹក្សាតំណាងអោយគណបក្សរបស់គេ ហើយគេសំរេចអ្វីៗក្រោយពីមានការពិភាក្សានិងពិគ្រោះយោបល់គ្នា ។ ទោះបីជាបានប្រសើរយ៉ាងនេះក្តី បុគ្គលិករបស់ Concern Worldwide បាននិយាយថាមួយភាគធំនៃការងាររបស់ក្រុមប្រឹក្សា នៅវិលវល់តែជុំវិញផលប្រយោជន៏របស់គណបក្ស ។ បុគ្គលិកអង្គការ Concern Worldwide បាននិយាយថាសមាជិក ក្រុមប្រឹក្សាទទួលខុសត្រូវចំពោះគណបក្សរបស់គេជាងចំពោះប្រជាជនដែលជាអ្នកបោះឆ្នោតអោយគេ ។ អង្គការ គិតថាសមត្ថភាពរបស់សមាជិកក្រុមប្រឹក្សាឃុំនៅមានកំរិតនៅឡើយនៅក្នុងការធ្វើកម្មវិធីអភិវឌ្ឍន៏ ។ អភិបាល ស្រុកបាកានបានកត់សំគាល់ថាសមត្ថភាពរបស់ ក្រុមប្រឹក្សាឃុំមេទឹកនៅខ្សោយ ។

*ស្ថាប័នការងារ*

អង្គការ Concern Worldwide ហើយនិងសីលាបានសហការគ្នាបើកវគ្គបណ្តុះបណ្តាលផ្សេងៗដល់សមាជិកក្រុមប្រឹក្សាឃុំលើប្រធានបទនានាដូចជាការគ្រប់គ្រងបែបវិមជ្ឈការ ការគ្រប់គ្រងប្រព័ន្ធហិរញ្ញវត្ថុ ទស្សនៈនៃការអភិវឌ្ឍន៍ ការរៀបចំថវិកានិងផែនការសំរាប់រយៈពេល ៥ឆ្នាំ ។ សមាជិកក្រុមប្រឹក្សាឃុំសប្បាយនឹងចូលរួមនៅក្នុងការបណ្តុះបណ្តាលនេះ ហើយសុំអោយមានជាបន្ថែមទៀត ដើម្បីកសាងសមត្ថភាពរបស់គេនៅក្នុងការបំពេញតួនាទីនិងការ ទទួលខុសត្រូវរបស់គេម្នាក់ៗ ។

ក្រុមប្រឹក្សាឃុំធ្វើការប្រជុំម្តងក្នុងមួយខែហើយរាយការណ៍ពីភារកិច្ចរបស់គេ ។ ស្មៀនឃុំកត់កំណត់ហេតុអង្គប្រជុំ ។ សមាជិកនៃក្រុមប្រឹក្សាឃុំនិយាយថាគេបានប្រជុំទៀងទាត់នៅតាមភូមិដើម្បីស្តាប់ពីកង្វល់របស់មេភូមិហើយនិងអ្នកភូមិ ។ សមាជិកក្រុមប្រឹក្សាឃុំទទួលស្គាល់ថាពីដំបូងការខ្វែងគំនិតគ្នាតាមខ្សែគណបក្សធ្វើអោយគេមានការពិបាកនៅក្នុងការធ្វើការជាមួយគ្នា ។ តែបន្តិចម្តងៗអ្វីៗបានប្រសើរឡើងវិញ ។ ការនេះប្រហែលជាដោយសារការបណ្តុះបណ្តាលដែលគេបានទទួល និងមួយចំណែកទៀតដោយសារទំនាក់ទំនងផ្ទាល់ខ្លួនដែលគេរក្សាមកតាំងពីនៅក្មេងជាមួយគ្នា ។ ការខ្វែងគំនិតគ្នាត្រូវបានដោះស្រាយតាមរយៈការបោះឆ្នោតយកសំលេងភាគច្រើន ។ ការបោះឆ្នោតនេះច្រើនតែគណបក្សប្រជាជនឈ្នះពីព្រោះគេមានសមាជិកច្រើននៅក្នុងក្រុមប្រឹក្សា ។

តាំងពីពេលបង្កើតមក ក្រុមប្រឹក្សាឃុំមេទឹកបានចេញដីការឃុំចំនួន ២ទាក់ទងនឹងបញ្ហានៅក្នុងឃុំ ។ ដីការមួយហាមប្រាមការឆក់ត្រី ហើយដីការមួយទៀតហាមប្រាមការលេងល្បែងស៊ីសង ។ តែដីការទាំងពីរនេះមិនត្រូវបានគេគោរពតាមបានល្អទេ ពីព្រោះមន្ត្រីថ្នាក់លើហើយនិងនគរបាលមិនសូវគាំទ្រ ។ មេឃុំរាយការណ៍ទៀងទាត់ទៅអភិបាលស្រុកនៅក្នុងការប្រជុំប្រចាំខែជាមួយនឹងមេឃុំហើយនិងប្រធានមន្ទីរស្រុកនៅទីស្នាក់ការស្រុក ។ នៅក្នុងអង្គប្រជុំនេះ មេឃុំស្នើសុំជំនួយទៅអភិបាលស្រុកនៅក្នុងការដោះស្រាយបញ្ហានៅក្នុងឃុំ ។ ក្រុមប្រឹក្សាឃុំផ្សព្វផ្សាយពត៌មានទៅអោយអ្នកភូមិតាមរយៈគណកម្មាធិការអភិវឌ្ឍន៍ភូមិ និងមេភូមិ ។

*ទស្សនៈរបស់អ្នកភូមិ*

ដើម្បីយល់អោយបានច្បាស់ពីទស្សនៈរបស់អ្នកភូមិ ក្រុមអ្នកស្រាវជ្រាវបានជួបជាមួយប្រជាជននៅក្នុងភូមិចំនួនបីដែលស្ថិតនៅក្នុងភូមិសាស្ត្រ ខុសៗពីគ្នា គឺភូមិមេទឹក ក្តាត និងអូរព្រាល ។

ជាទូទៅ ក្រុមអ្នកភូមិដែលបានសំភាសមានការខកចិត្តចំពោះការធ្វើកន្លងមករបស់ក្រុមប្រឹក្សាឃុំ ។ អ្នកភូមិបានត្អូញត្អែរថា សមាជិកក្រុមប្រឹក្សាឃុំមិនសូវចុះមើលតាមភូមិទេ ហើយបើចុះទៅមិនឃើញញឹកញាប់ទេ ។ គេនិយាយទៀតថា សមាជិកក្រុមប្រឹក្សាឃុំធ្វើការមិនចុះសំរុងគ្នាទេ ហើយកំរាយការណ៍ប្រាប់អ្នកភូមិពីអ្វីដែលគេធ្វើណាស់ ។ អ្នកឆក់ត្រីមិនទទួលទណ្ឌកម្មទេ ដោយសារមានរួមទាំងបងប្អូនរបស់សមាជិកក្រុមប្រឹក្សាឃុំផង ។ តែក្រុមអ្នកភូមិបានទទួលស្គាល់ថាប្រជាជនបានចូលរួមនៅក្នុងការប្រជុំធ្វើផែនការហើយក្រោយមកចូលរួមនៅក្នុងគំរោងធ្វើផ្លូវតាមរយៈកម្មវិធីស្បៀងពលកម្មដែលជួយដោយអង្គការកម្មវិធីស្បៀងអាហារពិភពលោក ។ ដោយសារមានផ្លូវថ្មី អ្នកភូមិអាចធ្វើដំណើរនិងដឹកជញ្ជូនផលិតផលបានស្រួល ។ ក្មេងកាន់តែច្រើនអាចទៅសាលារៀន ។ ក្រុមអ្នកភូមិបានសំដែងទស្សនៈថា អង្គការ Concern Worldwide សីលានិងអង្គការកម្មវិធីស្បៀងអាហារពិភពលោក ជាអ្នកធ្វើការអភិវឌ្ឍន៍ទាំងអស់ គឺមិនមែនក្រុមប្រឹក្សាឃុំទេ ។

ជារួម ក្រុមអ្នកភូមិដែលបានសំភាសន៍ជាមួយនៅភូមិក្តាតបាននិយាយថា សមាជិកក្រុមប្រឹក្សាឃុំគឺនិយមគណបក្សនយោបាយណាស់ ដូច្នេះទើបសមាជិកក្រុមប្រឹក្សាឃុំតែងតែមិនចុះសំរុងគ្នាហើយមិនបានសំរេចអ្វីទេ ។ ពួកគេចង់អោយសមាជិកក្រុមប្រឹក្សាឃុំឧស្សាហ៍ចុះទៅសួរសុខទុក្ខប្រជាជន ដើម្បីយល់អោយបានច្បាស់ពីបញ្ហារបស់អ្នកភូមិ ។ សមាជិកក្រុមប្រឹក្សាឃុំមិនសូវរាយការណ៍អោយប្រជាជនដឹងទេ ទោះបីជាការិយាល័យឃុំនៅក្បែរនឹងភូមិក្តាតក៏ដោយ ។ បើគេរាយការណ៍គឺគេធ្វើតាមរយៈប្រធានភូមិ ។ អ្នកភូមិមួយចំនួនបានឆ្លើយថាបានចូលរួមនៅក្នុងការប្រជុំធ្វើផែនការជាមួយនឹងក្រុមប្រឹក្សាឃុំ មេភូមិ គណៈកម្មាធិការអភិវឌ្ឍន៍ភូមិ និងអង្គការមិនមែនរដ្ឋាភិបាល ទោះបីជាគេមិនយល់ស្របទៅនឹងលំដាប់អាទិភាពដែលបានសំរេចទៅហើយនោះក៏ដោយ ។ ភាគច្រើននៃក្រុមអ្នកភូមិបាននិយាយថា ផ្លូវហើយនិងសាលារៀនត្រូវបានកសាងឡើងនៅក្នុងភូមិ តែគេមិនច្បាស់ថាតើគំរោងហេដ្ឋារចនាសម្ព័ន្ធទាំងនេះទទួលបានថវិកា តាមរយៈផែនការឃុំឬទទួលថវិកាដោយឡែករបស់អង្គការមិនមែនរដ្ឋាភិបាល ។

ក្រុមអ្នកភូមិដែលបានសំភាសន៍នៅអូរព្រាលសង្កេតឃើញថា ជាទូទៅបេក្ខជនក្រុមប្រឹក្សាឃុំបានចុះមកភូមិរបស់គេញឹកញាប់នៅក្នុងពេលយុទ្ធនាការបោះឆ្នោត តែក្រោយពីបោះឆ្នោតមកគេកំរចុះមកណាស់ ។ អ្នកខ្លះនិយាយថាបើគ្មានលុយពិបាកណាស់ជាមួយនឹងសមាជិកក្រុមប្រឹក្សាឃុំ ។ ក្រុមភាគច្រើនគិតថាអង្គការមិនមែនរដ្ឋាភិបាល ដូចជា Concern Worldwide និង CARE ទទួលខុសត្រូវនិងយកចិត្តទុកដាក់ចំពោះការអភិវឌ្ឍន៍ភូមិ ។ ដោយសារគ្រោះធម្មជាតិដែលមានមកលើភូមិ គ្រួសារជាច្រើននៅក្នុងភូមិអូរព្រាលខ្វះស្បៀង ។ សមាជិកគ្រួសារខ្លះត្រូវចេញ ពីភូមិទៅរកការងារធ្វើនៅប្រទេសថៃ ឬភ្នំពេញដើម្បីរកលុយចិញ្ចឹមគ្រួសារ ។ ដោយប្រឈមនឹងការពិបាកនេះ ធនាគារស្រូវនិងគំរោងឥណទាននៅក្នុងភូមិមានបញ្ហា ។ ទោះជាយ៉ាងណាក្តី មានគ្រួសារច្រើនបាន

ចូលរួមនៅក្នុងការប្រជុំធ្វើផែនការដែលរៀបចំឡើងដោយសីលា ហើយគ្រួសារភាគច្រើនបានចូលរួមវិភាគទានដល់ការជួសជុលផ្លូវ និងគំរោងជីកប្រឡាយ ។ ក្រុមប្រឹក្សាឃុំពឹងលើការជួយរបស់មេភូមិ គណៈកម្មការអភិវឌ្ឍន៍ភូមិ និងអង្គការ Concern Worldwide នៅក្នុងការបំផុសការចូលរួមរបស់ប្រជាជននៅក្នុងគំរោងជួសជុលផ្លូវថ្នល់និងជីកប្រឡាយ ។

## សកម្មភាពធ្វើផែនការនិងអនុវត្តន៍

*ដំណើរការធ្វើផែនការ*

ក្រុមប្រឹក្សាឃុំមេទឹកនិងមានការចូលរួមរបស់សមាជិកគណៈកម្មាធិការផែនការនិងថវិកា បានរៀបចំផែនការអភិវឌ្ឍន៍ឃុំ ៥ឆ្នាំ ។ គណៈកម្មាធិការផែនការនិងថវិកា មានសមាជិកក្រុមប្រឹក្សាឃុំចំនួន ៩នាក់ តំណាងគណៈកម្មការអភិវឌ្ឍន៍ភូមិ ២នាក់ ពីភូមិនីមួយៗក្នុងចំណោម ១៥ ។ សរុបទាំងអស់គណៈកម្មការនេះមានសមាជិកចំនួន ៣៩នាក់ ។ ដំណើរការធ្វើផែនការចាប់ផ្តើមពីថ្នាក់ភូមិដោយមានធ្វើការសិក្សាវាយតំលៃពីតំរូវការនិងកំណត់អាទិភាព ។ តំណាងគណៈកម្មការអភិវឌ្ឍន៍ភូមិ ប្រធានភូមិនិងបុគ្គលិក Concern Worldwide បានចូលរួមសកម្មក្នុងការងារនោះ ។ បុគ្គលិកអង្គការ Concern Worldwide បាននិយាយថា មានប្រជាជនចូលរួមពី ៥៥ ទៅ ៦០ភាគរយ នៅក្នុងការសិក្សាវាយតំលៃទាំងនេះ ។ គណៈកម្មាធិការផែនការនិងថវិកាបានពិនិត្យមើលឡើងវិញ លើផែនការភូមិនៅថ្នាក់ឃុំដោយមានជំនួយពីបុគ្គលិកសីលានិងអង្គការ Concern Worldwide ។ អាទិភាពរបស់ភូមិបន្ទាប់មក ត្រូវបានបូកសរុបទៅជាអាទិភាពរបស់ឃុំ ហើយគំរោងថវិកាត្រូវបានកំណត់ ។ ផែនការឃុំដែលលេចចេញមកត្រូវ បានយកទៅឧទ្ទេសនាមនៅក្នុងសិក្ខាសាលាសមាហរណកម្មថ្នាក់ស្រុកដើម្បីសុំថវិកាបន្ថែមលើថវិកាដែលផ្តល់អោយដោយរដ្ឋ ។ តាមធម្មតា Concern Worldwide យល់ព្រមជួយថវិកាដល់សកម្មភាពដែលមាននៅក្នុងផែនការរបស់ឃុំ ដូចជាគំរោងជួសជុលផ្លូវថ្នល់ស្របទៅតាមគោលបំណងរបស់គេ ។ ក្រុមប្រឹក្សាឃុំបានអោយដឹងថាថវិកា ដែលទទួលបានពីអង្គការ Concern Worldwide គឺមានច្រើន ។ បើក្រុមប្រឹក្សាឃុំពឹងផ្អែកតែទៅលើថវិកាឃុំ ដែលបានមកពីរដ្ឋាភិបាលនោះ គេមិនអាច អនុវត្តន៍ការងារភាគច្រើនដែលមាននៅក្នុងផែនការនោះទេ ។

*ការអនុវត្តន៍ការងារ*

ក្រុមប្រឹក្សាឃុំទទួលបានលុយប្រហែល ៤១លានរៀលក្នុងមួយឆ្នាំសំរាប់ការងារអភិវឌ្ឍន៍ ។ ថវិការបស់ឃុំមានទុកនៅឯរតនាគាររបស់ខេត្ត ។ ក្រុមប្រឹក្សាឃុំក៏បានទទួលផងដែរនូវថវិកាសំរាប់ចំណាយផ្នែករដ្ឋបាល ។ ប្រាក់នេះក៏ត្រូវបានទុកនៅរតនាគារខេត្តដែរ ដោយដាក់នៅក្នុងគណនេយ្យផ្សេងគ្នា ។

សមាជិកក្រុមប្រឹក្សាឃុំទទួលស្គាល់ថាគេមានការពិបាកនៅក្នុងការលើកទឹកចិត្តអោយប្រជាជនចូលរួមនៅក្នុងគំរោងអភិវឌ្ឍន៍ដោយសារនៅក្នុងឃុំមានបញ្ហាខ្វះស្បៀង ។ ក្រុមប្រឹក្សាឃុំនិយាយថាប្រជាជនច្រើនចូលចិត្តចូលរួមនៅក្នុងគំរោងស្បៀងពលកម្មដូចជាការជួសជុលផ្លូវ និងការជីកប្រឡាយអោយជ្រៅថែមទៀត ។ នៅក្នុងឆ្នាំ ២០០៣ ក្រុមប្រឹក្សាឃុំបានធ្វើការច្រើនជាមួយនឹងអង្គការ Concern Worldwide ហើយនិងសីលាដើម្បីធ្វើផ្លូវ និងប្រឡាយស្រោចស្រព ។ ក្រុមប្រឹក្សាឃុំរំពឹងមកលើអង្គការ Concern Worldwide ហើយនិងសីលាអោយជួយលើការតាមដានគំរោង ។ សមាជិកក្រុមប្រឹក្សាឃុំនិងតំណាងអង្គការប្រជាជនដែលបានសំភាសន៏យល់ស្របគ្នាថា អ្នកធូរធារបានទទួលផលចំណេញច្រើនជាងគេពីគំរោងកសាងផ្លូវ ។

ក្រុមប្រឹក្សាឃុំរាយការណ៍ថាភូមិចំនួនប្រាំនៅក្នុងតំបន់កម្មវិធីរបស់អង្គការ Concern Worldwide បានទទួលជំនួយភាគច្រើន ។ ក្រុមអ្នកសំរបសំរួលថ្នាក់ស្រុកយល់ដូចការសង្កេតឃើញនេះដែរ ។ នេះមានន័យថាភូមិភាគច្រើននៅក្នុងឃុំបានទទួលជំនួយតិចពីគំរោងអភិវឌ្ឍន៍ឃុំ បើទោះបីជាភូមិទាំងនេះបានចូលរួមនៅក្នុងការប្រជុំធ្វើផែនការក្តី ។ អង្គការ Concern Worldwide ចង់អនុវត្តគំរោងដោយរួមគ្នាជាមួយក្រុមប្រឹក្សាឃុំនិងផ្តល់ថវិកាផងដែរ នេះដោយសារអង្គការ Concern Concern Worldwide យល់ឃើញថាសមត្ថភាពរបស់សមាជិកក្រុមប្រឹក្សាឃុំនៅមានកំរិតនៅឡើយ អង្គការនេះមិនចង់ផ្តល់ថវិកាអោយក្រុមប្រឹក្សា ដើម្បីអោយគេគ្រប់គ្រងគំរោងទេ ។ ដូច្នោះក្រុមប្រឹក្សាឃុំបានសំរួលផែនការឃុំ អោយស៊ីទៅនឹងកម្មវិធីរបស់ Concern Concern Worldwide ដើម្បីអោយប្រាកដថាមានថវិកាសំរាប់គំរោង ។

## ភាពជាដៃគូរវាងក្រុមប្រឹក្សាឃុំហើយនិងសង្គមស៊ីវិល

*ទំនាក់ទំនងជាមួយនឹងអង្គការប្រជាជន*

ក្រុមប្រឹក្សាឃុំមេទឹកពឹងផ្អែកជាសំខាន់លើមេភូមិអោយផ្សព្វផ្សាយពត៌មានទាក់ទងនឹងរដ្ឋបាលឃុំ ។ តែទាក់ទងនឹងការធ្វើផែនការអភិវឌ្ឍន៍និងការអនុវត្តន៏គំរោង ក្រុមប្រឹក្សាឃុំធ្វើការជិតស្និទ្ធជាមួយនឹងគណៈកម្មការអភិវឌ្ឍន៍ភូមិ ។ គណៈកម្មាធិការផែនការនិងថវិកា មានសមាជិកដែលមកពីគណៈកម្មការអភិវឌ្ឍន៍ភូមិពីរនាក់មកពីភូមិនីមួយៗនៅក្នុងឃុំ ហើយពួកគេបានចូលរួមយ៉ាងសកម្មនៅក្នុងដំណើរការធ្វើផែនការឃុំ ។ ក្រុមប្រឹក្សាឃុំក៏ពឹងផ្អែកលើគណៈកម្មការអភិវឌ្ឍន៍ភូមិ ' ក្នុងការបំផុសការចូលរួមរបស់អ្នកភូមិនៅក្នុងការអនុវត្តន៏គំរោងអភិវឌ្ឍន៏ឃុំ ។ ការចូលរួមរបស់អាជ្ញាធមិឃុំនៅក្នុងការងារអភិវឌ្ឍន៍នានា វាបានផ្តល់ឱកាសអោយក្រុមប្រឹក្សាឃុំនិងសមាគមប្រជាជនផ្សេងៗអាចធ្វើការជាមួយគ្នា ថែមទាំងបង្កើនការសហការណ៏និងសំរបសំរួលគ្នា ។ តែទោះជាមានភាពស្និទ្ធស្នាលនឹងគ្នាយ៉ាងនេះក្តី ក៏ភាពជាដៃគូពិតប្រាកដមិនទាន់ឃើញមាននៅឡើយទេ ។ តាមពិតទៅ

គណៈកម្មការអភិវឌ្ឍន៍ភូមិហើយនិងអង្គការប្រជាជនទាំងអស់ធ្វើការច្រើនជាមួយនឹង Concern Worldwide ហើយនិងសីលា ជាងជាមួយនឹងក្រុមប្រឹក្សាឃុំ ។

*ទំនាក់ទំនងជាមួយនឹងអង្គការមិនមែនរដ្ឋាភិបាល*

ក្រុមប្រឹក្សាឃុំមេទឹកកត់សំគាល់ឃើញថា អង្គការ Concern Worldwide សហប្រតិបត្តិការ និងសំរបសំរួលជាមួយនឹងពួកគេយ៉ាងជិតស្និទ្ធដើម្បីតាក់តែងនិងអនុវត្តន៍ផែនការអភិវឌ្ឍន៍ឃុំ រីឯអង្គការមិនមែនរដ្ឋាភិបាលផ្សេងទៀតគ្រាន់តែជំរាបប្រាប់គេពីសកម្មភាពរបស់ពួកគេនៅក្នុងឃុំ ។ ក្រុមប្រឹក្សាឃុំទទួលបានផលចំណេញពីការចូលរួមយ៉ាងសកម្មរបស់ Concern Worldwide នៅក្នុងដំណើរការវិមជ្ឈការ ។ Concern Worldwide បានប្រកាន់ជំហ៊ានច្បាស់លាស់នៅក្នុងការបញ្ចូល កម្មវិធីកសាងសមត្ថភាពដើម្បីការអភិវឌ្ឍន៍ជនបទ (CBRD) របស់ខ្លួនទៅក្នុងក្របខ័ណ្ឌនៃផែនការអភិវឌ្ឍន៍ឃុំ ។ ដើម្បីធ្វើអោយសំរេចបាននូវគោលដៅរបស់ខ្លួន Concern Worldwide ត្រូវតែវាយតំលៃ និងតាមដានដោយប្រុងប្រយ័ត្ន លើសមត្ថភាពរបស់ខ្លួនជាមួយនឹងក្រុមប្រឹក្សាឃុំដើម្បីរកមើលលទ្ធភាពក្នុងការផ្លាស់ប្តូរសកម្មភាពមួយចំនួន អោយឆ្លើយតបទៅនឹងចំនុចអាទិភាព ហេតុដូចនេះហើយចំពោះទំនាក់ទំនងរបស់ក្រុមប្រឹក្សាឃុំជាមួយនឹង Concern Worldwide ពិតជាមានសារៈសំខាន់ណាស់ ពោលគឺលើសពីភាពជាដៃគូទៅទៀត ។

## ទំនាក់ទំនងជាមួយនឹងរដ្ឋាភិបាលថ្នាក់ជាតិហើយនិងគណបក្សនយោបាយ

ក្រុមប្រឹក្សាឃុំ បានរាយការណ៍ទៀងទាត់ទៅអភិបាលស្រុកហើយនិងប្រធានមន្ទីរ អំពីស្ថានភាពនៅក្នុងឃុំ ហើយនិងការងាររបស់ក្រុមប្រឹក្សាឃុំ ។ សមាជិករបស់ក្រុមប្រឹក្សាឃុំក៏បានសំរបសំរួលល្អជាមួយនឹងកម្មវិធីសីលា ហើយនិងក្រុមសំរបសំរួលថ្នាក់ស្រុក ។

នៅក្នុងរង្វង់ក្រុមប្រឹក្សាឃុំមេទឹក ការប្រកាន់តាមខ្សែគណបក្សរបស់ពួកគេ ជាទូទៅវាមានការរាំងស្ទះការងាររបស់ក្រុមប្រឹក្សា ។ សមាជិកក្រុមប្រឹក្សាឃុំបានសារភាពថា គេមានការមិនយល់ស្របគ្នាធំៗមួយចំនួនដែរ តែគេគិតថាទំនាក់ទំនងការងាររបស់ពួកគេកាន់តែបានប្រសើរឡើងហើយឥឡូវនេះ ។ តែនេះមិនមែនជាការយល់ឃើញរបស់អ្នកភូមិ តំណាងអង្គការប្រជាជនហើយនិងបុគ្គលិករបស់ Concern Worldwide ទេ ។ ក្រុមទាំងនេះបាននិយាយថា ក្រុមប្រឹក្សាឃុំដែលមកពីគណបក្សទាំងបី បានតំកល់ប្រយោជន៍ និង ខិតខំជំរុញមុខមាត់គណបក្សរបស់គេខ្ពស់ជាងការងារនៅក្នុងឃុំ ។ ជាលទ្ធផល គឺក្រុមប្រឹក្សាឃុំមិនអាចធ្វើអោយអ្នកភូមិជឿថា ក្រុមខ្លួនកំពុងតែធ្វើការដើម្បីផលប្រយោជន៍របស់ប្រជាជនទេ ហើយលើសពីនេះទៀតប្រជាជនបានប្រៀបធៀបថា រដ្ឋបាលឃុំឥឡូវនេះ វាមិនខុសអ្វីពីរដ្ឋអំណាចឃុំមុននោះទេ ។

## ឧបសម្ព័ន្ធ ៦

### អ្នកចូលរួមនៅក្នុងការស្រាវជ្រាវ

| | |
|---|---|
| Huy Komnith | American Friends Service Committee (AFSC) |
| Nop Sarin Sreyroth | Cambodian Women's Crisis Center (CWCC) |
| Kim Morokath | Dan Church Aid (DAC) |
| Keo Chenda | Enfants et Development (E&D) |
| Bun Sophat | Food for the Hungry International (FHI) |
| Seng Tinekor | Food for the Hungry International (FHI) |
| Um Phor | Food for the Hungry International (FHI) |
| Ea Dy | Family Health Promotion (FHP) |
| Hun Leakhena | Krom Akphiwat Phum (KAWP) |
| Yim Nimola | Khmer Women's Voice Center (KWVC) |
| Oum Ravy | Khmer Women's Voice Center (KWVC) |
| Muth Sokunny | Khmer Youth Association (KYA) |
| Kol Leakhana | NGO Forum |
| Heng Sokha | Non Timber Forest Products (NTFP) |
| In Sopheap | Sor Sor Troung (SST) |
| Chet Charya | Star Kampuchea |
| Ea Tharady | Star Kampuchea |
| Tou Tony | Vicheasthan Bandosbondal Neakropkrong Kangea Aphivath (VBNK) |
| Pen Vuthy | Vicheasthan Bandosbondal Neakropkrong Kangea Aphivath (VBNK) |
| Hen Heang | World Vision Cambodia (WVC) |
| Ly Khom | World Vision Cambodia (WVC) |

### ក្រុមអ្នកស្រាវជ្រាវរបស់គំរោង ADI

| | |
|---|---|
| Oeur Il | Cooperation Committee for Cambodia/ADI Project |
| Seng Savuth | Cooperation Committee for Cambodia/ADI Project |
| Ang Sopha | Cooperation Committee for Cambodia/ADI Project |
| Hor Sakphea | Cooperation Committee for Cambodia/ADI Project |
| John McAndrew | Cooperation Committee for Cambodia/ADI Project |